ហាមលក់

ក្រសួងអប់រំ យុវជន និងកីឡា

# សេដ្ឋកិច្ចវិទ្យា

## ១១

## កំណែ



គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

ជំពូកទី១ សេដ្ឋកិច្ចទីផ្សារនិងផលិតកម្ម

មេរៀនទី១ ប្រព័ន្ធសេដ្ឋកិច្ច

## សំណួរ

2. ចូរអ្នកស្រាវជ្រាវរកចម្លើយ ដើម្បីឆ្លើយតបនឹងសំណួរពិភាក្សាខាងក្រោម:

ក.អ្វីដែលហៅថា "សេដ្ឋកិច្ច" ?ចូរពន្យល់សញ្ញាណរបស់វាឱ្យបានច្បាស់លាស់។

ខ.តើសេដ្ឋកិច្ចមានប៉ុន្មានប្រភេទ?អ្វីខ្លះ ?

គ.ដូចម្តេចហៅថា សេដ្ឋកិច្ចទីផ្សារសេរី ?

ឃ.ដូចម្តេចហៅថា សេដ្ឋកិច្ចបញ្ជា ?

ង. ដូចម្តេចហៅថា សេដ្ឋកិច្ចចម្រុះ ?

ច.តើ "វិទ្យាសាស្ត្រសេដ្ឋកិច្ច" មានន័យដូចម្តេច ?

ឆ.ដូចម្តេចហៅថា "ការអភិវឌ្ឍសង្គម"?ក្នុងពេលធ្វើការអភិវឌ្ឍសង្គម តើគេតែងជួបប្រទះឃើញសកម្មភាពអ្វីខ្លះលេចធ្លោឡើង? តើសកម្មភាពទាំងនោះមានផលប៉ះពាល់ ចំពោះបរិស្ថានធម្មជាតិនិងបរិស្ថានសង្គមដែរឬទេ?ប្រសិនបើមាន តើអ្វីជាផលប៉ះពាល់ទាំងនោះ?

ឃ.តើគេត្រូវធ្វើការអភិវឌ្ឍសង្គមតាមវិធីណា ដើម្បីកុំឱ្យប៉ះពាល់ចំពោះបរិស្ថានធម្មជាតិនិងសង្គម?

---

## ចម្លើយ

2. ក.សេដ្ឋកិច្ច គឺជាការសិក្សាអំពីរបៀបដែលបុគ្គល ក្រុមគ្រួសារ សង្គម ដែលចេះលៃលកប្រើប្រាស់នូវធនធានដែលមាននៅក្នុងការផលិតចេញជាផលិតផលនិងបង្កើតសេវាកម្មផ្សេងៗ ដើម្បីបំពេញនូវសេចក្ដីត្រូវការឥតព្រំដែនរបស់មនុស្ស។

ខ.សេដ្ឋកិច្ចមាន៣ប្រភេទគឺ:

✓សេដ្ឋកិច្ចទីផ្សារសេរី

✓សេដ្ឋកិច្ចបញ្ជា ឬសេដ្ឋកិច្ចផែនការ

✓សេដ្ឋកិច្ចចម្រុះ

គ.សេដ្ឋកិច្ចទីផ្សារសេរីគឺជាប្រព័ន្ធសេដ្ឋកិច្ចដែលកម្មសិទ្ធិលើធនធានសេដ្ឋកិច្ចឬកត្តាផលិតកម្មមួយភាគធំស្ថិតនៅក្នុងរង្វង់ការគ្រប់គ្រងរបស់ផ្នែកឯកជនដែលជានិតិបុគ្គលឬរូបវន្តបុគ្គល និងមានសេរីភាពក្នុងការធ្វើអាជីវកម្ម។

ឃ.សេដ្ឋកិច្ចបញ្ជាគឺជាប្រព័ន្ធសេដ្ឋកិច្ចដែល រដ្ឋមានកម្មសិទ្ធិលើធនធាននិងកត្តាផលិតកម្មស្ទើរតែទាំងអស់ ឯយន្តការគ្រប់គ្រងនិងសម្របសម្រួលផ្អែកលើមូលដ្ឋានផែនការរបស់រដ្ឋ ។

ង.សេដ្ឋកិច្ចចម្រុះ គឺជាប្រព័ន្ធសេដ្ឋកិច្ចដែលមានលាយបញ្ចូលគ្នារវាប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី និងសេដ្ឋកិច្ចបញ្ជា ឬសេដ្ឋកិច្ចផែនការគឺមានន័យថា វិស័យឯកជននិងវិស័យរដ្ឋមានតួនាទីយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍប្រទេសជាតិ។ឧទាហរណ៍:នៅពេលរដូវកាលស្រូវចុះថោក រដ្ឋត្រូវទិញស្រូវរក្សាទុកដើម្បីលក់ចេញនៅរដូវស្រូវឡើងថ្លៃ។

ច.វិទ្យាសាស្ត្រសេដ្ឋកិច្ច ជាវិទ្យាសាស្ត្រសិក្សាស្រាវជ្រាវរកវិធីដោះស្រាយបញ្ហាប្រើប្រាស់ធនធានសេដ្ឋកិច្ចដែលយើងមានដោយកម្រនិងគ្រប់គ្រងចង្វាក់ផលិតកម្មទាំងអស់ឱ្យចំទីកន្លែងត្រូវពេលវេលា និងប្រកបដោយភាពសក្តិសិទ្ធិដើម្បីបំពេញឱ្យបាននូវតម្រូវការរបស់សង្គមមនុស្ស។

ឆ.ការអភិវឌ្ឍសង្គម មានន័យថាធ្វើឱ្យសង្គមទទួលបាននូវការផ្គត់ផ្គង់ទាំងផ្នែកសម្ភារៈនិងទាំងផ្នែកស្មារតី ទៅតាមសេចក្តីត្រូវការ។

- សកម្មភាពទាំងនោះ មានផលប៉ះពាល់ចំពោះបរិស្ថានធម្មជាតិនិងបរិស្ថានសង្គមយ៉ាងខ្លាំងដូចជា:
- ផលប៉ះពាល់ចំពោះបរិស្ថានធម្មជាតិ:បញ្ហាការពារនិងគ្រប់គ្រងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របមានសារៈសំខាន់ណាស់។ ការខ្ជះខ្ជាយនិងការប្រើប្រាស់ដោយគ្មានសនិទានភាពនូវប្រភេទធនធានធម្មជាតិដែលមិនអាចបង្កើតមកវិញបាន តែងការផ្តាច់និរន្តភាពនៃការអភិវឌ្ឍនិងនាំមកនូវភាពក្រីក្រនិងបដិវាទកម្មនៅក្នុងសេដ្ឋកិច្ចប្រទេសជាតិ។
- ផលប៉ះពាល់ចំពោះបរិស្ថានសង្គម:ចំណាយមួយផ្នែកធំត្រូវបានចំណាយទៅលើសេវាកម្មកម្សាន្ត និងកាត់បន្ថយមួយផ្នែកធំនៃការសន្សំរបស់ជាតិ។

ជ.ដើម្បីអភិវឌ្ឍសង្គម ដោយគ្មានការប៉ះពាល់ចំពោះបរិស្ថានធម្មជាតិ និងសង្គមគឺយើងត្រូវប្រើប្រាស់ធនធាន

ដោយមានការគ្រប់គ្រងល្អ និងប្រើប្រាស់ធនធានដែលមានដើម្បីបំពេញនូវសេចក្ដីតម្រូវការជាមូលដ្ឋានជាមុនសិន ចៀសវាងការប្រើប្រាស់ធនធានកម្រដោយខ្ជះខ្ជាយ តាមបែបហ៊ឺហារ។

---

មេរៀនទី២ **ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ**

សំណួរ

2. ចូរអ្នកស្រាវជ្រាវនិងពិភាក្សាជាមួយដៃគូ ឬសមាជិកដទៃទៀតក្នុងក្រុមដើម្បីដោះស្រាយសំណួរដូចខាងក្រោម

ក.មុននឹងសម្រេចចិត្តជ្រើសយកអាជីវកម្មឬសេវាកម្មណាមួយ តើមានញ្ហាអ្វីខ្លះដែលអាជីវករ ឬសហគ្រិនត្រូវគិត?

ខ.តើអាជីវករ ឬសហគ្រិនត្រូវគិតដូចម្ដេចខ្លះលើបញ្ហាត្រូវផលិតអ្វី?

គ.ហេតុអ្វីគេនិយាយថា ការបែងចែកទំនិញក្នុងសេដ្ឋ

កិច្ចទីផ្សារពុំមានគោលការណ៍សីលធម៌?

ឃ.តើអាជីវករត្រូវការជ្រើសយកអ្វីខ្លះ ដើម្បីបានជោគជ័យក្នុងការប្រកួតប្រជែងលើសេដ្ឋកិច្ចទីផ្សារ?

---

## ចម្លើយ

1.ក.មុននឹងសម្រេចចិត្តជ្រើសយកអាជីវកម្មឬសេវាកម្មណាមួយ អាជីវករ ឬសហគ្រិនត្រូវគិតទៅលើធនធាន (ធនធានមនុស្ស ធនធានសម្ភារៈ និងធនធានហិរញ្ញវត្ថុ) ដែលខ្លួនមាន ហានិភ័យដែលអាចកើតមានឡើង ឱកាសក្នុងការធ្វើអាជីវកម្ម និងត្រូវធ្វើស្វែងយល់ពីស្ថានភាពសេដ្ឋកិច្ច។(ប្អូនៗអាចឆ្លើយលើសពីនេះ)

ខ.លើបញ្ហាដែលត្រូវផលិត អាជីវករ ឬសហគ្រិនចាំបាច់ត្រូវគិតពីលទ្ធភាពរបស់ខ្លួន មានវត្ថុធាតុដើមគ្រប់គ្រាន់ គុណភាព តម្លៃ និងតម្រូវរបស់អតិថិជន។ ត្រូវផលិតតែមុខទំនិញណាដែលគេត្រូវការមិនចាំផលិតទំនិញដែលគ្មានអ្នកទិញនោះទេ។

គ.ការបែងចែកទំនិញក្នុងសេដ្ឋកិច្ចទីផ្សារ ពុំមានគោល

ការណ៍សីលធម៌ទេពីព្រោះសេដ្ឋកិច្ចទីផ្សារមាន ប្រកួតប្រជែងដោយសេរី ដែលអាចធ្វើឲ្យសហគ្រាសមួយធ្វើការបង្អាប់បង្អោនទំនិញរបស់សហគ្រាសមួយដោយសេរី និងធ្វើការលក់ផលិតផលក្នុងតម្លៃថោកជាហេតុធ្វើបាត់បង់នូវស្តង់ដាររបស់ទំនិញ។

ឃ.ដើម្បីជោគជ័យក្នុងការប្រកួតប្រជែងលើសេដ្ឋកិច្ចទីផ្សារ អាជីវករត្រូវការជ្រើស និងប្រើប្រាស់នូវបច្ចេកវិទ្យាទំនើប និងមានតម្លៃថោក គុណភាពល្អ។

---

# មេរៀនទី៣

## ការវាយតម្លៃប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ

### សំណួរ

2. ចូរអ្នកធ្វើការស្រាវជ្រាវនិងពិភាក្សាជាមួយដៃគូ ឬជាមួយសមាជិកក្នុងក្រុមដើម្បីដោះស្រាយសំណួរខាងក្រោម:

ក.តើក្រុមអ្នកគាំទ្រប្រព័ន្ធសេដ្ឋកិច្ចទីផ្សារបានផ្តល់ទឡ្ហីករណ៍ដូចម្តេចខ្លះ?

ខ.តើក្រុមអ្នកប្រឆាំងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ បានផ្តល់ទឡ្ហីករណ៍ដូចម្តេចខ្លះ?

គ.តើអ្នកគាំទ្រទឡ្ហីករណ៍ណាមួយ? ហេតុអ្វី?

---

### ចម្លើយ

2.ក.ក្រុមអ្នកគាំទ្រប្រព័ន្ធសេដ្ឋកិច្ចទីផ្សារបានផ្តល់ទឡ្ហីករណ៍ដូចជា:

- ការប្រកួតប្រជែង
- ដៃអរូប

- ការធ្វើនិយ័តកម្មសេដ្ឋកិច្ចតាមរបៀបរដ្ឋបាលប្រមូលផ្តុំ ឬបញ្ជា
- ការធ្វើនិយ័តកម្មសេដ្ឋកិច្ចតាមបែបសេដ្ឋកិច្ចទីផ្សារ

ខ.ក្រុមអ្នកប្រឆាំងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារបានផ្តល់ទស្សនៈទឡ្ហីករណ៍ដូចជា:

- បំណោងប្រាថ្នារកចំណូល
- ការរីចម្រើននៃបច្ចេកវិទ្យាទំនើបនាំឱ្យការប្រកួតប្រជែងចុះខ្សោយ
- វិសមភាពក្នុងការបែងចែកផលិតផល
- កង្វះការផ្គត់ផ្គង់សេវាសាធារណៈ

គ.យោងតាមអត្ថន័យនៃទឡ្ហីករណ៍គាំទ្រនិងទឡ្ហីករណ៍ប្រឆាំងសេដ្ឋកិច្ចទីផ្សារខ្ញុំគាំទ្រទឡ្ហីករណ៍គាំទ្រប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ពីព្រោះប្រពន្ធ័ទីផ្សារសេរីបានធ្វើឲ្យប្រជាជនទូទៅជាអ្នកទទួលបានផលចំណេញពីការប្រកួតប្រជែងគឺទទួលបានផលិតមានគុណភាពល្អក្នុងតម្លៃថោក។ម្យ៉ាងទៀតប្រពន្ធ័ទីផ្សារសេរិមានសីលណាស់ក្នុងការបែងចែកគុណភាពផលិតផល

ជាក់ស្តែងបច្ចុប្បន្នមានអង្គការស្តង់ដារអន្តរជាតិ(ISO= International Standard Organization ) ធ្វើការធ្វើការបែងចែកគុណភាពផលិតផលលើពិភពលោក។

---



មេរៀនទី៤

## ទីផ្សារ

### សំណួរ

2. ចូរអ្នកពិភាក្សាជាមួយដៃគូឬក្រុមដើម្បីដោះស្រាយនូវសំណួរខាងក្រោម

ក.ដូចម្ដេចហៅថាទីផ្សារ?

ខ.តើមានលក្ខខណ្ឌអ្វីខ្លះដែលធ្វើឱ្យទីផ្សារមានសកម្មភាព?ចូរពន្យល់។

គ.តើមានអន្តរាគមន៍របស់រដ្ឋដែរឬទេក្នុងទីផ្សារ?បើមានតើរដ្ឋបានបំពេញមុខងារអ្វីខ្លះ?

ឃ.នៅទីផ្សារ តើថ្លៃទំនិញ ឬសេវាកម្មត្រូវបានកំណត់ដោយវិធីណា?ចូរពន្យល់។

ង.តើថ្លៃទំនិញស្ថិតក្រោមឥទ្ធិពលអ្វីខ្លះ?ចូររៀបរាប់និងពន្យល់។

## ចម្លើយ

2.ក.ទីផ្សារ គឺជាការរៀបចំឱ្យអ្នកលក់និងអ្នកទិញជួបគ្នាក្នុងគោលបំណងដោះដូរទំនិញ ឬសេវាកម្មទៅវិញទៅមក។

ខ.ទីផ្សារអាមានសកម្មភាពបានលុះត្រាមានៈ

- ការដោះដូរពលកម្មៈពលកម្មជាកម្លាំងចលករសម្រាប់អភិវឌ្ឍសេដ្ឋកិច្ច។ មនុស្សបានលក់ពលកម្មនេះតាមតម្រូវការទីផ្សារហើយទីផ្សារផ្តល់មកមនុស្សវិញនូវតម្លៃតបស្នង(ប្រាក់ខែ ឬប្រាក់ឈ្នួល)។
- ការដោះដូរផលិតផលៈនៅពេលដែលទីផ្សារយកកម្លាំងពលដើម្បីផលិតផលិតផល ហើយដាក់លក់ជូនកម្លាំងពលកម្ម(ទទួលបានថ្លៃទំនិញ)។
- សិទ្ធិជាម្ចាស់កម្មសិទ្ធិនិងសិទ្ធិសហគ្រិនៈទីផ្សារបើកចំហសិទ្ធិជាម្ចាស់កម្មសិទ្ធិនិងសិទ្ធិសហគ្រិន។
- ថ្លៃទំនិញនិងសេវាត្រូវបានកំណត់ៈថ្លៃទំនិញត្រូវបានកំណត់ឱ្យមានការទូទាត់ចំណាយលើវត្ថុធាតុដើមមធ្យោបាយផលិតកម្ម និងកម្លាំងពលុកម្ម រួមទាំងការ

ចំណាយផ្សេងទៀត ដូចជា ការបង់ពន្ធការជួលអគារ ឬទីកន្លែង ការវេចខ្ចប់ និងការដឹកជញ្ជូន។

- ការធ្វើអន្តរាគមន៍របស់រដ្ឋក្នុងទីផ្សារៈរដ្ឋមានតួនាទីតិចតួចណាស់ក្នុងការធ្វើអន្តរាគមន៍លើទីផ្សារ។

គ.រដ្ឋមានបានបំពេញមុខងារ៣យ៉ាងគឺ:

- មុខងារធ្វើនិយ័តកម្មៈរដ្ឋជាអ្នកបង្កើតនិងជំរុញការអនុវត្តច្បាប់នានា ដូចជាច្បាប់កិច្ចសន្យា ច្បាប់កម្មសិទ្ធិ ក្រមសីលធម៌សេដ្ឋកិច្ច ច្បាប់ពន្ធ ច្បាប់ចរាចរណ៍ ច្បាប់បរិយាបណ្ណជាដើម ដើម្បីផលប្រយោជន៍អតិថិជន សហគ្រិនអាជីវកម្ម និងសង្គមជាតិ។
- មុខងារលើកទឹកចិត្តៈរដ្ឋជាអ្នកធ្វើឱ្យមានប្រសិទ្ធិភាពក្នុងការរក្សាស្ថេរភាពសេដ្ឋកិច្ចនិងការអភិវឌ្ឍសេដ្ឋកិច្ច ដើម្បីកាត់បន្ថយនូវវិបត្តិផ្សេងៗដូចជាការបាត់បង់ការងារ អតិផរណាជាដើម។
- មុខងារត្រួតពិនិត្យៈរដ្ឋជាអ្នកទប់ស្កាត់ការប៉ះពាល់ទៅលើបរិស្ថាន មានដូចជាបង្ហូរកាកសំណល់ដែលមានជាតិគីមីឬកាកសំណល់ផ្សេងៗទៅក្នុងទឹក។ផលិត

និងលក់សារជាតិដែលបង្កឱ្យមានគ្រោះថ្នាក់ដល់អាយុជីវិតនិងលក់ថ្នាំញៀនការផលិតចំណីអាហារដែលមានជាតិគីមីឬការផលិតទំនិញដែលមានជាតិវិទ្យុសកម្មជាដើម។

ឃ.នៅទីផ្សារ ថ្លៃទំនិញឬសេវាកម្មត្រូវបានកំណត់ដោយអ្នកលក់និងអ្នកទិញ។ដើម្បីឱ្យមានការដោះដូរអ្នកលក់និងអ្នកទិញត្រូវការថ្លៃទំនិញ ឬថ្លៃសេវាកម្មមានលក្ខណៈសមហេតុផល។

ង.ថ្លៃទំនិញស្ថិតនៅក្រោមឥទ្ធិពល២យ៉ាងគឺ:

- ថ្លៃនិងឥទ្ធិពលចំណូល:ដោយចំណូលមានព្រំដែនអ្នកទិញបានទិញទំនិញតិចជាងមុននៅពេលដែលថ្លៃទំនិញមានការកើនឡើង។ម្យ៉ាងទៀតតម្រូវការអ្នកទិញអាចមានការប្រែប្រួលទៅតាមចំណូលជាក់ស្តែងរបស់គេ។
- ថ្លៃនិងឥទ្ធិពលជំនួស:ប្រសិនបើទំនិញមួយឡើងថ្លៃអ្នកទិញអាចបន្ថយការទិញទំនិញនោះហើយទៅទិញទំនិញទៀតដែលគេចាត់ទុកថាមានឥទ្ធិពលជំនួស។

# មេរៀនទី៨

## របនាសម្ព័ន្ធទីផ្សារ

?សំណួរ

2. ចូរអ្នកពិភាក្សាជាមួយដៃគូឬជាក្រុមដើម្បីដោះស្រាយនូវសំណួរខាងក្រោមនេះ

ក. ដូចម្តេចហៅថា របនាសម្ព័ន្ធទីផ្សារ ? តើរចនាសម្ព័ន្ធទីផ្សារមានអ្វីខ្លះ?

ខ. ដូចម្តេចហៅថាការប្រកួតប្រជែងពេញលេញ ? ចូរពន្យល់។

គ. ដូចម្តេចហៅថាការប្រកួតប្រជែងមិនពេញលេញ? ចូរពន្យល់។

ឃ.តើរបបលក់ផ្តាច់មុខ ជារចនាសម្ព័ន្ធទីផ្សារឬទេ? ហេតុអ្វី?

ង. តើអំណាចនៃរបបលក់ផ្តាច់មុខមានប្រភពពីណា?

ច.តើរបបលក់ផ្តាច់មុខមានគុណវិបត្តិអ្វីខ្លះ ? ចូរពន្យល់។

# ចម្លើយ

2.ក . រចនាសម្ព័ន្ធទីផ្សារ គឺជាសកម្មភាពសេដ្ឋកិច្ចដែលទ្រទ្រង់របបទីផ្សារសេរី ដែលរួមមានការប្រកួតប្រជែងពេញលេញនិងការប្រកួតប្រជែងមិនពេញលេញ។

ខ. ការប្រកួតប្រជែងក្នុងសកម្មភាពសេដ្ឋកិច្ច គឺជាការប្រឹងប្រែងបំពេញតម្រូវការរបស់អតិថិជនឱ្យបានច្រើនបំផុតនៅលើទីផ្សារ ហើយរក្សាបាននិរន្តរភាពនិងកិត្តិនាមនៃអាជីវកម្មរបស់ខ្លួន។ការប្រកួតប្រជែងពេញលេញមានលក្ខណៈដូចខាងក្រោម:

✓ការប្រៀបធៀបផលិតផលក្នុងប្រភេទតែមួយ

✓កត្តាផលិតកម្ម

✓មានអ្នកលក់និងអ្នកទិញច្រើន

✓សេរីភាពក្នុងការចូលទីផ្សារ

គ. ការប្រកួតប្រជែងមិនពេញលេញ:ជារចនាសម្ព័ន្ធផ្សារដែលគ្មានការប្រកួតប្រជែងពេញលេញ។ការប្រកួតប្រជែងមិនពេញលេញមានកម្រិតផ្សេងៗដូចជា:

✓របបរួមគ្នាផ្តាច់មុខ

✓ របបផ្តាច់មុខពីរនាក់

ឃ.របបលក់ផ្តាច់មុខ មិនមែនជារចនាសម្ព័ន្ធទីផ្សារទេ ពីព្រោះរបបលក់ផ្តាច់មុខ គឺសិទ្ធិពិសេសរបស់បុគ្គល សហគ្រាសឬស្ថាប័នសាធារណៈក្នុងការផលិតការ លក់ ឬធ្វើអាជីវកម្មទៅលើទំនិញ ឬសេវាណាមួយ។

ង.អំណាចនៃរបបលក់ផ្តាច់មុខមានប្រភពពី:

✓ មានគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការ ផ្តល់សិទ្ធិលក់ផ្តាច់មុខក្នុងទីផ្សារ។

✓ មានការគ្រប់គ្រងកត្តាផលិតកម្ម ឬវត្ថុធាតុដើមផ្តាច់ មុខតែឯង។

✓ មានឧត្តមភាពសេដ្ឋកិច្ច ពោលគឺមានមូលធនច្រើន ដាច់គេសម្រាប់ធ្វើការដាក់ទុនវិនិយោគ។

✓ មានសិទ្ធិស្របច្បាប់ ដូចជាប័ណ្ណប៉ាតង់ សិទ្ធិចម្លង ឬការទិញសិទ្ធិផ្តាច់មុខពីផលិតករដទៃជាដើម។

ច. របបលក់ផ្តាច់មុខមានគុណវិបត្តិដូចជា:

➢ លទ្ធភាពមានឥទ្ធិពលលើថ្លៃផលិតផលៈដោយសារ គ្មានអ្នកលក់ផ្សេងទៀតអាចចូលក្នុងទីផ្សារបាន អ្នក

លក់ផ្តាច់មុខអាចកំណត់ឱ្យបរិមាណផលិតផលរបស់ខ្លួនទាបជាបរិមាណតម្រូវការរបស់អតិថិជន។ជាហេតុធ្វើឲ្យទំនិញឡើងថ្លៃ។

➢ លទ្ធភាពមានឥទ្ធិពលលើតម្រូវការៈនៅពេលដែលទំនិញឡើងថ្លៃ អ្នកប្រើប្រាស់តែងកាត់បន្ថយតម្រូវការរបស់ខ្លួន ហើយនៅពេលដែលទំនិញចុះថ្លៃ អ្នកប្រើប្រាស់តែងបង្កើនតម្រូវការរបស់ខ្លួន។ក្នុងករណីមានការលក់ផ្តាច់មុខ តម្រូវការរបស់អ្នកប្រើប្រាស់មិនមានកំណើនទេ ហើយគេត្រូវទូទាត់ថ្លៃទំនិញខ្ពស់ជាងថ្លៃទំនិញដូចគ្នាក្នុងទីផ្សារប្រកួតប្រជែង។

➢ ការប៉ះពាល់ដល់វិស័យសេដ្ឋកិច្ចទាំងមូលៈការឡើងថ្លៃទំនិញណាមួយតាមរយៈការលក់ផ្តាច់មុខអាចធ្វើឱ្យប៉ះពាល់ដល់វិស័យសេដ្ឋកិច្ចទាំងមូល។

# មេរៀនទី៦

## គ្រឹះសេដ្ឋកិច្ចទីផ្សារនៅកម្ពុជា

?សំណួរ

2. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬជាក្រុមដើម្បីដោះស្រាយនូវសំណួរខាងក្រោមនេះ

ក. តើយន្តការនិងរចនាសម្ព័ន្ធសេដ្ឋកិច្ចជាអ្វី?

ខ. អ្វីទៅជាការរៀបចំយន្តការសម្រាប់រចនាសម្ព័ន្ធសេដ្ឋកិច្ចថ្មី?

គ. តើរដ្ឋត្រូវមានភារកិច្ចរៀបចំអ្វីខ្លះក្នុងដំណាក់កាលដំបូងនៃការកសាងមូលដ្ឋានគ្រឹះនៃរចនាសម្ព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី?

ឃ.តើហេដ្ឋារចនាសម្ព័ន្ធមានតួនាទីអ្វីក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី?

ង. តើអ្វីជាកិច្ចការចំពោះមុខ ក្នុងការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ?ចូរពន្យល់។

ច. តើប្រទេសកម្ពុជាបច្ចុប្បន្ននេះ នឹងអាចសម្រេចបាន លើការងារកែទម្រង់ប្រព័ន្ធសេដ្ឋកិច្ចដូចបណ្ដាប្រទេស មួយចំនួននៅអឺរ៉ុបនិងសហរដ្ឋអាមេរិចដែរឬទេ? ហេតុអ្វី?

---

<u>ចម្លើយ</u>

2. ក.យន្តការនិងរចនាសម្ព័ន្ធសេដ្ឋកិច្ច គឺជាបាតុភូតសេដ្ឋកិច្ច ប៉ុន្តែវាជាផ្នែកមួយនៃបាតុភូតវប្បធម៌ ប្រពៃណី សីលធម៌ និងចិត្តសាស្ត្រ។

ខ. ការរៀបចំយន្តការសម្រាប់រចនាសម្ព័ន្ធសេដ្ឋកិច្ចថ្មី គឺជាការកែប្រែដែលប៉ះពាល់ដល់គ្រប់ផ្នែកនៃជីវភាពសង្គម ទាំងសេដ្ឋកិច្ច នយោបាយ ច្បាប់ វប្បធម៌ សីលធម៌ ចិត្តសាស្ត្រ។

គ. ក្នុងដំណាក់ដំបូងនៃការកសាងមូលដ្ឋានគ្រឹះនៃរចនាសម្ព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី រដ្ឋត្រូវមានភារកិច្ចរៀបចំបរិបទមួយ សម្រាប់ឱ្យប្រព័ន្ធសេដ្ឋកិច្ចថ្មីមានដំណើរការនិងរីកលូតលាស់បាន។

ការងារនេះមានពាក់ព័ន្ធនឹង:

✓ការកែលំអប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈនិងពង្រឹងអភិបាលកិច្ចល្អ។

✓ការកសាងធនធានមនុស្សនៅក្នុងប្រទេសតាមការរីកចម្រើននៃបច្ចេកវិទ្យាថ្មី។

✓បញ្ហាស្ថេរភាពរូបនីយកម្មស្ថានភាពសេដ្ឋកិច្ចនិងនយោបាយ។

✓ការរៀបចំនិងកែលំអប្រព័ន្ធវិនិយោគសាធារណៈជាដើម ដើម្បីឱ្យសមស្របតាមយន្តការទីផ្សារសេរី។

✓ការពង្រឹងប្រព័ន្ធគ្រប់គ្រងនិងការពារធនធានធម្មជាតិ

✓ការកែលំអប្រព័ន្ធសេដ្ឋកិច្ចនិងពាណិជ្ជកម្ម(តាមសមាគមពាណិជ្ជកម្មពិភពលោកWTO)។

ឃ.ក្នុងប្រព័ន្ធសេដ្ឋកិច្ចសេរីហេដ្ឋារចនាសម្ព័ន្ធមានតួនាទីជាគ្រោងឆ្អឹង ជាសរសៃឈាមនិងជាសាច់ដុំនៃប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី។ វាជាមូលដ្ឋានបង្អែកនៃប្រព័ន្ធសេដ្ឋកិច្ចនិងជាបណ្តាញតភ្ជាប់បណ្តាកត្តាផលិតកម្មរបស់ភ្នាក់ងារសេដ្ឋកិច្ចនានា ដើម្បីធានាបាននូវសមាហរណកម្មផ្ទៃក្នុងនៃប្រព័ន្ធសេដ្ឋកិច្ចនិងជាកម្លាំងចល

ករជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិផង។

ង. ក្នុងការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធ កិច្ចការចំពោះមុខគឺត្រូវរៀបចំនិងបណ្ដុះបណ្ដាលធនធានមនុស្សឱ្យបានច្រើន និងមានសមត្ថភាពស្របតាមការីកចំរើននៃបច្ចេកវិទ្យាថ្មីៗដើម្បីឱ្យគេចេះគ្រប់គ្រងនិងប្រើប្រាស់ធនធានធម្មជាតិឱ្យចំទិស និងមានប្រសិទ្ធិភាព។

ច.ប្រទេសកម្ពុជានឹងទទួលជោគជ័យលើការងារកែទម្រង់ប្រព័ន្ធសេដ្ឋកិច្ចដូចបណ្ដាប្រទេសមួយចំនួននៅអឺរ៉ុប និងនៅសហរដ្ឋអាមេរិចដែរ ក្នុងករណីរដ្ឋដើរតួយ៉ាងសំខាន់ក្នុងការរៀបចំគ្រឹះសេដ្ឋកិច្ចទីផ្សារពីព្រោះ

✓ភាពខ្ទេចខ្ទាំនិងក្រខ្សត់នៃសេដ្ឋកិច្ចជាតិ ទាមទារឱ្យមានការស្ដារឡើងវិញគ្រប់ជ្រុងជ្រោយនិងគ្រប់វិស័យពិសេសការស្ដារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធជារូបវ័ន្តព្រមទាំងការបណ្ដុះបណ្ដាលធនធានមនុស្ស។

✓ចរិតឯកវប្បកម្មនិងភាពអន់ថយនៃទំនាក់ទំនងទីផ្សារនៅក្នុងប្រទេសក៏ទាមទារឱ្យរដ្ឋរៀបចំនឹងធ្វើ

អន្តរាគមន៍ក្នុងការពង្រឹងសេដ្ឋកិច្ចដើម្បីធានានូវប្រសិទ្ធភាពក្នុងការគ្រប់គ្រងនិងសមាហរណកម្មផ្ទៃក្នុងនៃប្រព័ន្ធសេដ្ឋ កិច្ចជាតិ។

✓ភាពអន់ថយនៃរបៀបផលិតពឹងផ្អែកលើធម្មជាតិក្នុងផ្នែកកសិកម្មនិងភាពប្រែប្រួលនៃលក្ខខណ្ឌធម្មជាតិដែលមានប្រទេសទាមទារឱ្យរដ្ឋដើរតួនាទីដឹកនាំយ៉ាងសំខាន់ក្នុងជីវិតសេដ្ឋកិច្ចជាតិ។

✓ផ្នែកឯកជននៅខ្សោយវាទាមទារឱ្យរដ្ឋធ្វើការកំណត់ទិសនិងមានផែនការមេរយៈពេលយូរសម្រាប់ធ្វើការអភិវឌ្ឍផ្នែកឯកជនមានការបង្កើតច្បាប់ការពារប្រយោជន៍ឯកជនក្នុងការលើកទឹកចិត្តដល់សហគ្រិនក្នុងការគ្រប់គ្រងសកម្មភាពសេដ្ឋកិច្ចនិងទីផ្សារ។

✓ភាពមិនទាន់សុក្រឹតនៃបរិស្ថានដែលជួយដល់ការប្រព្រឹត្តនិងការីកលូតលាស់នៃយន្តការសេដ្ឋកិច្ចទីផ្សារសេរីទាមទារឱ្យរដ្ឋយកចិត្តទុកដាក់កសាងឡើងវិញនិងកែលំអក្នុងផ្នែកជាច្រើនទាំងផ្នែក

រចនាសម្ព័ន្ធនៃ ស្ថាប័នរដ្ឋបាល ទាំងផ្នែកសេវាកម្ម និងទាំងផ្នែកទ្រ ទ្រង់នានា។

✓ផ្នែកឯកជននិងផ្នែករដ្ឋពុំទាន់មានទំនាក់ទំនងជាគូសន្ធនានឹងគ្នានៅឡើយ។ ញ្ញានេះទាមទារឱ្យរដ្ឋកសាងប្រព័ន្ធយន្តការការងារមួយដែលមានរចនាសម្ព័ន្ធប្រទាក់ក្រឡាគ្នារវាងរដ្ឋនិងឯកជន។

# មេរៀនទី៧

## កម្មសិទ្ធិឯកជននិងសេរីភាពក្នុងការជ្រើសរើស

?សំណួរ

2. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬជាក្រុមដើម្បីដោះស្រាយនូវសំណួរខាងក្រោមនេះ

ក. កម្មសិទ្ធិឯកជនជាអ្វី?

ខ. តើមានគោលការណ៍អ្វីខ្លះ ក្នុងការប្រើប្រាស់កម្មសិទ្ធិឯកជន?

គ. តើការផ្តល់សេរីភាពនិងសិទ្ធិក្នុងការជ្រើសរើសដល់សហគ្រិនមានសារៈសំខាន់ដូចម្តេចខ្លះ?

ឃ.តើសេរីភាពក្នុងការជ្រើសរើសរបស់កម្លាំងពលកម្មនិងអ្នកប្រើប្រាស់មានសារៈសំខាន់ដូចម្តេចខ្លះ?

ង. តើការប្រកួតប្រជែងជាអ្វី?

ច. តើការប្រកួតប្រជែងមានតួនាទីអ្វីខ្លះ?

## ចម្លើយ

2. ក.កម្មសិទ្ធិឯកជន ក្នុងន័យសេដ្ឋកិច្ចមានន័យថា ការយកមកធ្វើជារបស់ខ្លួននូវមធ្យោបាយផលិតកម្មនិងទ្រព្យសម្ភារៈដែលផលិតបាន។

ខ. ក្នុងការប្រើប្រាស់កម្មសិទ្ធិឯកជន មានគោលការណ៍ដូចជា:

- ព្រំដែនសេរីភាពរបស់ម្ចាស់កម្មសិទ្ធិ
- សេរីភាពរបស់ម្ចាស់កម្មសិទ្ធិ
- ប្រសិទ្ធភាពក្នុងការហាមឃាត់

គ. ការផ្តល់សេរីភាពនិងសិទ្ធិក្នុងការជ្រើសរើសដល់សហគ្រិនមានសារៈសំខាន់ដូចជា:

- សហគ្រិន មានសិទ្ធិសម្រេចចិត្តចូលធ្វើអាជីវកម្មក្នុងវិស័យណាមួយ ដែលជាផ្នែករបស់សេដ្ឋកិច្ចជាតិ ឬចាកចេញពីអាជីវកម្មនោះ។
- សហគ្រិនអាចទិញដូរដោយសេរីនូវធនធានសេដ្ឋកិច្ចសម្រាប់ចាត់ចែងនិងប្រើប្រាស់ក្នុងដំណើរការផលិតទំនិញ ឬសេវាក្នុងអាជីវកម្មរបស់ខ្លួនក្នុង

នាមជាម្ចាស់កម្មសិទ្ធិ។

- សហគ្រិន មានសិទ្ធិលក់ដូរទំនិញទាំងនេះក្នុងទីផ្សារតាមតម្លៃនិងបរិមាណផលិតផល ឬសេវា។

ឃ.សេរីភាពក្នុងការជ្រើសរើសរបស់កម្លាំងពលកម្មនិងអ្នកប្រើប្រាស់មានសារៈសំខាន់ដូចជាៈ

- ម្ចាស់កម្មសិទ្ធិលើធនធានធម្មជាតិនិងទំនិញវិនិយោគអាចប្រើប្រាស់ជួល ឬលក់ធនធានទាំងនោះ ទៅតាមការយល់ឃើញរបស់ខ្លួន។
- អ្នកប្រើប្រាស់មានសេរីភាពក្នុងការប្រើប្រាស់ក្របខណ្ឌថវិកាឬបំណុលដែលខ្លួនមាន ដើម្បីទិញទំនិញឬសេវាកម្មក្នុងតម្លៃនិងបរិមាណដែលត្រូវនឹង បំណងរបស់ខ្លួន។
- អ្នកមានកម្លាំងពលកម្ម អាចព្រមព្រៀងឬមិនព្រមព្រៀងលក់កម្លាំងពលកម្មរបស់ខ្លួន ដោយផ្អែកលើកម្រិតសមត្ថភាពរបស់ខ្លួនទៅតាមការសម្រេចចិត្តផ្ទាល់ខ្លួន។

ង. ការប្រកួតប្រជែងជាការប្រជែងគ្នាក្នុងការស្វែងរកទី

ផ្សារ វត្ថុធាតុដើម ឱកាសសម្រាប់ការបណ្តាក់ទុនឬប្រាក់ចំណេញឱ្យបានច្រើនអតិបរមា។

ច. ការប្រកួតប្រជែងមានតួនាទីដូចជា:

✓ទប់ស្កាត់ការដំឡើងថ្លៃទំនិញឬសេវា: ជាទូទៅ នៅពេលដែលមានអ្នកលក់និងអ្នកទិញច្រើននៅក្នុងទីផ្សារមិនអាចមានអ្នកលក់ឬអ្នកទិញណាម្នាក់អាចប៉ាន់ស្មានបានត្រឹមត្រូវអំពីបរិមាណតម្រូវការឬការផ្គត់ផ្គង់លើមុខទំនិញណាមួយបានឡើយ ជាពិសេស គេមិនអាចមានឥទ្ធិពលក្នុងការកំណត់ ថ្លៃទំនិញបានទេ។

✓រក្សានិន្នាការភាពសេដ្ឋកិច្ចទីផ្សារដ៏យូរអង្វែង:តាមរយ: ការប្រើប្រាស់សេរីភាពក្នុងការប្រកួតប្រជែងផលិតករអាចចូលនិងចេញនៅក្នុងអាជីវកម្មឬក្នុងវិស័យណាមួយនៃសេដ្ឋកិច្ចជាតិបានតាមចំណង់។ ចំណុចនេះ មានសារប្រយោជន៍ក្នុងការផ្តល់លទ្ធភាពសម្រប សម្រួលការផ្គត់ផ្គង់សេចក្តីត្រូវការរបស់អតិថិជន ការលើកកម្ពស់ការប្រើប្រាស់បច្ចេក

វិទ្យាថ្មីនិងការ បង្កើនធនធានសេដ្ឋកិច្ច។

✓ត្រួតពិនិត្យថ្លៃៈក្នុងសេដ្ឋកិច្ចទីផ្សារ ការប្រកួតប្រជែង មានតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យថ្លៃ។ជាទូទៅក្រឹត្យក្រមនៃការផ្គត់ផ្គង់និងតម្រូវការជាភ្នាក់ងារ ផ្តល់ព័ត៌មានដល់ផលិតករអំពីតម្រូវការរបស់អតិថិជន។ក៏ប៉ុន្តែការប្រកួតប្រជែងបង្ខំឱ្យសហគ្រិនបំពេញ តម្រូវការរបស់អតិថិជន ពីព្រោះថាទំនិញមានតម្រូវ ការខ្ពស់ ថ្លៃក៏មានកំណើនកើនឡើងដែរ។ផលិតផលមានការកើនឡើង បន្ទាប់មកថ្លៃក៏ធ្លាក់ចុះ។

✓លើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាទំនើបៈ ការប្រើប្រាស់បច្ចេកវិទ្យាអាចឱ្យផលិតករកាត់បន្ថយបានការចំណាយផលិតកម្ម ហើយធ្វើឱ្យគេមានប្រៀបក្នុងប្រកួតប្រជែង។ បន្ថែមលើនេះ គេអាចលក់ទំនិញក្នុងតម្លៃទាប ហើយអាចកាត់បន្ថយការ លំបាកបានយ៉ាងច្រើន។

✓ធ្វើឱ្យស្របគ្នារវាងផលប្រយោជន៍របស់បុគ្គលនិង

ផលប្រយោជន៍សង្គមៈ ភ្នាក់ងារសេដ្ឋកិច្ចនីមួយៗខិតខំបង្កើនចំណូលឱ្យបានច្រើនជាអតិបរិមាតាមរយៈការផលិតទំនិញនិងសេវា។ក្នុងការងារនេះផលិតករប្រើវិធានការចាត់ចែងប្រើប្រាស់ធនធានដែលមានដោយកម្រប្រកបដោយប្រសិទ្ធភាព ក្នុងការផលិតទំនិញឱ្យមានគុណភាពនិងមានបរិមាណសមស្របតាមតម្រូវការរបស់អ្នកប្រើប្រាស់។

# មេរៀនទី៨

## ផលិតផលជាតិ

?សំណួរ

2. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬជាក្រុមដើម្បីដោះស្រាយនូវសំណួរខាងក្រោម

ក. ដូចម្ដេចហៅថាផលិតផលក្នុងស្រុកសរុប?

ខ. ដូចម្ដេចហៅថាផលិតផលជាតិ?

គ. ដូចម្ដេចហៅថាផលិតផលជាតិសរុប?

ឃ.ផលិតផលជាតិសរុបមានទំនាក់ទំនងយ៉ាងណាជាមួយនឹងសុខុមាលភាពប្រជាពលរដ្ឋ?

ង.រវាងផលិតក្នុងស្រុកសរុបនិងផលិតផលជាតិសរុបតើមួយណាជាអ្នកបង្ហាញសក្ដានុពលនៃផលិតកម្មរបស់ជាតិមួយ? ហេតុអ្វី?

## ចម្លើយ

2. ក.ផលិតផលក្នុងស្រុកសរុប គឺជាតម្លៃសរុបនៃទំនិញ និងសេវាកម្មដែលសម្រេចបានដោយប្រើប្រាស់កត្តាផលិតកម្មដែលជាកម្មសិទ្ធិក្នុងស្រុកក្នុងអំឡុងពេលមួយមានកំណត់។

ខ. ផលិតផលជាតិ(NP)គឺជាតម្លៃសរុបនៃទំនិញនិងសេវាកម្មទាំងអស់ទាំងក្នុងស្រុក ទាំងជាអំណោយពីបរទេសដែលមាននៅក្នុងសេដ្ឋកិច្ចជាតិមួយក្នុងពេលជាក់លាក់មួយ។

គ. ផលិតផលជាតិសរុប(GNP)គឺជាការបូកសរុបការចំណាយទាំងអស់របស់រដ្ឋាភិបាល រួមនឹងទុនវិនិយោគឯកជនដែលមានប្រភពនៅក្នុងស្រុកនិងក្រៅស្រុក។

ឃ.ផលិតផលជាតិសរុបមានទំនាក់ទំនងយ៉ាងខ្លាំងជាមួយនឹងសុខុមាលភាពពីព្រោះផលិតផលជាតិសរុបគឺជាតម្លៃសរុបដែលបានពីការវាស់កម្រិតផលិតកម្មសេដ្ឋកិច្ច។វាមិនត្រឹមតែបង្ហាញនូវកម្រិតគុណភាពនៃសុខុមាលភាពសង្គមប៉ុណ្ណោះទេតែវាបង្ហាញនូវសុខុ

មាលភាពផ្លូវចិត្តរបស់ប្រជាពលរដ្ឋនៅក្នុងសង្គមផង ដែរ។ សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋគឺមានជីវភាព រស់នៅសមរម្យហូបចុកគ្រប់គ្រាន់មានរបស់របរប្រើ ប្រាស់គ្រប់គ្រាន់មានជម្រកនិងមានការលំហែកាយ ក្នុងការថែទាំសុខភាព។ការបំពេញសេចក្តីត្រូវការ របស់ប្រជាពលរដ្ឋដោយការបង្កើនផលិតផលទំនិញ និងសេវាកម្មតាមតម្រូវការ នាំមកនូវការលូតលាស់ នៃសេដ្ឋកិច្ចជាតិនិងការកាត់បន្ថយវិបត្តិផ្សេងៗនៅក្នុង សង្គម។

ង. រវាងផលិតក្នុងស្រុកសរុបនិងផលិតផលជាតិសរុប ផលិតផលជាតិសរុបជាអ្នកបង្ហាញសក្តានុពលនៃ ផលិតកម្មរបស់ជាតិមួយ ពីព្រោះ ផលិតផលជាតិសរុប គឺជា ការបូកសរុបការចំណាយរបស់រដ្ឋាភិបាល រួមនឹងទុនវិនិយោគឯកជនដែលមានប្រភពនៅក្នុង ស្រុកនិងក្រៅស្រុក។កម្រិតកើនឡើងឬថយចុះនៃ ផលិតផលជាតិសរុបឆ្លុះបញ្ចាំងឱ្យឃើញពីកម្រិតកើន ឡើង ឬថយចុះនៃសុខុមាលភាពប្រជាពលរដ្ឋ។

មេរៀនទី៩

# ផលិតកម្ម

?សំណួរ

2.ចូរអ្នកពិភាក្សាជាមួយដៃគូឬជាក្រុមដើម្បីដោះស្រាយនូវសំណួរខាងក្រោម

ក. ដូចម្តេចហៅថា ផលិតកម្មមិនទាន់សម្រេច?

ខ. ដូចម្តេចហៅថា ផលិតកម្មទំនិញ?

គ. ដូចម្តេចហៅថា ផលិតកម្មទំនិញសាមញ្ញ?

ឃ. ដូចម្តេចហៅថា ផលិតកម្មមេកានិច?

ង. ដូចម្តេចហៅថាផលិតកម្មសរុប?

ច. ដូចម្តេចហៅថា ផលិតកម្មសុទ្ធ?

# ចម្លើយ

ក.ផលិតកម្មមិនទាន់សម្រេចជាផលិតផលដែលស្ថិតនៅក្នុងដំណាក់កាលជាអន្តរការីនៃដំណើរការផលិតកម្មមុននឹងធ្វើពាណិជ្ជកម្ម។

ខ.ផលិតកម្មទំនិញជាផលិតកម្មទ្រព្យសម្ភារៈសម្រាប់ប្តូរផ្តោះតាមរយៈការទិញនិងការលក់។

គ.ផលិតកម្មទំនិញសាមញ្ញជាផលិតកម្មនៃទំនិញរបស់របរសម្រាប់ប្តូរផ្តោះតាមរយៈការលក់និងការទិញហើយត្រូវបានបង្កើតឡើងដោយឈរលើកម្មសិទ្ធិឯកជនរបស់ពលករតូចៗនិងពលកម្មផ្ទាល់ខ្លួន។

ឃ.ផលិតកម្មមេកានិចជាការប្រើប្រាស់ឧបករណ៍ម៉ាស៊ីន ដូចជា ម៉ូទ័រ ម៉ាស៊ីនបញ្ជូន និងម៉ាស៊ីនប្រតិបត្តិការដែលជាមធ្យោបាយដ៏មានអានុភាពដែលអាចផ្តល់ការសន្សំសំចៃនិងជួយសម្រួលការងារ។

ង. ផលិតកម្មសរុបជាសន្ទស្សន៍ស្តែងឡើងក្រោមទម្រង់ជារូបិយវត្ថុដែលបង្ហាញនូវទំហំផលិតកម្មរបស់សហគ្រាសក្រុមផលិតកម្មណាមួយផ្នែកណាមួយ ឬសំណុំ

នៃសេដ្ឋកិច្ចជាតិទាំងមូល។

ច. ផលិតកម្មសុទ្ធជាសន្ទស្សន៍សេដ្ឋកិច្ច បង្ហាញនូវតម្លៃបង្កើតថ្មី ដែលជាលទ្ធផលសំខាន់បំផុតនៃសកម្មភាពរបស់សហគ្រាស ក្រុមប្រមូលផ្តុំនានា និងវិស័យនានានៃផលិតកម្មសម្ភារៈនៅក្នុងប្រទេសមួយ(ច្រើនប្រើនៅប្រទេសសង្គមនិយម)។

---

# មេរៀនទី១០

## ព្រំដែនសមត្ថភាពផលិតកម្ម

### ?សំណួរ

២. ចូរអ្នកពិភាក្សាជាមួយដៃគូឬជាក្រុមដើម្បីដោះស្រាយនូវសំណួរខាងក្រោម

ក. ដូចម្ដេចហៅថាសមត្ថភាព និងព្រំដែនសមត្ថភាពផលិតកម្ម? ចូរផ្ដល់ឧទាហរណ៍។

ខ. តើសមត្ថភាពផលិតកម្មមានប៉ុន្មានប្រភេទ?អ្វីខ្លះ?

គ. តើអ្វីដែលជាចំណោទបញ្ហាសំខាន់ចំពោះអ្នកសេដ្ឋកិច្ចចំពោះការងារផលិតកម្ម?

### ចម្លើយ

2. ក.សមត្ថភាព និងព្រំដែលសមត្ថភាពផលិតកម្ម សំដៅលើលទ្ធភាពរបស់ប្រទេសជាតិ ក្នុងការបង្កើតផលិតផលដើម្បីផ្គត់ផ្គង់សេចក្ដីត្រូវការរបស់ខ្លួន។

ខ. សមត្ថភាពផលិតកម្មមាន៣ប្រភេទគឺ:

- ✓ទុនវិនិយោគដែលប្រទេសនីមួយៗមាន
- ✓ធនធានធម្មជាតិ
- ✓ធនធានមនុស្ស

គ. ចំណោទបញ្ហាសំខាន់ចំពោះអ្នកសេដ្ឋកិច្ចចំពោះការងារផលិតកម្មមានដូចជា:

- ✓ផលិតយ៉ាងដូចម្ដេច?
- ✓ផលិតប៉ុន្មាន?
- ✓ផលិតសម្រាប់អ្នកណា?
- ✓តើត្រូវផលិតអ្វី?
- ✓តើត្រូវជ្រើសរើសឱ្យសមត្ថភាពផលិតកម្មស្ថិតនៅក្រោម ឬស្ថិតនៅលើ ឬស្ថិតនៅក្រៅខ្សែព្រំដែនសមត្ថភាពផលិតកម្ម។

---

# ?សំណួរបញ្ចប់ជំពូកទី១

I.ចូរគូសញ្ញា✓ក្នុងប្រអប់មុខចម្លើយណាដែលត្រឹមត្រូវ

1. សេដ្ឋកិច្ច គឺជាការសាកសួរថា

☐ក.តើទំនិញអ្វីដែលគេត្រូវផលិត?

☐ខ.តើផលិតឡើងយ៉ាងដូចម្តេច?

☐គ.តើផលិតឡើងសម្រាប់អ្នកណា?

☐ឃ.តើផលិតនៅពេលណា?

2 .មុខទំនិញដែលលក់បានច្រើន ជាមុខទំនិញដែល

☐ក.មានតម្រូវការច្រើន

☐ខ.ប្រើប្រាស់បានយូរ

☐គ.ពិបាករក

☐ឃ.មានគុណភាពខ្ពស់។

3.ក្នុងការដោះដូរ ថ្លៃស្ថិតក្រោម:

☐ក.ឥទ្ធិពលចំណូល

☐ខ.ឥទ្ធិពលជំនួស

☐គ.ឥទ្ធិពលចំណាយ

☐ឃ.ឥទ្ធិពលតម្រូវការ។

II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

វិទ្យាសាស្ត្រសេដ្ឋកិច្ច ជាវិទ្យាសាស្ត្រស្រាវជ្រាវរក ......................បញ្ហាប្រើប្រាស់ធនធានសេដ្ឋកិច្ច ឬ......... ...........ដែលយើងមានដោយកម្រនិងគ្រប់គ្រងផលិតកម្ម ទាំងអស់ឱ្យចំទីកន្លែងពេលវេលា និងប្រកបដោយ ចភាពសក្តិសិទ្ធិ ដើម្បីបំពេញឱ្យបាននូវតម្រូវការរបស់ សង្គមមនុស្ស។

III. ចូរឆ្លើយសំណួរខាងក្រោម

1. ហេតុអ្វីបានជាគេថា ការបែងចែកទំនិញក្នុងសេដ្ឋកិច្ចទីផ្សារ ពុំមានគោលការណ៍សីលធម៌?
2. មូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចផលិតកម្មមានអ្វីខ្លះ? ចូររៀបរាប់។
3. តើមតិដែលគាំទ្រសេដ្ឋកិច្ចបញ្ញាមានទឡ្ហីករណ៍ដូចម្តេចខ្លះ?
4. នៅទីផ្សារ តើថ្លៃទំនិញ ឬថ្លៃសេវាកម្មត្រូវបានកំណត់ឡើងដោយវិធីណា?ចូរពន្យល់។
5. រវាងផលិតផលក្នុងស្រុបសរុបនិងផលិតផលជាតិ

សរុបតើមួយណាជាអ្នកបង្ហាញសក្តានុពលនៃផលិតកម្មរបស់ជាតិ?ហេតុអ្វី?

6. តើសមត្ថភាពផលិតកម្មជាអ្វី?មានប៉ុន្មានប្រភេទ? ចូរពន្យល់ប្រភេទនីមួយៗ។

## ចម្លើយ

I.ចូរគូសញ្ញា✓ក្នុងប្រអប់មុខចម្លើយណាដែលត្រឹមត្រូវ

1. សេដ្ឋកិច្ច គឺជាការសាកសួរថា

☑ក.តើទំនិញអ្វីដែលគេត្រូវផលិត?

☑ខ.តើផលិតឡើងយ៉ាងដូចម្តេច?

☑គ.តើផលិតឡើងសម្រាប់អ្នកណា?

2 .មុខទំនិញដែលលក់បានច្រើន ជាមុខទំនិញដែល

☑ក.មានតម្រូវការច្រើន

3.ក្នុងការដោះដូរ ថ្លៃស្ថិតក្រោមៈ

☑ឃ.ឥទ្ធិពលតម្រូវការ។

II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

វិទ្យាសាស្ត្រសេដ្ឋកិច្ច ជាវិទ្យាសាស្ត្រស្រាវជ្រាវរក វិធីដោះស្រាយ បញ្ហាប្រើប្រាស់ធនធានសេដ្ឋកិច្ច ឬ ធនធានកម្រ ដែលយើងមានដោយកម្រនិងគ្រប់គ្រងផលិតកម្មទាំងអស់ឱ្យចំទីកន្លែងពេលវេលា និងប្រកបដោយចភាពសក្តិសិទ្ធិ ដើម្បីបំពេញឱ្យបាននូវតម្រូវការរបស់សង្គមមនុស្ស។

III.

1. ការបែងចែកទំនិញក្នុងសេដ្ឋកិច្ចទីផ្សារ ពុំមានគោលការណ៍សីលធម៌ទេពីព្រោះសេដ្ឋកិច្ចទីផ្សារមាន ប្រកួតប្រជែងដោយសេរីដែលអាចធ្វើឲ្យសហគ្រាសមួយធ្វើការបង្អាប់បង្អោនទំនិញរបស់សហគ្រាសមួយដោយសេរី និងធ្វើការលក់ផលិតផលក្នុងតម្លៃថោក ជាហេតុធ្វើបាត់បង់នូវស្តង់ដាររបស់ទំនិញ។
2. មូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចផលិតកម្មមាន៣ប្រភេទគឺ:

✓សេដ្ឋកិច្ចទីផ្សារសេរី

✓សេដ្ឋកិច្ចបញ្ជា ឬសេដ្ឋកិច្ចផែនការ

✓សេដ្ឋកិច្ចចម្រុះ

3. មតិដែលគាំទ្រសេដ្ឋកិច្ចបញ្ញាមានទឡ្ហីករណ៍ដូចជា:

✓បំណងប្រាថ្នារកចំណូល

✓ការរីចម្រើននៃបច្ចេកវិទ្យាទំនើបនាំឱ្យការប្រកួតប្រជែងចុះខ្សោយ

✓វិសមភាពក្នុងការបែងចែកផលិតផល

✓កង្វះការផ្គត់ផ្គង់សេវាសាធារណ:

4. នៅទីផ្សារ ថ្លៃទំនិញឬសេវាកម្មត្រូវបានកំណត់ដោយអ្នកលក់និងអ្នកទិញ។ដើម្បីឱ្យមានការដោះដូរអ្នកលក់ និងអ្នកទិញត្រូវការថ្លៃទំនិញ ឬថ្លៃសេវាកម្មមានលក្ខណ:សមហេតុផល។

5. រវាងផលិតក្នុងស្រុកសរុបនិងផលិតផលជាតិសរុប គឺផលិតផលជាតិសរុបជាអ្នកបង្ហាញសក្តានុពលនៃផលិតកម្មរបស់ជាតិមួយ ពីព្រោះ ផលិតផលជាតិសរុបបានបង្ហាញឲ្យឃើញពីលទ្ធភាពដែលប្រជាជននៃប្រទេសមួយធ្វើការផលិតបានទាំងក្នុង និងក្រៅប្រទេស។

6. សមត្ថភាពផលិតកម្ម សំដៅលើលទ្ធភាពរបស់ប្រទេសជាតិក្នុងការបង្កើតផលិតផលដើម្បីផ្គត់ផ្គង់សេចក្តីត្រូវការរបស់ខ្លួន។

សមត្ថភាពផលិតកម្មមាន៣ប្រភេទគឺ:

✓ទំនិញវិនិយោគដែលប្រទេសនីមួយៗមាន

✓ធនធានធម្មជាតិ

✓ធនធានមនុស្ស

# ជំពូកទី២ រដ្ឋនិងសេដ្ឋកិច្ច

## មេរៀនទី១

## មីក្រូនិងម៉ាក្រូសេដ្ឋកិច្ច

?សំណួរ

2. ចូរប្អូនពិភាក្សាជាមួយដៃគូ ឬជាក្រុម ដើម្បីដោះស្រាយសំណួរដូចខាងក្រោមៈ

ក. តើវិទ្យាសាស្ត្រសេដ្ឋកិច្ចមានទស្សនទានដូចម្តេចខ្លះចំពោះមីក្រូ និងម៉ាក្រូសេដ្ឋកិច្ច?

ខ. ដូចម្តេចដែលហៅថា មីក្រូនិងម៉ាក្រូសេដ្ឋកិច្ច?ចូរអ្នកពន្យល់។

គ. តើ "មីក្រូសេដ្ឋកិច្ច"និង "ម៉ាក្រូសេដ្ឋកិច្ច"មានភាពខុសគ្នាយ៉ាងដូចម្តេចខ្លះ?

ឃ.តារាង "ប្រជាពលរដ្ឋនិងកម្លាំងពលកម្មនៅកម្ពុជា" តើព័ត៌មានអ្វី ដែលអ្នកចាប់អារម្មណ៍ជាងគេ?

ង. ដើម្បីដោះស្រាយបញ្ហាសេដ្ឋកិច្ចមួយ តើគេត្រូវសិក្សា

ទៅលើអ្វី?

---

## ចម្លើយ

2.ក . ចំពោះមីក្រូ និងម៉ាក្រូសេដ្ឋកិច្ចវិទ្យាសាស្ត្រសេដ្ឋកិច្ច គេរកឃើញថា វិទ្យាសាស្ត្រសេដ្ឋកិច្ចមានទំនាក់ទំនងជាឫសគល់យ៉ាងជ្រៅនៅក្នុងទស្សនវិជ្ជាស្តីពីសង្គម។

ខ. - មីក្រូសេដ្ឋកិច្ចជាផ្នែកនៃវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលសិក្សាអំពី ដំណើរការរបស់ផលិតកម្មការប្រើប្រាស់ធនធាន ការកំណត់ថ្លៃលើផលិតផលទំនិញ ចំនួនកម្មករ និងប្រាក់បៀវត្ស ប្រាក់ចំណូលនិងចំណាយរបស់សហគ្រាសមួយ។

- ម៉ាក្រូសេដ្ឋកិច្ចគឺជាការសិក្សាវិភាគរកមូលហេតុនិងផលវិបាកនៃការអភិវឌ្ឍសេដ្ឋកិច្ច។ដូច្នេះគេត្រូវយល់ដឹងអំពី:

✓ទីផ្សារពលកម្មនិងការពាក់ព័ន្ធនឹងជំនាញឯកទេសកម្រិតជំនាញ និងតម្រូវការទីផ្សារ។

✓ចរិតសេដ្ឋកិច្ចជាតិ ការរីកចម្រើននិងការមានវិបត្តិកើតឡើង បរិមាណសរុបថ្លៃទំនិញនិងសេវាកំណើន

សរុបនៃផលិតផល អត្រាអតិផរណា អត្រាគ្មានការងារធ្វើ អត្រាប្តូរប្រាក់ អត្រាការប្រាក់ក្នុងចរន្តសេដ្ឋកិច្ច។

✓ទំនាក់ទំនងរវាងសេដ្ឋកិច្ចជាតិនិងអន្តរជាតិ។ការសិក្សាតាមដានវិបត្តិសេដ្ឋកិច្ចពិភពលោកនិងផលប៉ះពាល់ចំពោះសេដ្ឋកិច្ចកម្ពុជា។

✓បញ្ហាសេដ្ឋកិច្ចចម្បងក្នុងជីវភាពសង្គម មានន័យថាបញ្ហាកែទម្រង់សេដ្ឋកិច្ចដែលឆ្លុះអំពីទំនាក់ទំនងរវាងទីផ្សារទំនិញ ទីផ្សារពលកម្ម និងទីផ្សារហិរញ្ញវត្ថុ។

គ. មីក្រូសេដ្ឋកិច្ចនិង ម៉ាក្រូសេដ្ឋកិច្ច មានភាពខុសគ្នាលើការសិក្សាកម្មវត្ថុសំខាន់៣គឺ:

✓ថ្លៃទំនិញ:មីក្រូសេដ្ឋកិច្ចសិក្សាថ្លៃធៀប (ឧទាហរណ៍ថ្លៃអង្ករធៀបនឹងថ្លៃទំនិញផ្សេងៗទៀត)ចំណែកម៉ាក្រូសេដ្ឋកិច្ចវិញគឺសិក្សាពីការកំណត់ ថ្លៃមធ្យម ដោយរាប់គ្រប់ទំនិញនិងសេវា។

✓ទិដ្ឋភាពសេដ្ឋកិច្ច: មីក្រូសេដ្ឋកិច្ចនិងម៉ាក្រូសេដ្ឋកិច្ច

សិក្សាពីទិដ្ឋភាពសេដ្ឋកិច្ចផ្សេងពីគ្នា។ម៉ាក្រូសេដ្ឋកិច្ចសិក្សានិងវិភាគលើទិដ្ឋភាពរួម ឯមីក្រូសេដ្ឋកិច្ចសិក្សានិងវិភាគលើទិដ្ឋភាពតាមផ្នែក។

✓ប្រាក់ចំណូលៈក្នុងការសិក្សាមីក្រូសេដ្ឋកិច្ច គេសន្មត់ប្រាក់ចំណូលសរុបរបស់អ្នកប្រើប្រាស់ ថេរ ហើយគេសិក្សាពីរបៀបដែលអ្នកប្រើប្រាស់ ចាយប្រាក់ចំណូលរបស់ខ្លួនក្នុងការទិញទំនិញ ផ្សេងៗ។ ចំណែកឯនៅក្នុងការសិក្សាម៉ាក្រូសេដ្ឋកិច្ច វិញ កម្រិតនៃប្រាក់ចំណូលសរុប ឬចំណាយគឺស្ថិតនៅក្នុងចំណោមអថេរសំខាន់ៗដែលត្រូវសិក្សា។

ឃ.តារាង "ប្រជាពលរដ្ឋនិងកម្លាំងពលកម្មនៅកម្ពុជា" ព័ត៌មាន ដែលអ្នកចាប់អារម្មណ៍ជាងគេកម្លាំងពលកម្មសរុបដែលមានសារៈសំខាន់សម្រាប់ការសិក្សាម៉ាក្រូសេដ្ឋកិច្ច។

ង. ដើម្បីដោះស្រាយបញ្ហាសេដ្ឋកិច្ចមួយ គេត្រូវសិក្សាវិភាគទាំងក្នុងម៉ាក្រូសេដ្ឋកិច្ចនិងក្នុងមីក្រូសេដ្ឋកិច្ច។

# មេរៀនទី២

## គោលនយោបាយសេដ្ឋកិច្ច

?សំណួរ

2. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬជាក្រុមដើម្បីដោះស្រាយនូវសំណួរខាងក្រោម

ក. ដូចម្ដេចហៅថា ការសម្រួលគោលនយោបាយសេដ្ឋកិច្ច?

ខ. គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនៃប្រទេសនីមួយៗក្នុងពិភពលោកមានខ្លឹមសារដូចគ្នាឬទេ?ហេតុអ្វី?

គ. តើអ្វីជាប្រសិទ្ធភាពនៃការសម្រួលគោលនយោបាយសេដ្ឋកិច្ច?ចូរពន្យល់។

ឃ. តើនឹងមានផលប៉ះពាល់យ៉ាងដូចម្ដេច ប្រសិនបើការសម្រួលគោលនយោបាយសេដ្ឋកិច្ចមិនទទួលជោគជ័យ?

# ចម្លើយ

2.ក.ការសម្រួលគោលនយោបាយសេដ្ឋកិច្ចមានន័យថា ការរៀបចំគោលនយោបាយនានាដែលពាក់ព័ន្ធនឹងបញ្ហាម៉ាក្រូសេដ្ឋកិច្ចឱ្យមានលក្ខណៈសមស្របតាមដំណើរអភិវឌ្ឍន៍ជាក់ស្តែងនៃសេដ្ឋកិច្ចរបស់ប្រទេសមួយ។

ខ. គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនៃប្រទេសនីមួយៗក្នុងពិភពលោកមានខ្លឹមសារមិនដូចគ្នាពីព្រោះ គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចក្នុងបណ្តាប្រទេសជឿនលឿនធានាឱ្យមានកំណើនសេដ្ឋកិច្ចដោយផ្អែកលើដំណើរការផលិតកម្ម ភាពមានការងារធ្វើពេញលេញនិងធ្វើឱ្យអត្រាអតិផរណាស្ថិតក្នុងកម្រិតទាប។ ចំណែកឯគោលបំណងនៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍវិញ មានការកំណត់ទៅតាមបញ្ហាជាអាទិភាពជាច្រើន រួមមានកំណែទម្រង់ប្រព័ន្ធសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ថាប័នច្បាប់តុលាការ និងកំណែទម្រង់ផ្នែករដ្ឋបាលសាធារណៈជា

ដើម។

គ. ប្រសិទ្ធភាពនៃការសម្របសម្រួលគោលនយោបាយសេដ្ឋកិច្ចគឺរដ្ឋត្រូវប្រើប្រាស់ឧបករណ៍គោលនយោបាយសារពើពន្ធ រូបិយវត្ថុ ពាណិជ្ជកម្មក្រៅប្រទេស និងគោលនយោបាយប្រាក់ចំណូលជាដើមដែលបានសម្របសម្រួលរួចហើយ។ប៉ុន្តែក្នុងការប្រើប្រាស់ឧបករណ៍ខាងលើរដ្ឋអាចជួបបញ្ហាជាច្រើន ដែលអាចធ្វើឱ្យការអនុវត្តគោលនយោបាយនោះមិនទទួលបានជោគជ័យគឺបណ្តាលមកពីមូលហេតុជាច្រើនដូចជា:

- ប្រព័ន្ធផ្តល់ព័ត៌មានមិនទាន់សម័យ ឬការផ្តល់ព័ត៌មានមិនទាន់ហេតុការណ៍។
- កង្វះប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់និងរចនាសម្ព័ន្ធសេដ្ឋកិច្ចមិនសូវមានការអភិវឌ្ឍ។
- យឺតយ៉ាវក្នុងការសំរេចចិត្តខុស ឬអនុវត្តគោលនយោបាយ។
- អំពើគេចពន្ធនិងចរាចរណ៍ទំនិញខុសច្បាប់។
- ឱនភាពថវិការដ្ឋដែលកើតមានដោយសារការប្រែ

មូលពន្ធមិនតាមគោលការណ៍កំណត់។

❖កង្វះប្រសិទ្ធភាពក្នុងការប្រតិបត្តិការងាររបស់រដ្ឋបាលសាធារណៈ។

❖ភាពអនាធិបតេយ្យក្នុងសកម្មភាពសេដ្ឋកិច្ច។

ឃ.ប្រសិនបើការសម្រេសម្រួលគោលនយោបាយសេដ្ឋកិច្ចមិនបានទទួលជោគជ័យនោះនឹងមានផលប៉ះពាល់ដូចជា:

✓គ្រោះធម្មជាតិ មានភាពរាំងស្ងួន ទឹកជំនន់ ខ្យល់ព្យុះជាដើម។

✓ការបំពុលបរិយាកាស ទឹកប្រើប្រាស់ ដែលបង្កដោយកាកសំណល់មានជាតិវិទ្យុសកម្មជាហេតុនាំឱ្យមានជំងឺផ្សេងៗរាលដាលពេញសហគមន៍។

✓អាជីវកម្មបំពានច្បាប់និងរំលោភក្រមសីលធម៌របស់សេដ្ឋកិច្ច។

✓ការប្រើប្រាស់ពលកម្មកុមារធ្ងន់ធ្ងរក្នុងផលិតកម្ម។

✓កង្វះប្រសិទ្ធភាពនៃរដ្ឋបាលសាធារណៈ។

មេរៀនទី៣

# សេដ្ឋកិច្ចកម្ពុជា

?សំណួរ

2. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬជាក្រុម ដើម្បីឆ្លើយសំណួរដូចខាងក្រោមនេះ

ក. ចូររៀបរាប់ស្ថានភាពរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជាមុនសម័យសង្គ្រាម។

ខ. ចូររៀបរាប់ភាពទូទៅនៃការរីចចម្រើននៃសេដ្ឋកិច្ចនៃកម្ពុជា ក្រោយសម័យសង្គ្រាម។

គ. តើសកម្មភាពអ្វីខ្លះជាកំណែទម្រង់ចរិតអភិរក្សនៃសេដ្ឋកិច្ចកម្ពុជា?

ឃ.ចូរបង្ហាញធនធានជាមូលដ្ឋាននៃការសក្តានុពលសេដ្ឋកិច្ចកម្ពុជា។

## ចម្លើយ

2. ក.ស្ថានភាពរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជា មុនសម័យសង្គ្រាមៈចាប់តាំងពីសម័យនៅក្រោមនឹងអាណានិគមបារាំងរហូតដល់សម័យសាធារណរដ្ឋខ្មែរចរិតលក្ខណៈសេដ្ឋកិច្ចទំនើបបានជ្រៀតចូលជាបណ្តើរៗមកក្នុងសង្គមកម្ពុជា។ច្ចេកទេសការងារក្នុងគ្រប់វិស័យជាពិសេសបច្ចេកទេសក្នុងការងារធារាសាស្ត្រការដាំដុះនិងចិញ្ចឹមសត្វត្រូវបានកែលំអទៅរកភាពជឿនលឿនបន្តិចម្តងៗ។ ការប្រើម៉ាស៊ីនយន្តក្នុងកសិកម្មបានកើតមានឡើងជាដំបូងនៅឆ្នាំ១៩៦៧ក្នុងសម័យសង្គមរាស្រនិយមក្រោមការដឹកនាំរបស់ព្រះករុណាព្រះបាទនរោត្តមសីហនុ។ទន្ទឹមនឹងនោះព្រះរាជាណាចក្រកម្ពុជាបានកសាងនិងដាក់ឱ្យមានដំណើរការរោងចក្រឧស្សាហកម្មមួយចំនួន មានរោងចក្រតម្បាញក្រចៅតំបាញកំណាត់ទេសឯក រោងចក្រធ្វើកៅស៊ូ ក្រែបរោងចក្រកែវស៊ីម៉ងត៍ ក្តារបន្ទះ បារីស្ករស ត្រីខប្រអប់.....ដែលមានសមត្ថភាពផលិតដើម្បីបម្រើសេចក្តីត្រូវ

ការក្នុងប្រទេស និងអាចនាំផលិតផលចេញទៅក្រៅប្រទេសទៀតផង។ប៉ុន្តែទោះជាយ៉ាងនេះក្តី ជាទូទៅសេដ្ឋកិច្ចកម្ពុជានៅតែជាសេដ្ឋកិច្ចដែលពឹងផ្អែកលើខឿនសេដ្ឋកិច្ចឧស្សាហា កម្មអន់ថយមានលក្ខណៈបុរាណ និងប្រពៃណីនិយមនិង ជាប្រភេទសេដ្ឋកិច្ចឯកវប្បកម្ម។ ការបែងចែកពលកម្មក្នុងប្រព័ន្ធសេដ្ឋកិច្ចមានកម្រិតទាបបំផុត។ ក្នុងចំណោមមនុស្ស១០នាក់គឺមានមនុស្ស៨នាក់ទៅហើយដែលប្រកបរបរកសិកម្ម នៅសល់តែ២នាក់ប៉ុណ្ណោះ ដែលប្រកបមុខរបរផ្សេងទៀត។ប្រជាកសិករភាគច្រើនលើសលប់ប្រកបមុខរបរកសិកម្មតាមបែបផែនផលិតកម្មបុរាណដោយពឹងផ្អែកទាំងស្រុងលើធម្មជាតិ និងគ្មានប្រើប្រាស់បច្ចេកទេសទំនើប។ជាទូទៅ សក្តានុពលសេដ្ឋកិច្ចកម្ពុជាពឹងផ្អែកជាចម្បងលើការនាំចេញផលិតផលកសិកម្មស្រូវ។ក្រៅពីនេះមានការនាំចេញផលិតផល និងអនុផលព្រៃឈើផលិតផលនេសាទ រ៉ែត្បូងថ្មនិងផលិតផលវាយនភណ្ឌផ្សេងៗ។

ខ. ក្រោយសម័យសង្គ្រាម ការរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជាគឺ:បន្ទាប់ពីការដួលរលំភ្លាមនៃរបបប្រល័យពូជសាសន៍នាថ្ងៃ ៧ មករា ១៩៧៩ សេដ្ឋកិច្ចប្រទេសកម្ពុជាស្ថិតនៅកម្រិតសូន្យ។នាពេលវិលត្រឡប់មកភូមិស្ថានកំណើតវិញប្រជាពលរដ្ឋជាទូទៅស្ថិតក្នុងភាពទុគ៌តខ្វះទីលំនៅ ចំណីអាហារ សម្លៀកបំពាក់ ថ្នាំសង្កូវ ហើយថែមទាំងមានជំងឺរុំារ៉ៃ។ប៉ុន្តែដោយការខិតខំស្តារនិងកសាងជាតិឡើងវិញរបស់រដ្ឋាភិបាល និងប្រជាពលរដ្ឋគ្រប់រូប និងរួមទាំងឧបត្ថម្ភជាសម្ភារៈថវិកា និងស្មារតីពីសហាគមន៍អន្តរជាតិផងពីមួយឆ្នាំទៅមួយឆ្នាំប្រទេសកម្ពុជាមានការលូតលាស់រីកចម្រើនជាលំដាប់មានដូចជាការលូតលាស់ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តសេដ្ឋកិច្ច សង្គម វប្បធម៌ សាសនា ជាដើមដែលសុទ្ធសឹងជាមូលដ្ឋានសម្រាប់ការកាត់បន្ថយភាពក្រីក្រនិងការទ្រទ្រង់សិទ្ធិសេរីភាព និងប្រជាធិបតេយ្យ។ប៉ុន្តែ ទោះបីមានការឧបត្ថម្ភគាំទ្រពីមូលនិធិអន្តរជាតិយ៉ាងណាក្តី ក៏សក្តានុពលសេដ្ឋកិច្ចកម្ពុជា

នៅតែពឹងផ្អែកលើវិស័យមួយចំនួន មានវិស័យកាត់ដេរ សំណង់ សេវាកម្ម និងទេសចរណ៍ហើយចរិតសេដ្ឋកិច្ចមានលក្ខណៈតាមទម្លាប់ពីមុនមក។ប្រទេសកម្ពុជាមានផ្ទៃ ដីដាំដុះបង្គួរដែលអាចដាំដំណាំដូចជា ស្រូវ ពោតស៊ូ អំពៅ កាហ្វេ ត្នោត ដំឡូងមីជាដើម។ក្រៅពីនេះប្រទេសកម្ពុជានៅមានធនធានផ្នែកប្រព័ន្ធជលសាស្ត្រដែលអាចជួយសម្រួលយ៉ាងច្រើនដល់ផ្នែកដឹកជញ្ជូន និងអាចក្លាយជាមូលដ្ឋានផលិតថាមពលវារីអគ្គិសនីដ៏សំខាន់ថែមទៀតផង។បន្ថែមលើនេះ ប្រទេសកម្ពុជាមានធនធានរ៉ែមួយចំនួនសំខាន់គឺ ត្បូងថ្ម ដែលបានបម្រើអាជីវកម្មរបស់ប្រជាពលរដ្ឋមួយចំនួន តាំងពីសម័យដើមរហូតដល់បច្ចុប្បន្ន។ក្រៅពីនេះនៅមានធនធានរ៉ែក្នុងដី និងក្រោមដី មានប្រេងកាត មាស ដែកសំណប៉ាហាំង និងបុកស៊ីតដែលភាគច្រើនកំពុងស្ថិតក្នុងការស្រាវជ្រាវរុករកនៅឡើយ។

គ. កំណែទម្រង់ចរិតអភិវឌ្ឍន៍នៃសេដ្ឋកិច្ចកម្ពុជាមានសកម្មភាពដូចជាៈ

✓ មានការបែងចែកពលកម្មក្នុងកម្រិតខ្ពស់។

✓ គំរូកិច្ចការប្រពលវប្បកម្មដំណាំស្រូវ: ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវមានការអភិវឌ្ឍជាទូទៅនិងជាផ្លូវការនៅប្រទេសម៉ាដាកាស្កា។គេបានរកឃើញថាប្រព័ន្ធនេះជាបច្ចេកវិទ្យាកសិកម្មដំណាំស្រូវដែលធានាបាននូវការអភិវឌ្ឍជានិរន្តរ៍ដែលអាចជួយដល់ កសិករក្នុងការបង្កើតផលស្រូវលើដីតូចតាចរបស់គេឱ្យបានជាង១០តោនក្នុងមួយហិចតា ដោយមិនពឹងផ្អែកលើពូជបង្កាត់ ជីគីមីនិងថ្នាំគីមីកំចាត់សត្វល្អិត។

✓ មានមូលដ្ឋានបច្ចេកទេសនិងវិទ្យាសាស្ត្រមានបែបផែនផលិតកម្មដែលពឹងផ្អែកទៅលើបច្ចេកទេសវិទ្យាទំនើប និងមានរៀបចំចាត់ចែងគ្រប់គ្រងផលិតកម្ម និងបែងចែកផលិតផលតាមបែបវិទ្យាសាស្ត្រ។

✓ ជាសេដ្ឋកិច្ចបែបប្រពលវប្បកម្ម។ការអភិវឌ្ឍសេដ្ឋកិច្ចជាតិត្រូវពឹងផ្អែកសំខាន់លើការផ្លាស់ប្តូរ

ផ្នែកគុណភាព ដែលផ្សារភ្ជាប់ទៅនឹងការផ្លាស់ប្តូរក្នុងរចនា សម្ព័ន្ធសេដ្ឋកិច្ច ការជំរុញឱ្យមានការប្រើប្រាស់បច្ចេកទេសទាន់សម័យ ចំណេះដឹងនិងចំណេះធ្វើថ្មីៗដើម្បីជានាកំណើនផលិតកម្ម។

✓មានយន្តការគ្រប់ដណ្តប់ និងនាំមុខដាច់ខាតនៅក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ដែលឈរលើមូលដ្ឋានកម្មសិទ្ធិឯកជនសេរីភាពក្នុងការជ្រើសរើស និងការប្រកបមុខរបរ មានការផលិតសម្រាប់បម្រើឱ្យទីផ្សារក្នុងការសម្របសម្រួលដំណើរការសេដ្ឋកិច្ចរដ្ឋប្រើឧបករណ៍ប្រយោលដូចជា យន្តការច្បាប់ គោល នយោបាយសារពើពន្ធ គោលនយោបាយពន្ធដារ គោលនយោបាយវិនិយោគ និងរូបិយវត្ថុគោល គោលនយោបាយលើកទឹកចិត្តជាដើម។

ឃ.ធនធានជាមូលដ្ឋាននៃការសក្តានុពលសេដ្ឋកិច្ចកម្ពុជាមាន:

✓ផលិតផលឧស្សហកម្ម: ផលិតផលឧស្សាហកម្ម

សំខាន់ដែលបម្រើការនាំចេញនៅកម្ពុជាគឺ សម្លៀកបំពាក់ និងកៅស៊ូក្រែប។ក្រៅពីនេះ មានផលិតផលសិប្បកម្មតម្បាញសូត្រ និងសិប្បកម្មកែច្នៃជាវត្ថុអនុស្សាវរីយ៍ជាគ្រឿងអលង្ការជាដើម។

✓ ផលិតផលសំខាន់ៗនៃវិស័យកសិកម្ម នេសាទ និង ព្រៃឈើៈមានដូចជាស្រូវ ថ្នាំជក់ ត្រី សត្វចិញ្ចឹម និងឈើ។ក្រៅពីនេះ ផលិតផលដែលមានតម្រូវការក្នុងការនាំចេញមាន ពោត សណ្តែក ល្ហុង ដំឡូង អំពៅ គ្រាប់ស្វាយចន្ទី ម្រេច កាហ្វេ និងផ្លែឈើ។

# មេរៀនទី៨

## តួនាទីរដ្ឋក្នុងដំណើរសេដ្ឋកិច្ច

?សំណួរ

2. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬជាមួយសមាជិកឯទៀតក្នុងក្រុមដើម្បីរកចម្លើយចំពោះសំណួរខាងក្រោម

ក. តើរដ្ឋមានតួនាទិដូចម្តេចខ្លះនៅក្នុងសង្គមជាតិមួយ?

ខ. ជាទូទៅតើរដ្ឋមានតួនាទីអ្វីខ្លះនៅក្នុងសេដ្ឋកិច្ច?ចូររៀបរាប់។

គ. តើរដ្ឋមានតួនាទីអ្វីខ្លះនៅក្នុងសេដ្ឋកិច្ចទីផ្សារ?ចូររៀបរាប់។

ឃ.តើរដ្ឋមានតួនាទីអ្វីខ្លះនៅក្នុងសេដ្ឋកិច្ចបញ្ជា?ចូររៀបរាប់។

ង. តើរដ្ឋមានតួនាទីអ្វីខ្លះនៅក្នុងសេដ្ឋកិច្ចចម្រុះ?ចូររៀបរាប់។

ច. តើសេដ្ឋកិច្ចចម្រុះបែបទិផ្សារមានន័យយ៉ាងដូចម្តេច?

ចូរផ្តល់ឧទាហរណ៍។

ឆ. តើសេដ្ឋកិច្ចបែបបញ្ជាមានន័យដូចម្តេច?ចូរផ្តល់ឧទាហរណ៍។

ជ. តើសេដ្ឋកិច្ចចម្រុះបែបទីផ្សារនិងសេដ្ឋកិច្ចចម្រុះបែបបញ្ជាមានភាពខុសគ្នាយ៉ាងដូចម្តេច?

ឈ.តើរដ្ឋមានតួនាទីអ្វីខ្លះក្នុងវិស័យសេដ្ឋកិច្ចនៅក្នុងប្រទេសកំពុងអភិវឌ្ឍ?

---

**ចម្លើយ**

2.ក.នៅក្នុងសង្គមជាតិមួយ រដ្ឋមានតួនាទីជាអ្នកសម្របសម្រួលនិងធានាកំណើនសេដ្ឋកិច្ចជាតិ។

ខ. នៅក្នុងសេដ្ឋកិច្ចរដ្ឋមានតួនាទី២គឺ:

✓តួនាទីដោយឡែក: តួនាទីដោយឡែករបស់រដ្ឋក្នុងសេដ្ឋកិច្ចគឺអាស្រ័យទៅលើប្រព័ន្ធគ្រប់គ្រងសេដ្ឋកិច្ចប្រសិនបើសង្គមនោះមានប្រព័ន្ធគ្រប់គ្រងសេដ្ឋកិច្ចបែបសេដ្ឋកិច្ចបញ្ជារដ្ឋមានតួនាទីស្ទើរទាំងស្រុងលើដំណើរការអភិវឌ្ឍសេដ្ឋកិច្ច។ ក្នុងករណីនេះដំណើរការផលិតកម្មដោះស្រាយ

បញ្ហាសំខាន់ៗទាក់ទងទៅនឹងផលិតកម្មកំណត់ការប្រើប្រាស់និងការបែងចែក ធនធានសេដ្ឋកិច្ច។

✓ តួនាទីរួមៈការពារយន្តការសេដ្ឋកិច្ចដោយបង្កើតឡើងនូវមូលដ្ឋានច្បាប់ និងបរិស្ថានសង្គមចាំបាច់សម្រាប់ជំរុញនិងសម្រសម្រួលការប្រព្រឹត្តទៅនៃយន្តការសេដ្ឋកិច្ច។តួនាទីនេះផ្សារភ្ជាប់ទៅនឹងការការពារ ការប្រកួតប្រជែងនៅក្នុងសេដ្ឋកិច្ចការសម្របសម្រួលការងារស្ថាប័ននិងភ្នាក់ងារសេដ្ឋកិច្ចនានា ដោយឈរលើមូលដ្ឋានច្បាប់និងការធានានូវស្ថិរភាពនិងសន្តិសុខសង្គមផងដែរ។

គ. នៅក្នុងសេដ្ឋកិច្ចទីផ្សាររដ្ឋមានតួនាទីត្រឹមជាអ្នកការពារកម្មសិទ្ធិ ជាអ្នកបង្កើតនិងចាត់ចែងស្ថាប័នសង្គមមូលដ្ឋានច្បាប់ផ្សេងៗដែលចាំបាច់សម្រាប់ជំរុញ និងសម្របសម្រួលការប្រព្រឹត្តទៅនៃយន្តការសេដ្ឋកិច្ចទីផ្សារតែប៉ុណ្ណោះ។

ឃ. នៅក្នុងសេដ្ឋកិច្ចបញ្ជារដ្ឋមានកម្មសិទ្ធិលើកត្តាផលិតកម្មស្ទើរតែទាំងអស់។ ឯយន្តការគ្រប់គ្រងនិងការសម្រ

សម្រួលផ្អែកទៅលើមូលដ្ឋានសេដ្ឋកិច្ចផែនការមាន ន័យថាដំណើរការផលិតកម្មស្ថិតនៅក្រោមការកំណត់ របស់រដ្ឋ។ដំណោះស្រាយធំៗទាក់ទងទៅនឹងផលិត កម្ម ការប្រើប្រាស់ការបែងចែកក៏ស្ថិតនៅក្រោមកំណត់ របស់រដ្ឋ។ដោយហេតុថាសហគ្រាសជាកម្មសិទ្ធិរដ្ឋ ដូចនេះ សកម្មភាពរបស់ភ្នាក់ងារសេដ្ឋកិច្ចក្នុងផលិត កម្ម ការចែកចាយការផ្លាស់ប្តូរទំនិញនិងសេវាកម្មផ្សេង ៗស្ថិតនៅក្រោមការ ត្រួតពិនិត្យនិងត្រូវអនុវត្តតាមផែន ការរបស់រដ្ឋ។

ង. នៅក្នុងសេដ្ឋកិច្ចចម្រុះរដ្ឋមានតួនាទីដូចជា:

- ចំពោះសេដ្ឋកិច្ចបែបផែនការៈរដ្ឋមានតួនាទីធ្វើអន្ត រាគមន៍លើការកែសម្រួល និងបំពេញចន្លោះខ្វះខាត់ របស់យន្តការទីផ្សារនិងផ្ទេរសកម្មភាពទីផ្សារឲ្យ ក្លាយទៅជាសកម្មភាពមានប្រយោជន៍ចំពោះសង្គម ជាតិទាំងមូល។
- ចំពោះសេដ្ឋកិច្ចចំរុះបែបផែនការៈរដ្ឋមានតួនាទីធ្វើ យន្តការទីផ្សារ និងធ្វើសកម្មភាពបំពេញភាពខ្វះ

ចន្លោះនៃយន្តការទីផ្សារ។

ច. សេដ្ឋកិច្ចចម្រុះបែបទីផ្សារមានន័យថា សេដ្ឋកិច្ចដែលលក្ខណៈកំពុងបែរទៅរកសេដ្ឋកិច្ចទីផ្សារ។

ឧទាហរណ៍: សេដ្ឋកិច្ចសហរដ្ឋអាមេរិចជាសេដ្ឋកិច្ចទីផ្សារសេរីប៉ុន្តែមានលក្ខណៈពិសេសត្រង់រដ្ឋមានតួនាទីដ៏សកម្មក្នុងការប្រើឧបករណ៍ម៉ាក្រូសេដ្ឋកិច្ចដែលមានក្នុងដៃសម្រាប់ចូលរួមសម្របសម្រួលក្នុងដំណើរការអភិវឌ្ឍ សេដ្ឋកិច្ចមានដូចជាជំរុញការអនុវត្តគោលនយោបាយសារពើពន្ធ ដើម្បីរក្សាស្ថិរភាពនិងជំរុញកំណើនសេដ្ឋកិច្ច ផ្តល់ទំនិញនិងសេវាដែលអវត្តមានក្នុងទីផ្សារ ឬមានពុំគ្រប់គ្រាន់ជាដើម។

ឆ. សេដ្ឋកិច្ចចម្រុះបែបបញ្ជាគឺរដ្ឋធ្វើអន្តរាគមន៍ រដ្ឋអាចកែសម្រួលនិងបំពេញចន្លោះខ្វះខាតរបស់យន្តការទីផ្សារនិងផ្ទេរសកម្មភាពទីផ្សារឱ្យក្លាយទៅជាសកម្មភាពមានប្រយោជន៍សម្រាប់សង្គមជាតិទាំងមូល។

ឧទាហរណ៍: សេដ្ឋកិច្ចអតីតសហភាពសូវៀតនិងជាពិសេសសេដ្ឋកិច្ចរបស់បណ្តាប្រទេសអឺរ៉ុបខាងកើតមាន

លក្ខណៈជាសេដ្ឋកិច្ចបញ្ជា។

ជ. សេដ្ឋកិច្ចចម្រុះបែបទីផ្សារ និង សេដ្ឋកិច្ចចម្រុះបែបបញ្ជាមានភាពខុសគ្នា:

✓សេដ្ឋកិច្ចចម្រុះបែបបញ្ជាមានយន្តការទីផ្សារ ដោយសារគេយល់ថាក្នុងដំណាក់កាលដែលប្រព័ន្ធសេដ្ឋកិច្ច បញ្ជាកំពុងមានដំណើរការនោះ ទាមទារការប្រើជាបណ្ដោះអាសន្ននូវយន្តការសេដ្ឋកិច្ចទីផ្សារ។

✓ទិសដៅរបស់សេដ្ឋកិច្ចចម្រុះបែបទីផ្សារគឺការឈានឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារសុទ្ធសាធ ឯប្រការដែលយកយន្តការរដ្ឋមកប្រើក្នុងករណីខ្លះនោះ គឺដើម្បីបំពេញការខ្វះចន្លោះរបស់សេដ្ឋកិច្ចទីផ្សារតែប៉ុណ្ណោះ។

ឈ.ក្នុងវិស័យសេដ្ឋកិច្ចនៅក្នុងប្រទេសកំពុងអភិវឌ្ឍរដ្ឋមានតួនាទីដូចជា:

❖ដោះស្រាយភាពខ្សោយនៃផ្នែកឯកជន។

❖ដោះស្រាយចរិតឯករប្បកម្មនៃសេដ្ឋកិច្ចជាតិអន់ថយ

❖ដោះស្រាយនូវភាពអន់ថយនៃរបៀបផលិតក្នុងផ្នែកកសិកម្ម។

❖ដោះស្រាយនូវភាពខ្ទេចខ្ទាំនិងក្រខ្សត់នៃសេដ្ឋកិច្ច។

---

# មេរៀនទី៩

## អន្តរាគមន៍រដ្ឋក្នុងទីផ្សារ

### ?សំណួរ

2. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬសមាជិកដទៃទៀតក្នុងក្រុមដើម្បីដោះស្រាយសំណួរខាងក្រោម

ក. ដូចម្ដេចហៅថា សេដ្ឋកិច្ចទីផ្សារ?

ខ. តើរដ្ឋមានតួនាទីអ្វីខ្លះក្នុងសេដ្ឋកិច្ចទីផ្សារ?

គ. ដូចម្ដេចហៅថា សេដ្ឋកិច្ចចម្រុះទីផ្សារ?

ឃ. តើរដ្ឋមានតួនាទីអ្វីខ្លះក្នុងសេដ្ឋកិច្ចចម្រុះទីផ្សារ?

ង. តើសេដ្ឋកិច្ចជាមូលដ្ឋានក្នុងប្រទេសកំពុងអភិវឌ្ឍមានលក្ខណៈដូចម្ដេច?

ច. តើរដ្ឋមានតួនាទីបែបណាក្នុងការកសាងសេដ្ឋកិច្ចទីផ្សារក្នុងប្រទេសកំពុងអភិវឌ្ឍ?

ឆ. ក្នុងសេដ្ឋកិច្ចទីផ្សារនៃប្រទេសកំពុងអភិវឌ្ឍហេតុអ្វីមានពេលខ្លះរដ្ឋដាក់បទបញ្ជា?

# ចម្លើយ

2.ក.សេដ្ឋកិច្ចទីផ្សារគឺ កម្មសិទ្ធិលើមធ្យោបាយផលិតកម្មមួយផ្នែកធំស្ថិតនៅក្នុងរង្វង់ការគ្រប់គ្រងផ្នែកឯកជន។

ខ. នៅក្នុងសេដ្ឋកិច្ចទីផ្សារ រដ្ឋមានតួនាទីជាអ្នកការពារកម្មសិទ្ធិ ជាអ្នកបង្កើតនិងចាត់ចែងស្ថាប័នសង្គម មូលដ្ឋានច្បាប់ផ្សេងៗដែលចាំបាច់សម្រាប់ជំរុញ និងសម្រួលការប្រព្រឹត្តទៅនៃយន្តការសេដ្ឋកិច្ចទីផ្សារតែប៉ុណ្ណោះ។

គ.សេដ្ឋកិច្ចចម្រុះបែបទីផ្សារគឺជាប្រព័ន្ធសេដ្ឋកិច្ចដែលរដ្ឋក៏មានសិទ្ធិលើផលិតកម្ម ហើយឯជនក៏មានសិទ្ធិលើផលិតកម្ម ពោលគឺអនុញ្ញាតិឲ្យមានក្រុមហ៊ុនរដ្ឋផងនិងក្រុមហ៊ុនឯកជនផង ហើយជាអ្នកធ្វើយន្តការសេដ្ឋកិច្ចដោយប្រើប្រាស់គោលការណ៍របស់ខ្លួន។

ឃ.នៅក្នុងសេដ្ឋកិច្ចចម្រុះទីផ្សារ រដ្ឋមានតួនាទី២គឺ:

- តួនាទីដោយចំពោះឬបញ្ញា មានន័យថាជាការលូកដៃកាន់តែជ្រៅរបស់រដ្ឋក្នុងសេដ្ឋកិច្ច ជាពិសេសការជំរុញដំណើរការបង្កើនផលិតផលសង្គម តាមរយៈ

រឿងចក្រឬសហគ្រាសរដ្ឋដែលប្រព្រឹត្តទៅមិននៅក្រោមឥទ្ធិពលនៃក្រឹត្យក្រមតម្រូវការនិងការផ្គត់ផ្គង់

➤ ក្នុងបរិបទក្រឹត្យក្រមសេដ្ឋកិច្ចដោយការប្រើប្រាស់ឧបករណ៍ម៉ាក្រូសេដ្ឋកិច្ច។ ឧបករណ៍ម៉ាក្រូសេដ្ឋកិច្ចគឺជា ឧបករណ៍សំខាន់ដែលរដ្ឋាភិបាលប្រើប្រាស់សម្រាប់ធ្វើឱ្យសេដ្ឋកិច្ចមានស្ថិរភាពកំណើនបរិមាណផលិតផលជាតិស្ថិរភាពកម្រិតថ្លៃ និងរក្សាតុល្យភាពពាណិជ្ជកម្មក្រៅប្រទេស។ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារពិតមែនតែអាចសម្របសម្រួលទៅបានដោយឯកឯង ប៉ុន្តែនៅមានភាពខ្វះខាត រដ្ឋត្រូវប្រើប្រាស់ឧបករណ៍ម៉ាក្រូសេដ្ឋកិច្ចដែលមានដូចជា

- គោលនយោបាយសារពើពន្ធ
- គោលនយោបាយរូបិយវត្ថុ
- គោលនយោបាយពាណិជ្ជកម្មក្រៅប្រទេស

ង. សេដ្ឋកិច្ចជាមូលដ្ឋានក្នុងប្រទេសកំពុងអភិវឌ្ឍមានលក្ខណៈដូចជាៈ

- ចរិតឯកវប្បកម្មនៃសេដ្ឋកិច្ចជាតិ។

- ភាពទន់ខ្សោយនៃផ្នែកឯកជន។
- ភាពអន់ថយនៃរបៀបផលិតកម្មក្នុងផ្នែកកសិកម្ម
- ភាពខ្ទេចខ្ទាំដោយសារសង្គ្រាម។

ច.ក្នុងការកសាងសេដ្ឋកិច្ចទីផ្សារក្នុងប្រទេសកំពុងអភិវឌ្ឍ រដ្ឋជាអ្នកកសាងនិងពង្រីកមូលដ្ឋានគ្រឹះនៃប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ តាមរយៈការបោះជំហានចេញពីភាពក្រីក្រដោយប្រើមធ្យោបាយទាំងក្នុងតួនាទីដោយប្រយោល និងទាំងក្នុងតួនាទីដោយចំពោះហើយក្នុងករណីចាំបាច់ ខ្លះរដ្ឋដាក់ចេញនូវបទបញ្ជា។

ឆ.ក្នុងសេដ្ឋកិច្ចទីផ្សារនៃប្រទេសកំពុងអភិវឌ្ឍ ពេលខ្លះ រដ្ឋដាក់បទបញ្ជាពីព្រោះ ដើម្បីកែសម្រួលនិងបំពេញចន្លោះ ឬកង្វះខាតនៃយន្តការទីផ្សារនិងប្រែក្លាយយន្តការទីផ្សារនោះឱ្យទៅជាសកម្មភាពមានប្រយោជន៍សម្រាប់សង្គមជាតិទាំងមូល។

---

## មេរៀនទី៦

# ចំណូលជាតិ

?សំណួរ

2. ចូរឱ្យនិយមន័យនៃពាក្យ "ចំនូលជាតិ"។
3. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬជាក្រុម ដើម្បីដោះស្រាយនូវសំណួរខាងក្រោម

ក. តើចំណូលជាតិមានលក្ខណៈខុសពីចំណូលបុគ្គលដូចម្តេច?

ខ. តើចំណូលជាតិមានសមាសធាតុប៉ុន្មាន?អ្វីខ្លះ?

គ. តើចំណូលបុគ្គលចែកចេញជាប៉ុន្មានប្រភេទ? អ្វីខ្លះ?

ឃ. ហេតុអ្វីបានជាចំណូលបុគ្គលក្រោយការបង់ពន្ធមានសារៈសំខាន់សម្រាប់គ្រួសារ?

ចម្លើយ

2. ចំណូលជាតិ គឺជាបរិមាណទឹកប្រាក់សរុបដែលរកបាននៅក្នុងប្រទេស បានទទួលដោយអ្នកផ្គត់ផ្គង់ធនធាន

សេដ្ឋកិច្ចនិងធនធានហិរញ្ញវត្ថុ។

៣. ក.ចំណូលជាតិមានលក្ខណៈខុសពីចំណូលបុគ្គលត្រង់

✓ ចំណូលបុគ្គលគឺគិតទៅលើចំណូលដែលរកបាន ដោយបុគ្គលដែលនៅសល់ពីការចំណាយនានា។

✓ ចំណូលជាតិគឺគិតទៅលើរបស់ប្រទេសមួយដែល រាប់បញ្ចូនទាំងចំណូលបុគ្គល។

ខ. ចំណូលជាតិមានសមាសធាតុមាន៦ដូចជា:

- ចំណូលពីការជួល
- ចំណូលពីបរទេស
- ការប្រាក់សុទ្ធ
- ចំណូលរបស់ម្ចាស់កម្មសិទ្ធិ
- ប្រាក់ពលកម្ម ឬសំណងទូទាត់សម្រាប់និយោជិត
- ប្រាក់ចំណេញសាជីវកម្ម

គ. ចំណូលបុគ្គលចែកចេញជា២ប្រភេទគឺ:

- ចំណូលដែលមិនបានរក
- តែបានទទួលចំណូលរកបាន តែមិនបានទទួល

ឃ.បានជាចំណូលបុគ្គលក្រោយការបង់ពន្ធមានសារៈ

សំខាន់សម្រាប់គ្រួសារពីព្រោះ ចំណូលបុគ្គលក្រោយការបង់ពន្ធ បង្ហាញពីបរិមាណនៃចំណូលផ្នែកគ្រួសារដើម្បីចំណាយៗវាគឺជាចំណូលដែលអាចយកប្រើប្រាស់បានតាមតម្រូវការ និងចំណង់ចំណូលចិត្តមានការទិញទំនិញ និងសេវាកម្មប្រើប្រាស់និងយកទៅសន្សំនៅទីផ្សារហិរញ្ញវត្ថុជាដើម។

---

## មេរៀនទី៧

# គោលនយោបាយចំណាយនិងសារពើពន្ធ

?សំណួរ

2. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬជាក្រុម ដើម្បីដោះស្រាយសំណួរខាងក្រោម

ក. ហេតុអ្វីបានជារដ្ឋាភិបាលគ្រប់ប្រទេសត្រូវការចំណាយ? តើមានការចំណាយទៅលើអ្វីខ្លះ?

ខ. តើការចំណាយរបស់រដ្ឋាភិបាលមានប៉ុន្មានប្រភេទ? អ្វីខ្លះ?ចូររៀបរាប់និងពន្យល់។

គ. តើរដ្ឋាភិបាលរកចំណូលដោយវិធីណា?

ឃ.តើចំណូលរបស់រដ្ឋាភិបាលមានប៉ុន្មានប្រភេទ? អ្វីខ្លះ? ចូររៀបរាប់និងពន្យល់។

ង. ដូចម្តេចហៅថាតុល្យភាពចំណាយ និងចំណូល?ចូរពន្យល់។

ច. តើមានគោលនយោបាយអ្វីខ្លះ ក្នុងវិស័យសេដ្ឋកិច្ច។

ឆ. សេវាកម្មសាធារណៈតែងផ្ដត់ផ្គង់ដោយសារពើពន្ធ។ តើសារពើពន្ធមានឥទ្ធិពលបែបណាចំពោះ សកម្មភាពការងារឬកាសន្សំប្រាក់របស់បុគ្គល ក្រុមហ៊ុន ឬ សហគ្រាសឯកជន។

ចម្លើយ

2 ក.បានជារដ្ឋាភិបាលគ្រប់ប្រទេសត្រូវការចំណាយ ពីព្រោះរដ្ឋាភិបាលនៃប្រទេសនីមួយៗចាំបាច់ត្រូវទិញសម្ភារៈ ទំនិញនានា ព្រមទាំងធ្វើការកសាង និងស្ដាបនាប្រទេស និងចំណាចលើប្រាក់ខែមន្ត្រីរាជការ។

ខ.ការចំណាយរបស់រដ្ឋាភិបាលមាន៣ប្រភេទគឺ:

- ចំណាយជាមូលធនៈ ចំណាយជាមូលធនគឺជាចំណាយលើការទិញទ្រព្យសម្ភារៈ ការស្ដាបនាហេដ្ឋារចនាសម្ព័ន្ធមានសំណង់អាគារ ផ្លូវថ្នល់ ប្រឡាយទឹកជាដើម រួមទាំងការអនុវត្តគម្រោងកម្មវិធី អភិវឌ្ឍផ្សេងៗដែលជាការវិនិយោគ សាធារណៈ និងចំណាយលើការរំលស់បំណុល។
- ចំណាយតាមច្បាប់ហិរញ្ញវត្ថុៈ ច្បាប់ហិរញ្ញវត្ថុត្រូវបាន

រៀបចំឡើងដើម្បីធានាឱ្យមានតុល្យភាពរវាងចំណូលនិងចំណាយ។តុល្យភាពរវាងសកម្មភាពក្នុងវិស័យផ្សេងៗ និងធានាឱ្យគ្រប់ចំណាយរបស់ រដ្ឋាភិបាលមានប្រសិទ្ធភាពក្នុងការផ្តល់ផលប្រយោ ជន៍ប្រកបដោយសមធម៌ដល់ប្រជាពលរដ្ឋ តួយ៉ាង ដូចជាគិតតាំងពីចំណាយលើការកសាងបណ្ណាល័យ និងចង្កៀងបំភ្លឺតាមផ្លូវសាធារណៈឡើងទៅ។

- ចំណាយចរន្តៈចំណាយចរន្តគឺជាចំណាយលើសេវាទាំងឡាយ ដើម្បីទ្រទ្រង់យន្តការការពារនិងស្ថាបនាជាតិ។ចំណាយចរន្តត្រូវបានប្រើប្រាស់ទៅលើប្រាក់បៀវត្សបុគ្គលិកមន្ត្រីរាជការ និងទៅលើសេវាកម្ម ពិសេសៗដទៃទៀតដែលបម្រើកិច្ចការសាធារណៈ មានដូចជាសេវាកម្មក្នុងកម្មវិធីអប់រំ កម្មវិធីសុខាភិបាល ការផ្តល់សិទ្ធិសំខាន់ៗក្នុងវិស័យសន្តិសុខសង្គមជាដើម។

គ.រដ្ឋាភិបាលរកចំណូលបានមកពីការប្រមូលពន្ធរួមផ្សំនឹងការប្លុកបញ្ចូលជំនួយផ្សេងៗពីសហគមន៍អន្តរជាតិ។

ឃ.ចំណូលរបស់រដ្ឋាភិបាលមាន២ប្រភេទគឺ:

- ចំណូលចរន្តៈចំណូលចរន្ត ជាប្រាក់ចំណូលដែលប្រមូលបានតាមរយៈការយកពន្ធនិងអាករនៅក្នុងដំណើរ សកម្មភាពសេដ្ឋកិច្ចមានដូចជា កាផលិតការជួល ការលក់ ការធ្វើសម្បទាន និងសេវាកម្ម។
- ចំណូលជាមូលធនៈចំណូលជាមូលធនសំដៅលើប្រាក់ចំណូលពីការលក់សម្បត្តិរដ្ឋ ពីការផ្តល់អំនោយ ឬការ ផ្តល់កម្ចីអំពីសហគមន៍អន្តរជាតិដែលត្រូវបានបម្រុងទុកដើម្បីការវិនិយោគសាធារណៈ ការសន្សំ ការផ្ទេរជាផ្លូវ ការដើម្បីទូទាត់កង្វះខាតក្នុងចំណាយចរន្តនិងការរលស់បំណុល។

ង. តុល្យភាពចំណាយនិងចំណូលគឺជាភាពស្មើគ្នា ឬប្រហាក់ប្រហែលគ្នារវាងចំណាយ និងចំណូល។

ច. ក្នុងវិស័យសេដ្ឋកិច្ចមានគោលនយោបាយដូចជា៖

- គោលនយោបាយសវនកម្មជាតិ: ណែនាំការអនុវត្តកម្មវិធីសវនកម្មជាតិ។
- គោលនយោបាយពន្ធ: គិតគូរអំពីការផ្លាស់ប្តូរពន្ធ

កំណែទម្រង់ពន្ធ ឬការបញ្ចុះតម្លៃពន្ធសំខាន់ៗ។

- គោលនយោបាយមីក្រូសេដ្ឋកិច្ច: សង្កត់ធ្ងន់លើវិធានការមីក្រូសេដ្ឋកិច្ច ដើម្បីបង្កើនផលិតភាព និងប្រសិទ្ធភាពសេដ្ឋកិច្ចទាំងមូល។
- គោលនយោបាយទង្វើសេដ្ឋកិច្ច: បម្រើការរីកលូតលាស់នៃការផ្គត់ផ្គង់រូបិយវត្ថុប្រចាំឆ្នាំ ត្រួតពិនិត្យអត្រាការបាត់បង់អាជីព អត្រាអតិផរណា ការលូតលាស់ផលិតកម្ម អត្រាប្រាក់សន្សំរបស់បុគ្គល។
- គោលនយោបាយថវិកា: កំណត់ការចំណាយថវិការដ្ឋ ការប្រមូលពន្ធ និងវិធានការដោះស្រាយឱនភាពថវិការដ្ឋ។
- គោលនយោបាយសារពើពន្ធ: ចែងអំពីការពិនិត្យឱ្យបានល្អិតល្អន់ទាំងការយកពន្ធ ទាំងឥទ្ធិពលនៃការយកពន្ធនិងទាំងកម្មវិធីចំណាយរបស់រដ្ឋាភិបាល។
- គោលនយោបាយកំណែទម្រង់ហិរញ្ញវត្ថុ:រៀបចំកំណែទម្រង់ដើម្បីបង្កើនប្រសិទ្ធភាពការងារហិរញ្ញវត្ថុ

ឆ. សេវាកម្មសាធារណៈតែងផ្គត់ផ្គង់ដោយសារពើពន្ធ។ ចំពោះសកម្មភាពការងារបឬការសន្សំប្រាក់របស់បុគ្គល ក្រុមហ៊ុន ឬសហគ្រាសឯកជន សារពើពន្ធមានឥទ្ធិពលលើកម្រិតនៃការសន្សំរបស់បុគ្គល ក្រុមហ៊ុន ឬសហគ្រាស ពោលគឺអត្រាពន្ធកើនឡើង នោះកម្រិតសន្សំថយចុះ ប៉ុន្តែអត្រាពន្ធថយចុះ នោះកម្រិតសន្សំកើនឡើង។



# មេរៀនទី៨

## ជាតូបនីយកម្មនិងឯកជនូបនីយកម្ម

?សំណួរ

2. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬជាក្រុមដើម្បីដោះស្រាយនូវសំណួរខាងក្រោម

ក.ជាតូនីយកម្មជាទូទៅច្រើនគ្រប់គ្រងនិងដឹកនាំដូចម្តេច?

ខ. ហេតុអ្វីបានជាគេធ្វើជាតូនីយកម្មក្នុងប្រទេសកំពុង អភិវឌ្ឍ?

គ. តើលទ្ធផលនៃការអនុវត្តកម្មវិធីឯកជនភាវូបនីយកម្មក្នុងប្រទេសអភិវឌ្ឍច្រើនទទួលបានលទ្ធផលដូចម្តេច?

ឃ.ចូរធ្វើការប្រៀបធៀបពីលទ្ធផលនៃការអនុវត្តកម្មវិធីឯកជនភាវូបនីយកម្មក្នុងប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍ។តើមានលក្ខណៈខុសគ្នាដូចម្តេច?

---

# ចម្លើយ

2.ក.ជាគំរូមនីយកម្មជាទូទៅច្រើនគ្រប់គ្រងនិងដឹកនាំដោយបង្វិលសហគ្រាស ឬសាខាផលិតកម្មនៃកម្មសិទ្ធិឯកជនឱ្យទៅជាកម្មសិទ្ធិរបស់រដ្ឋ។

ខ. បានជាគេធ្វើជាតូបនីយកម្មក្នុងប្រទេសកំពុងអភិវឌ្ឍព្រោះជាតូបនីយកម្មដើម្បីប្រឆាំងនឹងរបបលក់ផ្ដាច់មុខរបស់បរទេស ឬប្រឆាំងនឹងនយោបាយអាណានិគមនិយមបែបថ្មី។ជាតូបនីយកម្មនឹងមានប្រសិទ្ធភាពទៅបានលុះត្រាតែរដ្ឋមានលទ្ធភាពនិងសមត្ថភាពគ្រប់គ្រាន់ ក្នុងការគ្រប់គ្រងសហគ្រាស ឬសាខាផលិតកម្មនោះឱ្យមានដំណើរការល្អប្រសើរ និងមានការរីកចម្រើនដោយស្របគ្នានឹងការអភិវឌ្ឍជាតិ។

គ. លទ្ធផលនៃការអនុវត្តកម្មវិធីឯកជនភាវូបនីយកម្មក្នុងប្រទេសអភិវឌ្ឍច្រើនទទួលបានលទ្ធផលជោគជ័យយ៉ាងខ្លាំង ដែលមានចំណុចដូចជា:

- ធនធានមនុស្សគ្រប់គ្រាន់តាមតម្រូវការនៃជំនាញ។
- រដ្ឋមានទិសដៅច្បាស់លាស់មានគោលនយោបាយ

ជាយុទ្ធសាស្ត្រសមស្រប។

- ប្រព័ន្ធគណនេយ្យធនាគារមានលក្ខណៈទូលំទូលាយ និងមានច្បាប់លិខិតបទដ្ឋានត្រឹមត្រូវ។
- ហិរញ្ញវត្ថុមានសក្តានុពល។

ឃ.ធ្វើការប្រៀបធៀបពីលទ្ធផលនៃការអនុវត្តកម្មវិធីឯកជនភាវូបនីយកម្មក្នុងប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍគឺ៖

- ប្រទេសកំពុងអភិវឌ្ឍ គឺកំពុងឆ្លងពីសេដ្ឋកិច្ចបែបផែនការមកជាសេដ្ឋកិច្ចទីផ្សារ គោលដៅចម្បងរបស់ប្រទេសទាំងនោះ គឺជាការលើកកម្ពស់ជំនាញឯកទេសនិងការបង្កើតមូលដ្ឋានប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ។
- ប្រទេសអភិវឌ្ឍ មានដូចជាអឺរ៉ុបខាងលិច អាមេរិចខាងជើងនិងជប៉ុន គោលបំណងសំខាន់ក្នុងការអនុវត្តកម្មវិធីឯកជនភាវូបនិយកម្មគឺជាការធ្វើឱ្យមានបច្ចេកវិទ្យាកាន់តែទំនើបនិងឱ្យមានចំណូលកាន់តែច្រើន។

# មេរៀនទី៩

## ពលកម្មនិងប្រាក់បៀវត្ស

### ?សំណួរ

2. ចូរអ្នកធ្វើការពិភាក្សាក្នុងក្រុម ឬជាមួយដៃគូដើម្បីដោះស្រាយសំណួរខាងក្រោម

ក. ដូចម្ដេចហៅថា ពលកម្ម? ចូរពន្យល់ដោយលំអិត។

ខ. ដូចម្ដេចហៅថាកម្លាំងពលកម្ម?ចូរពន្យល់ដោយលំអិត។

គ. ដូចម្ដេចហៅថាប្រាក់បៀវត្ស?

ឃ.នៅក្នុងសង្គមទូទៅហេតុអ្វីបានជាមានអ្នកចូលធ្វើការងារដែលមានតម្លៃឈ្នួលថោក?

## ចម្លើយ

2.ក.ពលកម្ម គឺជាសកម្មភាពប្រកបដោយមនសិការ ឬប្រកបដោយវិចារណញ្ញាណរបស់មនុស្ស សំដៅបំប្លែងកម្មវត្ថុណាមួយឱ្យទៅជាវត្ថុឬសម្ភារៈ ដែលបម្រើសេចក្តីត្រូវការរបស់ខ្លួន ដូចជាទំនិញជាដើម។ដោយសារពលកម្ម មនុស្សអាចវិវឌ្ឍចេញពីពិភពនៃសត្វនិង អាចគ្រប់គ្រងនិងប្រើប្រាស់ធម្មជាតិ ដើម្បីបម្រើប្រយោជន៍របស់ខ្លួន។ឆ្លងតាមបទពិសោធន៍ដ៏ច្រើន មនុស្សបានកែច្នៃធម្មជាតិធ្វើជាឧបករណ៍ពលកម្ម និងបានអភិវឌ្ឍសម្បទានិងចំណេះដឹងទាំងឡាយរបស់ខ្លួន។ពលកម្មទាំងអស់នេះរួមគ្នាជំរុញឱ្យសង្គមមានការរីកចម្រើន។ ដំណើរការពលកម្មមានធាតុបី:

- កម្មវត្ថុពលកម្ម គឺអ្វីៗដែលមនុស្សយកទៅកែច្នៃ ឱ្យទៅជាផលិតផលថ្មី ដូចជាវត្ថុដែលមានស្រាប់ក្នុងធម្មជាតិ (ដី ព្រៃឈើ ត្រី...)និងវត្ថុដែលឆ្លងកាត់ពលកម្មកែច្នៃ (ដែក អំបោះ...)។
- សកម្មភាពសនិទានរបស់មនុស្សពោលគឺពលកម្ម

ខ្លួនឯង។

- សកម្មភាពសនិទានរបស់មនុស្សពោលគឺពលកម្ម ខ្លួនឯង។
- មធ្យោបាយពលកម្ម គឺជាសម្ភារៈទាំងឡាយដែលមនុស្សប្រើប្រាស់ទៅលើកម្មវត្ថុពលកម្ម មានដូចជា ដែកឈូស ពូថៅ គ្រឿងម៉ាស៊ីន។

ខ. កម្លាំងពលកម្ម សំដៅលើមនុស្សអ្នកធ្វើពលកម្ម ឬផ្តល់សេវាកម្ម មានដូចជា ពលករ កម្មករ និយោជិក។ ក្នុងករណី ដែលកម្លាំងពលកម្មមានជំនាញ មានបច្ចេកទេស សម្រាប់ធ្វើការងារក្នុងឧស្សាហកម្ម ឬក្នុងស្ថាប័ននានា ដែលប្រើបច្ចេកទេសទាន់សម័យ គេហៅថា ធនធានមនុស្ស។

គ. ប្រាក់បៀវត្សគឺជាប្រាក់ថ្លៃឈ្នួលពលកម្ម ដែល បុគ្គលិក ឬកម្មករទទួលបានជាប្រចាំក្នុងអំឡុងពេល ដែលគេកំពុងបំពេញការងារនៅតាមគ្រឹះស្ថាន ឬ ក្រុមហ៊ុនណាមួយ។

ឃ.បានជាមានអ្នកចូលធ្វើការងារដែលមានតម្លៃឈ្នួល

ផោកពីព្រោះក្នុងទីផ្សារប្រកួតប្រជែងដែលមានទូទៅក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍ ប្រាក់បៀវត្សខ្ពស់មិនមានន័យថាមាននិកម្មភាពខ្ពស់ឡើយ។ ម៉្យាងទៀតនៅ ពេលដែលបង្កើនថ្លៃដើមពលកម្ម (ប្រាក់បៀវត្ស) សហគ្រាសនឹងព្យាយាមប្រើប្រាស់កម្លាំងពលកម្មឱ្យមាន ប្រសិទ្ធភាពខ្ពស់ផងដែរ។

---

មេរៀនទី១០

## ភាពគ្មានការងារធ្វើ

?សំណួរ

២. ចូរអ្នកធ្វើការពិភាក្សាក្នុងក្រុម ឬជាមួយដៃគូ ដើម្បីដោះស្រាយនូវសំណួរខាងក្រោម

ក. តើភាពគ្មានការងារធ្វើជាអ្វី?

ខ. តើភាពគ្មានការងារធ្វើដោយចេតនាខុសពីភាពគ្មាន

ការងារធ្វើដោយអចេតនាដូចម្តេច?

គ. តើភាពគ្មានការងារធ្វើចែកចេញជាប៉ុន្មានប្រភេទ? អ្វីខ្លះ?

ឃ.តើភាពគ្មានការងារធ្វើធ្វើឱ្យមានផលប៉ះពាល់អ្វីខ្លះ នៅក្នុងសង្គមសេដ្ឋកិច្ច?

---

ចម្លើយ

2.ក.ភាពគ្មានការងារធ្វើគឺអវត្តមាននៃការប្រើប្រាស់កម្លាំងពលកម្មដែលមានឬស្ថានភាពដែលមនុស្សគ្មានមុខរបរ។

ខ. ភាពគ្មានការងារធ្វើដោយចេតនាខុសពីភាពគ្មានការងារធ្វើដោយអចេតនាត្រង់៖

- ភាពគ្មានការងារធ្វើដោយអចេតនា: កើតមានឡើងចំពោះមនុស្សមានសមត្ថភាពពេញលេញគ្រាប់គ្រាន់ ប៉ុន្តែគេមិនអាចរកការងារធ្វើបាន។
- ភាពគ្មានការងារធ្វើដោយចេតនាគឺជាភាពទំនេរដែលកើតឡើងនៅពេលមនុស្សមិនព្រមទទួលយកការងារដែលពួកគេអាចធ្វើបាន ដោយពួកគេ

សង្ឃឹមថានឹងរកបានការងារថ្មីមួយទៀតដែលទទួលបានផលប្រយោជន៍ច្រើនជាង។ ជួនកាលមនុស្សបោះបង់ការងារមួយចោល ហើយស្វែងរកការងារផ្សេងមួយទៀត ឬសម្រេចចិត្តលាឈប់ពីការងារដែលពួកគេកំពុងធ្វើ ដោយសារការងារនោះទទួលបានប្រាក់ កម្រៃទាបពេក។កត្តានេះធ្វើឱ្យមនុស្សមួយចំនួននោះក្លាយជាអ្នកអត់ការធ្វើ ហើយដែលអ្នកសេដ្ឋកិច្ច ចាត់ទុកក្រុមប្រភេទនេះជាអ្នកអត់ការងារធ្វើដោយចេតនា។

គ. ភាពគ្មានការងារធ្វើចែកចេញជា៤ប្រភេទគឺ៖

- ភាពគ្មានការងារធ្វើដោយរចនាសម្ព័ន្ធ
- ភាពគ្មានការងារធ្វើដោយប៉ះទង្គិច
- ភាពគ្មានការងារធ្វើតាមកាល
- ភាពគ្មានការងារធ្វើតាមខួប

ឃ.ភាពគ្មានការងារធ្វើ ធ្វើឱ្យមានផលប៉ះពាល់ដល់ សង្គមសេដ្ឋកិច្ចដូចជា:

- ការបង់បាត់ធនធានមនុស្ស:ភាពគ្មានការងារធ្វើ

ធ្វើឱ្យមនុស្សបាត់បង់នូវជំនាញដែលពួកគេទទួលបានពីការបណ្តុះបណ្តាល។

- ភាពលំបាកវេទនារបស់ជនដែលគ្មានការងារធ្វើ៖ ជន ដែលគ្មានការងារធ្វើ ធ្វើឱ្យថយចុះនូវលទ្ធភាពផលិត ទំនិញនិងសេវាកម្ម ដែលផ្តល់ផលប៉ះពាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច។
- ការបាត់បង់ផលិតផលការងារនិងចំណូលរបស់ពលរដ្ឋ៖គឺជាផលប៉ះពាល់ដ៏ធំមួយ ដែលនឹងបង្កើតឱ្យមានផលប៉ះពាល់ផ្សេងទៀតជាច្រើន។

# មេរៀនទី១១

## វិបត្តិសេដ្ឋកិច្ច

?សំណួរ

2.ចូរអ្នកពិភាក្សាជាមួយដៃគូ ឬជាមួយសិស្សក្នុងថ្នាក់ដើម្បីឆ្លើយនឹងសំណួរខាងក្រោម

ក. ដូចម្តេចហៅថាវិបត្តិសេដ្ឋកិច្ច?

ខ. តើវិបត្តិសេដ្ឋកិច្ចកើតឡើងដោយបញ្ហាអ្វីខ្លះ?

គ. តើអ្នកណាជាអ្នកមានសមត្ថកិច្ចធ្វើអន្តរាគមន៍ដោះស្រាយវិបត្តិសេដ្ឋកិច្ច? ដោះស្រាយដោយវិធីណាខ្លះ?

ឃ.បច្ចុប្បន្ន តើប្រទេសកម្ពុជាមានបញ្ហាវិបត្តិសេដ្ឋកិច្ចដែរឬទេ? តើវិបត្តិនេះ កើតមានឡើងដោយសារអ្វី?

# ចម្លើយ

2.ក.វិបត្តិសេដ្ឋកិច្ច គឺជាការរងឥទ្ធិពលវិបត្តិហិរញ្ញវត្ថុដែលបណ្ដាលមកពីវិបត្តិបរិស្ថាន អស្ថេរភាពនយោបាយ ឬការរីកចម្រើនដល់កំពូលនៃការងារ ផលិតកម្មដែលនាំឱ្យមានផលិតផលលើស។

ខ. វិបត្តិសេដ្ឋកិច្ចកើតឡើងដោយបញ្ហាមួយចំនួនដូចជា៖

- ✓ គ្រោះធម្មជាតិ: មានដូចជា ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី បន្ទុះភ្នំភ្លើង ការរាំងស្ងួត។
- ✓ វិបត្តិវប្បធម៌: សំដៅលើការប្រកាន់យកឥរិយាបថអវិជ្ជមានរបស់ប្រជាពលរដ្ឋមួយចំនួនដែល ជាមូលហេតុនាំឱ្យរាំងស្ទះដល់ការលើកកម្ពស់សេដ្ឋកិច្ចរបស់បុគ្គលនិងគ្រួសារខ្លួនឯង ដែលជះឥទ្ធិពលលើការលើកកម្ពស់សេដ្ឋកិច្ចជាតិ។
- ✓ វិបត្តិផលិតផលលើស: បណ្ដាលមកពីផលិតផលមានកំណើនលើសពីសេចក្ដីត្រូវការរបស់ទីផ្សារ ដែលនាំឱ្យមានការធ្លាក់ចុះទាំងស្រុងនៃដំណើរផលិតកម្មដែលអាចបណ្ដាលឱ្យមានការ ថយចុះ

ការវិនិយោគទុន ការកើនឡើងនៃភាពគ្មានការងារធ្វើ ការបាត់បង់ប្រាក់ចំណូលរបស់សហគ្រាស នានា ការធ្លាក់ចុះនៃអត្រាប្រាក់ហ៊ុន និងកំណើនអតិផរណា។

✓ វិបត្តិកសិកម្ម: បណ្តាលមកពីមានកំណើនកសិកផលលើសពីសេចក្តីត្រូវការរបស់ទីផ្សារនៅក្នុងបណ្តាប្រទេសជឿនលឿន។វាស្តែងឡើងជាដំបូងដោយការប្រមូលផ្តុំនៃការស្តុកទុកយ៉ាងធំនៃកសិផលដែលមិនអាចលក់ចេញបាន។ មូលហេតុនៃវិបត្តិកសិកម្មគឺបណ្តាលមកពីកង្វះការស្រាវជ្រាវទីផ្សារ។

✓ វិបត្តិក្នុងការគ្រប់គ្រងថវិការដ្ឋ: មានន័យថា រដ្ឋមានកង្វះខាតក្នុងការគ្រប់គ្រងហិរញ្ញវត្ថុឱ្យបានសមស្របបណ្តាលឱ្យមានការចំណាយដ៏ធំជាងចំណូលដែលរកបាន។

✓ វិបត្តិនយោបាយ: មានដូចជា សង្គ្រាម ការប្រកាន់យកលទ្ធិផ្តាច់ការ របបប្រល័យពូជសាសន៍ ឬ

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

✓ វិបត្តិបរិស្ថាន: គឺការខូតបរិស្ថាននៃប្រទេសអភិវឌ្ឍនានា ដែលបណ្តាលមកពីការបំផ្លិចបំផ្លាញប្រកបដោយព្យសនកម្មដែលមិនអាចប្រកែតបាន ឬដែលពិបាកនឹងជួសជុលបាន។ ការបំផ្លិចបំផ្លាញកើតមកពីការធ្វើអាជីវកម្មជ្រុសហួស ការខ្ជះខ្ជាយឬការបន្លំលួច ធនធានធម្មជាតិទាំងឡាយដោយពួកក្រុមហ៊ុនផ្តាច់មុខធំៗនិងបង្កើនធនធានម្ហូបអាហារ និងកំណើននៃផលិតកម្ម ឧស្សាហកម្ម។ វិបត្តិបរិស្ថានជាការស្តែង ចេញនូវគុណវិបត្តិរបស់បណ្តាប្រទេសដែលមានការរីកចម្រើនមិនសមស្របខាងផ្នែកផលិតកម្មដែលជាកត្តាជះឥទ្ធិពលទៅលើវិស័យសេដ្ឋកិច្ច។

✓ វិបត្តិរូបិយវត្ថុ: គឺការបាត់លំនឹងទូទាត់យ៉ាងធ្ងន់ធ្ងរនៃប្រព័ន្ធហិរញ្ញវត្ថុក្នុងនិងក្រៅប្រទេស។វិបត្តិនេះមានឥទ្ធិពលលើវិបត្តិសេដ្ឋកិច្ច និងទំនាស់ទាំងឡាយក្នុងសង្គម។ វិបត្តិរូបិយវត្ថុមានពីរយ៉ាងគឺទី១

វាជាបាតុ ភូតកើតមានជាប្រចាំសម្រាប់យុគសម័យនៃ វិបត្តិសេដ្ឋកិច្ចទូទៅដែលជាការលុបបំបាត់ចោលនូវខ្ទាតមាសសម្រាប់រូបិយវត្ថុ ឬទី២ វាជាការធ្លាក់ចុះដុនដាប នៃស្ថានភាពរូបិយវត្ថុមួយចំនួនដែលមិនអាចផ្តោះប្តូរបានដោយសារអតិផរណា។

✓ វិបត្តិថាមពលៈជាវិបត្តិសេដ្ឋកិច្ចមួយនៅក្នុងចំណោមវិបត្តិសេដ្ឋកិច្ចទាំងឡាយ ប៉ុន្តែមិនមានលក្ខណៈជាខួបទេ។ វិបត្តិនេះ បានផ្ទុះឡើងនៅចុងឆ្នាំ ១៩៧៣។ វាស្តែងឡើងជាដំបូងដោយការខ្វះខាតធនធាន ថាមពល បន្ទាប់ពីមានការកើនឡើងយ៉ាងឆាប់រហ័ស នៃតម្លៃប្រេងកាតដែលជាផលិតផលថាមពលសំខាន់នៅសម័យបច្ចុប្បន្ន។

គ.អ្នកមានសមត្ថកិច្ចធ្វើអន្តរាគមន៍ ដោះស្រាយវិបត្តិសេដ្ឋកិច្ចមានដូចជា:

- ប្រទេសកំពុងអភិវឌ្ឍ: ជាទូទៅបណ្តាប្រទេសកំពុងអភិវឌ្ឍច្រើនជាប្រទេសដែលធ្លាប់ បានរងគ្រោះដោយការដាក់អាណានិគមអំពីសំណាក់ ប្រ

ទេសអាណាព្យាបាល។ស្ថិតក្នុងភាពជាប្រទេស ក្រោមអាណានិគម រដ្ឋាភិបាលមិនមានសេរីភាព ក្នុងការជំរុញការសិក្សារបស់ប្រជាពលរដ្ឋខ្លួនឡើយ ។ដូចនេះហើយ ទោះបីទទួលបានឯករាជ្យភាពជា យូរឆ្នាំមកហើយក្តី ក៏ប្រទេសកំពុងអភិវឌ្ឍនៅមាន ដឹតដាមបញ្ហាខ្វះខាតច្រើនបង្គួរ ក្នុងនោះមានបញ្ហា វិបត្តិវប្បធម៌ជាដើម។ដោយសារវិបត្តិនេះគេអាច និយាយបានថាគ្រប់ប្រទេសកំពុងអភិវឌ្ឍជាប្រ ទេសក្រីក្រ ឬជាប្រទេសកំពុងដោះស្រាយវិបត្តិ សេដ្ឋកិច្ច។ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយក្នុងយុគ សម័យសកលភាវូបនីយកម្មនេះ ប្រទេសកំពុង អភិវឌ្ឍមិនស្ថិតនៅជាប្រទេសឯកោទេពោលគឺមាន ការជួយឧបត្ថម្ភពីបណ្តាប្រទេសអភិវឌ្ឍ។

- នៅប្រទេសអភិវឌ្ឍៈ ជាទូទៅបណ្តាប្រទេសអភិវឌ្ឍ នានាការរីបន្តឹងឱ្យប្រជាពលរដ្ឋមានការសិក្សាខ្ពស់ និងចូលរួមលើកកម្ពស់វប្បធម៌អរិយធម៌ជឿនលឿន ត្រូវបានចាត់ទុកជាវិស័យអាទិភាព។ បន្ទាប់ពីនេះ

រដ្ឋបានដើរតួជាអ្នកបញ្ជា និងទប់ស្កាត់បាតុភាពអវិជ្ជមានដែលកើតមានក្នុងសេដ្ឋកិច្ចទីផ្សារ មានដូចជាការប្រកាន់ភាពម៉ឺងម៉ាត់ ត្រឹមត្រូវ មានតម្លាភាព គណនេយ្យភាពក្នុងការប្រមូលពន្ធដារ អាករ និងចំណូលគ្រប់ប្រភេទដើម្បីបង្កើនសេដ្ឋកិច្ចជាតិ ការកំណត់ថ្លៃពន្ធខ្ពស់ចំពោះទំនិញគ្រឿងស្រវឹង ទប់ស្កាត់ភាពផ្ដាច់មុខក្នុងពាណិជ្ជកម្ម ត្រួតពិនិត្យឱ្យមានការដាក់បង្ហាញថ្លៃលក់ទំនិញគ្រប់ប្រភេទ ចូលរួមសិក្សានិងផ្ដល់ព័ត៌មានអំពីទីផ្សារជាដើម។

ឃ. បច្ចុប្បន្ន ប្រទេសកម្ពុជាមានបញ្ហាវិបត្តិសេដ្ឋកិច្ចខ្លះៗ ដូចជា:

- ដោយបានទទួលរងឥទ្ធិពលវិបត្តិហិរញ្ញវត្ថុសកលលោកកំណើនសេដ្ឋកិច្ចជាតិកម្ពុជាបានធ្លាក់ចុះពី 6%នៅឆ្នាំ ២០០៨ នៅត្រឹម3%នៅឆ្នាំ ២០០៩ ប៉ុន្តែតួលេខនេះបញ្ជាក់ឱ្យឃើញថាសេដ្ឋកិច្ចជាតិកម្ពុជានៅតែមានកំណើននៅឡើយ។
- នៅដើមឆ្នាំ២០០៩ ឥទ្ធិពលវិបត្តិហិរញ្ញវត្ថុសកល

លោកបានធ្វើឱ្យសកម្មភាពសេដ្ឋកិច្ចមួយចំនួនជាប់គាំងបង្កឱ្យមានការថយចុះពាណិជ្ជកម្មអន្តរជាតិការ បាត់បង់ការងារធ្វើ និងការថយចុះចំណូលជាតិជាដើម។ប្រការនេះបានធ្វើឱ្យវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជានៅតែបន្តរងផលប៉ះពាល់ ជាពិសេសនយោបាយហិរញ្ញវត្ថុសាធារណៈក្នុងការអនុវត្តចំណូល និងចំណាយថវិការរដ្ឋ។

ឧឧឧឧ៚៙៙៙៙



# មេរៀនទី១២

## កម្មវិធីជាតិសម្រាប់នីតិសម្បទាននិងអភិវឌ្ឍន៍

?សំណួរ

2. ចូរអ្នកធ្វើការស្រាវជ្រាវនិងពិភាក្សាជាមួយដៃគូ ឬសមាជិកដទៃទៀតក្នុងក្រុមដើម្បីដោះស្រាយសំណួរខាងក្រោម

ក. តើកម្មវិធីជាតិ សម្រាប់នីតិសម្បទាននិងអភិវឌ្ឍន៍មានន័យយ៉ាងដូចម្ដេច?

ខ. តើការរៀបចំកម្មវិធីជាតិ សម្រាប់នីតិសម្បទាននិងអភិវឌ្ឍន៍ត្រូវគោរពលក្ខខណ្ឌអ្វីខ្លះ?

គ. តើខ្លឹមសារសំខាន់ៗដែលត្រូវមាននៅក្នុងកម្មវិធីជាតិសម្រាប់នីតិសម្បទា និង អភិវឌ្ឍន៍មានចំនួនប៉ុន្មាន? អ្វីខ្លះ?

ឃ. ដើម្បីទាក់ទាញការវិនិយោគ តើរដ្ឋត្រូវយកចិត្តទុកដាក់លើបញ្ហាអ្វីខ្លះ?

ង. តើហេតុអ្វីបានជារដ្ឋត្រូវយកចិត្តទុកដាក់លើការអភិវឌ្ឍជនបទ?

ច. តើយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាលមានផ្អែកលើលក្ខណខណ្ឌនៃការរៀបចំដែរឬទេ? ចូរបង្ហាញ។

---

ចម្លើយ

2.ក.កម្មវិធីជាតិ សម្រាប់នីតិសម្បទាននិងអភិវឌ្ឍន៍ ជាកម្មវិធីរបស់រដ្ឋាភិបាលរៀបចំឡើងក្នុងគោលបំណងធានាការមានសិទ្ធិគ្រប់គ្រាន់តាមផ្លូវច្បាប់ស្តារនិងអភិវឌ្ឍប្រទេសតាមមាគ៌ានយោបាយដែលមានចែងក្នុងច្បាប់។

ខ. ការរៀបចំកម្មវិធីជាតិ សម្រាប់នីតិសម្បទានិងអភិវឌ្ឍត្រូវគោរពលក្ខខណ្ឌះភាពប្រទាក់ក្រឡា ស៊ីសង្វាក់ និងគ្រប់ជ្រុងជ្រោយ ដែលក្នុងនោះមានការទាក់ទិនទៅនឹងរាល់បណ្តាផ្នែកសំខាន់ៗនៃសេដ្ឋកិច្ចនិងមជ្ឈដ្ឋានអស្ថិរភាពរបស់ប្រព័ន្ធសេដ្ឋកិច្ចទាំងមូល (ប្រព័ន្ធនយោបាយ ច្បាប់ បែបបទ និងរចនាសម្ព័ន្ធរដ្ឋបាល ហេដ្ឋារចនា សម្ព័ន្ធជារូបវន្ត ការបណ្តុះបណ្តាលធនធានមនុស្ស)។កម្មវិធីនេះ ត្រូវបានរៀបចំជាមធ្យោបាយ

សម្រាប់អនុវត្តដោយកំណត់ថា អ្នកណាជាអ្នកអនុវត្ត ពេលវេលាអនុវត្តដើម្បីអភិវឌ្ឍតាមទិសដៅដែលបានគ្រោងទុក។

គ. ខ្លឹមសារសំខាន់ៗដែលត្រូវមាននៅក្នុងកម្មវិធីជាតិសម្រាប់នីតិសម្បទា និង អភិវឌ្ឍន៍មានចំនួន៦គឺ៖

- នយោបាយម៉ាក្រូសេដ្ឋកិច្ចនិងការកែលំអ ខាងផ្នែកលិខិតបទដ្ឋាននិងរចនាសម្ព័ន្ធរដ្ឋបាលមានទាក់ទិនជុំវិញបញ្ហានយោបាយ ឥណទាន រូបិយវត្ថុ ពាណិជ្ជកម្ម អតិផរណា ការងារអាជីព ព្រមទាំងបញ្ហាផ្សេងទៀតដែលធ្វើឱ្យមានសុក្រិតភាពក្នុងប្រព័ន្ធច្បាប់នឹងប្រព័ន្ធរដ្ឋបាលជាដើម។
- រដ្ឋមានតួនាទីជាអ្នកគ្រប់គ្រងអ្នករៀបចំសម្របសម្រួល និងត្រួតពិនិត្យការអនុវត្តកម្មវិធីជាតិនីតិសម្បទានិងអភិវឌ្ឍន៍។
- ការកសាងនិងអនុវត្តគោលនយោបាយរបស់រដ្ឋក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធជារូបវន្តមានដូចជាមធ្យោបាយដឹកជញ្ជូន គមនាគមន៍ ថាមពល ការ

គ្រប់គ្រង និងអភិវឌ្ឍន៍បរិស្ថានព្រមទាំងសកម្មភាពពាក់ព័ន្ធផ្សេងៗទៀត។

- ការកសាងនិងអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជនបទដែលមានគោលដៅដោះស្រាយគម្លាតរវាងទីក្រុងនិងជនបទជួយឱ្យប្រជារាស្ត្រទូទៅមានសុខុមាលភាពនិងសន្តិសុខ។
- ការកសាងនិងអនុវត្តន៍គោលនយោបាយពាណិជ្ជកម្មនិងសហប្រតិបត្តិការអន្តរជាតិ ពោលគឺសមាហរណកម្មសេដ្ឋកិច្ចដោយភ្ជាប់ប្រព័ន្ធសេដ្ឋកិច្ចទៅនឹងប្រព័ន្ធសេដ្ឋកិច្ចពិភពលោក។
- ការកសាងធនធានមនុស្សគឺអប់រំមនុស្សឱ្យមានចំណេះដឹងចំណេះធ្វើខាងផ្នែកវិទ្យាសាស្ត្រនិងបច្ចេក វិទ្យាព្រមទាំងការផ្លាស់ប្តូរឥរិយាបថផ្សេងៗស្របតាមនិន្នាការទីផ្សារសេរីនៃពិភពអភិវឌ្ឍន៍។ ធនធាន មនុស្សជាកម្លាំងចលករនិងជាទិសដៅនៃសកម្មភាពសេដ្ឋកិច្ច។

ឃ. ដើម្បីទាក់ទាញការវិនិយោគ រដ្ឋត្រូវយកចិត្តទុកដាក់

លើបញ្ហាដូចជា:

- បញ្ហាពន្ធ(មានការលើកលែងពន្ធខ្លះ)
- បញ្ហាច្បាប់ជាតិ (គ្មានអំពើពុករលួយ គោរពសិទ្ធិមនុស្ស ...)
- បញ្ហានយោបាយ (រដ្ឋត្រូវធ្វើយ៉ាងណាត្រូវបានស្ថេរភាពនយោបាយ)
- បញ្ហាទីផ្សារលក់ផលិតផលៈត្រូវរកទីផ្សារសម្រាប់លក់ផលិតផលជាតិ។
- បញ្ហាធនធានមនុស្ស និងតម្លៃពលកម្មៈរដ្ឋត្រូវកសាងធនធាននិងយកតម្លៃពលកម្មថោកសមរម្យ។
- បញ្ហាទូរគមនាគមន៍ដូចជា ផ្លូវថ្នល់ ប្រព័ន្ធទំនាក់ទំនងផ្សេងៗ

ង. បានជារដ្ឋត្រូវយកចិត្តទុកដាក់លើការអភិវឌ្ឍជនបទ ពីព្រោះប្រជាជនកម្ពុជាភាគច្រើនរស់នៅជនបទ ហើយជីវភាពរបស់ពួកគាត់មានការលំបាកយ៉ាងខ្លាំង ប៉ុន្តែបើប្រជាជនរស់នៅជនបទមានជីវភាពធូរធារ ឬគម្លាតជីវភាពរបស់នៅរបស់ទីក្រុង និងជន

បទកាន់តែតូចៗទៅ នោះសេដ្ឋកិច្ចប្រទេសនឹងមាន
ការរីកចម្រើន ឬក្លាយនឹងក្លាយជាប្រទេសអភិវឌ្ឍ។

ច. យុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាលមានផ្អែកលើលក្ខខណ្ឌនៃការរៀបចំដែលបន្តមកពីយុទ្ធសាស្ត្រត្រីកោណដែលជាយុទ្ធសាស្ត្រ របស់រដ្ឋាភិបាលនីតិកាលទី២នៃរដ្ឋសភា ហើយដែលមានមុខងារយ៉ាងសមស្រប ក្នុងការបង្កើតបុព្វលក្ខខណ្ឌ សម្រាប់ការងើបឈរឡើងពេញជំហររបស់កម្ពុជាដោយរសារថា មានន័យធរណីមាត្រសាស្ត្រគេអាចដាក់វត្ថុដែលមានជើងបី ឬត្រីកោណ ឱ្យឈរបានគ្រប់ទីកន្លែងទាំងអស់ ទោះក្នុងស្ថានភាពណាក៏ដោយ។ចំណែកយុទ្ធសាស្ត្រចតុកោណ នេះត្រូវបានរៀបចំឡើងតាមរចនាសម្ព័ន្ធមុំបួននៃចតុកោណមានប្រទាក់ក្រឡាគ្នា ហើយផ្សារភ្ជាប់គ្នាគ្រប់ជ្រុងទាំងអស់ ដែលនៅក្នុងផ្នត់គំនិតរបស់មនុស្សទូទៅគឺតំណាងឱ្យចិរភាព និងស្ថិរភាព។ ក្នុងន័យនេះការសម្រេចបានជោគជ័យ នៅក្នុងការអនុវត្តយុទ្ធសាស្ត្រ ចតុកោណនិងនាំមកឱ្យកម្ពុជានូវ ស្ថិរភាពនឹង

ការអភិវឌ្ឍដោយចិរភាព។

---

## ?សំណួរបញ្ចប់ជំពូកទី២

I. ចូរគូសសញ្ញា ✓ក្នុងប្រអប់មុខចម្លើយណាដែលត្រឹមត្រូវ

1. ការវិភាគមីក្រូសេដ្ឋកិច្ច ជាការចាំបាច់សម្រាប់ស្វែងយល់យន្តការសំខាន់ៗរបស់

☐ក.ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ

☐ខ.ប្រព័ន្ធសេដ្ឋកិច្ចបញ្ជា

☐គ.ប្រព័ន្ធសេដ្ឋកិច្ចចម្រុះទីផ្សារ

☐ឃ.ប្រព័ន្ធសេដ្ឋកិច្ចចម្រុះផែនការ។

2. ប្រសិទ្ធភាពនៃការសម្រសម្រួលគោលនយោបាយសេដ្ឋកិច្ចស្ថិតនៅត្រង់

☐ក.លក្ខខណ្ឌសេដ្ឋកិច្ចមានអំណោយផល

☐ខ.ការផ្តល់ពត៌មានទាន់ហេតុការណ៍

☐គ.ជោគជ័យលើការអនុវត្តគោលនយោបាយសេដ្ឋកិច្ច

☐ឃ.ភាពរឹងមាំនៃរដ្ឋបាលសាធារណៈ

3. ក្នុងសេដ្ឋកិច្ចទីផ្សារសេរី ការធ្វើអន្តរាគមន៍របស់រដ្ឋមានទិសដៅ

☐ក.ជំរុញការប្រកួតប្រជែងក្នុងទីផ្សារ

☐ខ.ជួយបែងចែកទំនិញឱ្យដល់ដៃប្រជាពលរដ្ឋ

☐គ.ទប់ស្កាត់ទំនិញនាំចូល

☐ឃ.បំពេញភាពខ្វះចន្លោះនៃយន្តការទីផ្សារ។

4. ចំណាយរបស់រដ្ឋាភិបាលនៃប្រទេសនានា ត្រូវបានប្រើប្រាស់លើ

☐ក.ការពង្រីកទឹកដី

☐ខ.ការពង្រីកកម្មសិទ្ធិឯកជន

☐គ.ដើម្បីអភិវឌ្ឍប្រទេស

☐ឃ.ការបោះឆ្នោតថ្នាក់ជាតិ។

II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

1. ក្នុងការរៀបចំគោលនយោបាយផ្សេងៗ ដើម្បីលើកកម្ពស់សេដ្ឋកិច្ចជាតិ ឬជំរុញការងារផលិតកម្ម សេវាកម្មនានាគេត្រូវសិក្សាក្នុងមីក្រូសេដ្ឋកិច្ចនិង.............។

2. នៅក្នុងសង្គម រដ្ឋមានតួនាទីសំខាន់ចំនួន.................

គឺជាអ្នកបង្កើត........................ការពារសន្តិសុខជូនប្រជាពលរដ្ឋជាម្ចាស់កម្មសិទ្ធិលើ ........................ និងជាអ្នកបង្កើត រៀបចំចាត់ចែង និងគ្រប់គ្រងស្ថាប័នសម្រាប់ ............................................។

3. ក្នុងសេដ្ឋកិច្ចទីផ្សារ រដ្ឋមានតួនាទីដោយប្រយោលនិងតួនាទីដោយ ......................។តួនាទីដោយចំពោះរបស់រដ្ឋមានន័យថាជាការ....................ជាពិសេសការជំរុញកំណើនការបង្កើនផលិតផលសង្គម តាមរយៈរោងចក្រ ឬសហគ្រាសរដ្ឋដែលប្រព្រឹត្តទៅមិន នៅក្រោមឥទ្ធិពលនៃ........................................។

4. កំណើនផលិតកម្មជាកត្តាបង្កើន........................។

5. អតិផរណា ឱនភាពថវិកាកើតមាននៅពេលដែលចំណាយមានបរិមាណ ..............................ជាងចំណូល។

6. ភាពគ្មានការងារធ្វើគឺជាបន្ទុកដ៏ធ្ងន់ធ្ងរនិងមាន ...........យ៉ាងខ្លាំងដល់ ............................ទាំងមូល។

III. ចូរឆ្លើយសំណួរខាងក្រោម

1. ដូចម្តេចហៅថា ម៉ាក្រូសេដ្ឋកិច្ច? ចូរពន្យល់។

2. តើគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនៃប្រទេសនីមួយៗក្នុងពិភពលោកមានខ្លឹមសារដូចគ្នាដែរឬទេ? ហេតុអ្វី?
3. តើវិស័យណាខ្លះដែលកំណត់ការលូតលាស់នៃសេដ្ឋកិច្ចកម្ពុជា?
4. ក្នុងសេដ្ឋកិច្ចទីផ្សារតើរដ្ឋមានតួនាទីអ្វីខ្លះ?ចូររៀបរាប់។
5. ក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារត្រូវបានអនុវត្តនៅប្រទេសកំពុងអភិវឌ្ឍតើរដ្ឋត្រូវប្រកាន់យកតួនាទីអ្វីខ្លះ? ចូររៀបរាប់។
6. ដូចម្តេចហៅថាចំណូលជាតិ?តើចំណូលជាតិមានប្រភពពីណាខ្លះ?
7. តើសកម្មភាពសេដ្ឋកិច្ចរដ្ឋនិងឯកជន មានទំនាក់ទំនងនឹងគ្នាដូចម្តេច?ចូរពន្យល់។
8. ដូចម្តេចហៅថាជាតូបនីយកម្ម? តើជាតូបនីយកម្មមានប្រសិទ្ធភាព ឬអប្រសិទ្ធភាពយ៉ាងណាដល់សេដ្ឋកិច្ចជាតិ?
9. ដូចម្តេចហៅថាឯកជនូបនីយកម្ម? តើឯកជនូបនីយ

កម្មមានប្រសិទ្ធភាព ឬអប្រសិទ្ធភាពយ៉ាងណាដល់សេដ្ឋកិច្ចជាតិ?

11. ដូចម្តេចហៅថាប្រាក់បៀវត្ស? ហេតុអ្វីបានជាកម្មករភាគច្រើនត្រូវការប្រាក់បៀវត្សអប្បបរមា?

11. ដូចម្តេចហៅថាវិបត្តិសេដ្ឋកិច្ច? តើវាបង្កពីបញ្ហាអ្វី? តើអ្វីទៅជាកម្មវិធីជាតិសម្រាប់និតិសម្បទានិងអភិវឌ្ឍន៍នៅកម្ពុជា? ចូរពន្យល់។

---

## ចម្លើយ

I. ចូរគូសញ្ញា ✓ ក្នុងប្រអប់មុខចម្លើយណាដែលត្រឹមត្រូវ

1. ការវិភាគបីក្រូសេដ្ឋកិច្ច ជាការចាំបាច់សម្រាប់ស្វែងយល់យន្តការសំខាន់ៗរបស់

☑ក. ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ

2. ប្រសិទ្ធភាពនៃការសម្រសម្រួលគោលនយោបាយសេដ្ឋកិច្ចស្ថិតនៅត្រង់

☑គ. ជោគជ័យលើការអនុវត្តគោលនយោបាយសេដ្ឋកិច្ច

3. ក្នុងសេដ្ឋកិច្ចទីផ្សារសេរី ការធ្វើអន្តរាគមន៍របស់រដ្ឋ

មានទិសដៅ

☑ឃ.បំពេញភាពខ្វះចន្លោះនៃយន្តការទីផ្សារ

4. ចំណាយរបស់រដ្ឋាភិបាលនៃប្រទេសនានា ត្រូវបានប្រើប្រាស់លើ: ☑គ.ដើម្បីអភិវឌ្ឍប្រទេស

II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

1. ក្នុងការរៀបចំគោលនយោបាយផ្សេងៗ ដើម្បីលើកកម្ពស់សេដ្ឋកិច្ចជាតិ ឬជំរុញការងារផលិតកម្ម សេវាកម្មនានា គេត្រូវសិក្សាក្នុងមីក្រូសេដ្ឋកិច្ចនិងម៉ាក្រូសេដ្ឋកិច្ច

2. នៅក្នុងសង្គម រដ្ឋមានតួនាទីសំខាន់ចំនួន ២ គឺជាអ្នកបង្កើត ច្បាប់ ការពារសន្តិសុខជូន ប្រជាពលរដ្ឋជាម្ចាស់ កម្មសិទ្ធិលើ ទ្រព្យសម្បត្តិ និងជាអ្នកបង្កើតរៀបចំចាត់ ចែង និងគ្រប់គ្រងស្ថាប័ន សម្រាប់ជំរុញនិងសម្របសម្រួលការប្រព្រឹត្តទៅនៃយន្តការសេដ្ឋកិច្ច។

3. ក្នុងសេដ្ឋកិច្ចទីផ្សារ រដ្ឋមានតួនាទីដោយប្រយោលនិងតួនាទីដោយចំពោះ។តួនាទីដោយ ចំពោះរបស់រដ្ឋមានន័យថា ជាការលូកដៃកាន់តែជ្រៅរបស់រដ្ឋក្នុងសេដ្ឋកិច្ច

ជាពិសេសការជំរុញដំណើការបង្កើនផលិតផលសង្គម តាមរយៈរោងចក្រ ឬសហគ្រាសរដ្ឋដែលប្រព្រឹត្តទៅ មិននៅក្រោមឥទ្ធិពលនៃក្រឹត្យក្រមតម្រូវការនិងការផ្គត់ផ្គង់។

4. កំណើនផលិតកម្មជាកត្តាបង្កើនសេដ្ឋកិច្ច។
5. ឱនភាពថវិកាកើតមាននៅពេលដែលចំណាយមានបរិមាណច្រើនជាងចំណូល។
6. ភាពគ្មានការងារធ្វើ គឺជាបន្ទុកដ៏ធ្ងន់ធ្ងរនិងមាន ផលប៉ះពាល់យ៉ាងខ្លាំងដល់សង្គមជាតិទាំងមូល។

III.ចម្លើយនៃសំនួរ

1. ម៉ាក្រូសេដ្ឋកិច្ចគឺជាការសិក្សាវិភាគរកមូលហេតុនិងផលវិបាកនៃការអភិវឌ្ឍសេដ្ឋកិច្ច។ដូច្នេះគេត្រូវយល់ដឹងអំពី:
   - ទំនាក់ទំនងរវាងសេដ្ឋកិច្ចជាតិនិងអន្តរជាតិ។ការសិក្សាតាមដានវិបត្តិសេដ្ឋកិច្ចពិភពលោកនិងផលប៉ះពាល់ចំពោះសេដ្ឋកិច្ចកម្ពុជា។
   - បញ្ហាសេដ្ឋកិច្ចចម្បងក្នុងជីវភាពសង្គម មានន័យ

ថា បញ្ហាកែទម្រង់សេដ្ឋកិច្ចដែលឆ្លុះអំពីទំនាក់ទំនងរវាងទីផ្សារទំនិញ ទីផ្សារពលកម្ម និងទីផ្សារហិរញ្ញវត្ថុ។

- ចរិតសេដ្ឋកិច្ចជាតិ ការរីកចម្រើននិងការមានវិបត្តិកើតឡើង បរិមាណសរុបថ្លៃទំនិញនិងសេវាកំណើនសរុបនៃផលិតផលអត្រាអតិផរណាអត្រាគ្មានការងារធ្វើអត្រាប្តូរប្រាក់ អត្រាការប្រាក់ក្នុងចរន្តសេដ្ឋកិច្ច។
- ទីផ្សារពលកម្មនិងការពាក់ព័ន្ធនឹងជំនាញឯកទេសកម្រិតជំនាញ និងតម្រូវការទីផ្សារ។

2. គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនៃប្រទេសនីមួយៗក្នុងពិភពលោកមានខ្លឹមសារមិនដូចគ្នាពីព្រោះ គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចក្នុងបណ្តាប្រទេសជឿនលឿនធានាឱ្យមានកំណើនសេដ្ឋកិច្ចដោយផ្អែកលើដំណើរការផលិតកម្ម ភាពមានការងារធ្វើពេញលេញ និងធ្វើឱ្យអត្រាអតិផរណាស្ថិតក្នុងកម្រិតទាប។

ចំណែកឯគោលបំណងនៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍវិញ មានការកំណត់ទៅតាមបញ្ហាជារភាទិភាពជាច្រើន រួមមានកំណែទម្រង់ប្រព័ន្ធសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ថាប័នច្បាប់តុលាការ និងកំណែទម្រង់ផ្នែករដ្ឋបាលសាធារណៈជាដើម។

3. វិស័យដែលកំណត់ការលូតលាស់នៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមាន:
   - វិស័យឧស្សាហកម្ម សំខាន់ដែលបម្រើការនាំចេញនៅកម្ពុជាគឺ សម្លៀកបំពាក់ និងកៅស៊ូក្រែប។
   - វិស័យកសិកម្ម នេសាទ និងព្រៃឈើ មានដូចជា ស្រូវ ថ្នាំជក់ត្រី សត្វចិញ្ចឹម និងឈើ។ ក្រៅពីនេះ ផលិតផលដែលមានតម្រូវការក្នុងការនាំចេញមាន ពោត សណ្តែក ល្ង ក្តួច ដំឡូង អំពៅ គ្រាប់ស្វាយចន្ទី ម្រេច កាហ្វេ និងផ្លែឈើ។

4. នៅក្នុងសេដ្ឋកិច្ចទីផ្សារ រដ្ឋមានតួនាទីត្រឹមជាអ្នកការ

ពារកម្មសិទ្ធិ ជាអ្នកបង្កើតនិងចាត់ចែងស្ថាប័នសង្គម មូលដ្ឋានច្បាប់ផ្សេងៗដែលចាំបាច់សម្រាប់ជំរុញ និងសម្រួសម្រួលការប្រព្រឹត្តទៅនៃយន្តការសេដ្ឋកិច្ចទីផ្សារតែប៉ុណ្ណោះ។

5. ក្នុងវិស័យសេដ្ឋកិច្ចនៅក្នុងប្រទេសកំពុងអភិវឌ្ឍ រដ្ឋមានតួនាទីដូចជា:
   - ដោះស្រាយចរិតឯករប្បកម្មនៃសេដ្ឋកិច្ចជាតិអន់ថយ
   - ដោះស្រាយភាពខ្សោយនៃផ្នែកឯកជន។
   - ដោះស្រាយនូវភាពអន់ថយនៃរបៀបផលិតក្នុងផ្នែកកសិកម្ម។
   - ដោះស្រាយនូវភាពខ្វេចខ្វាំនិងក្រខ្សត់នៃសេដ្ឋកិច្ច។

6. ចំណូលជាតិ គឺជាបរិមាណទឹកប្រាក់សរុបដែលរកបាននៅក្នុងប្រទេស បានទទួលដោយអ្នកផ្គត់ផ្គង់ធនធានសេដ្ឋកិច្ចនិងធនធានហិរញ្ញវត្ថុ។

ចំណូលជាតិមានប្រភពដូចជា

- ការប្រាក់សុទ្ធ

- ប្រាក់ពលកម្ម ឬសំណងទូទាត់សម្រាប់និយោជិត
- ចំណូលពីបរទេស
- ចំណូលពីការជួល
- ចំណូលរបស់ម្ចាស់កម្មសិទ្ធិ
- ប្រាក់ចំណេញសាជីវកម្ម

7. សកម្មភាពសេដ្ឋកិច្ចរដ្ឋនិងឯកជនមានទំនាក់ទំនងយ៉ាងខ្លាំងពីព្រោះរដ្ឋជាអ្នកបង្កើតគម្រោងកម្មវិធីសកម្មភាពដោយមានការបោះទុនវិនិយោគពីអន្តរជាតិ ក្នុងគ្រប់វិស័យមានដូចជា វិស័យអប់រំ សុខាភិបាល សង្គមកិច្ច។រដ្ឋជាអ្នកបង្កើតច្បាប់ដើម្បី ការពារដល់ផលប្រយោជន៍សាធារណៈ។

8. ជាតូបនីយកម្មមានន័យថាការបង្វិលសហគ្រាស ឬសាខាផលិតកម្មនៃកម្មសិទ្ធិឯកជនឱ្យទៅជាកម្មសិទ្ធិរបស់រដ្ឋ។

- អប្រសិទ្ធភាពនៃជាតូបនីយកម្មៈក្រោយពេលបានក្លាយជាកម្មសិទ្ធិរបស់រដ្ឋក្នុងករណីសហគ្រាសត្រូវការចំណាយហិរញ្ញវត្ថុច្រើនហើយផលិតកម្មមិនសូវ

មានប្រសិទ្ធភាពនោះមានន័យថាជាតូបនីយកម្មគ្មានប្រសិទ្ធទេ។

- ប្រសិទ្ធភាពនៃជាតូបនីយកម្ម: ជាទូទៅនៅក្នុងប្រទេសកំពុងអភិវឌ្ឍគេធ្វើជាតូបនីយកម្មដើម្បីប្រឆាំងនឹងរបបលក់ផ្តាច់មុខរបស់បរទេស ឬប្រឆាំងនឹងនយោបាយអាណានិគមនិយមបែបថ្មី។

9. ឯកជនូបនីយកម្មមានន័យថាការជួល ឬផ្ទេរទ្រព្យសម្បត្តិរដ្ឋទៅឱ្យឯកជនដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

✓ប្រសិទ្ធភាពឯកជនូបនីយកម្ម:ទទួលជោគជ័យលុះត្រាតែ

- រដ្ឋមានទិសដៅច្បាស់លាស់ មានគោលនយោបាយជាយុទ្ធសាស្ត្រសមស្រប។
- ធនធានមនុស្សគ្រប់គ្រាន់តាមតម្រូវការនៃជំនាញ
- ហិរញ្ញវត្ថុមានសក្តានុពល
- ប្រព័ន្ធគណនេយ្យធនាគារមានលក្ខណ:ទូលំ

ទូលាយនិងមានច្បាប់លិខិតបទដ្ឋានត្រឹមត្រូវ។

✓អប្រសិទ្ធភាពនៃឯកជនូបនីយកម្មៈ ក្នុងប្រទេសកំពុងអភិវឌ្ឍភាគច្រើនតែងនៅខ្វះខាតគោលនយោបាយច្បាស់លាស់អំពីកម្មវិធីនិងទិសដៅ ឯកជនូបនីយកម្ម ហើយគោលនយោបាយនានាច្រើនប្រទាញប្រទង់ទៅតាមកត្តានយោបាយ។ បន្ថែមលើនេះ កង្វះធនធានមនុស្ស ហិរញ្ញវត្ថុ ប្រព័ន្ធគណនេយ្យធនាគារ និងច្បាប់លិខិតបទដ្ឋានបានបង្កអប្រសិទ្ធភាពនៃឯកជនូបនីយកម្មដែលស្តែងឱ្យឃើញនូវរូបភាពការប្រែក្លាយការផ្តាច់ មុខរបស់រដ្ឋឱ្យទៅជាការផ្តាច់មុខរបស់ឯកជនប៉ុណ្ណោះ។

10. ☛ប្រាក់បៀវត្ស គឺជាប្រាក់ថ្លៃឈ្នួលពលកម្ម ដែលបុគ្គលិក ឬកម្មករទទួលបានជាប្រចាំក្នុងអំឡុងពេល ដែលគេកំពុងបំពេញការងារនៅតាមគ្រឹះស្ថាន ឬ ក្រុមហ៊ុនណាមួយ។

☛បានជាកម្មករភាគច្រើនត្រូវការប្រាក់បៀវត្សអប្បបរមាពីព្រោះក្នុងទីផ្សារប្រកួតប្រជែងដែលមានទូទៅ

ក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍប្រាក់បៀវត្សខ្ពស់មិនមានន័យថាមាននិកម្មភាពខ្ពស់ឡើយ។ ម៉្យាងទៀតនៅពេលដែលបង្កើនថ្លៃដើមពលកម្ម(ប្រាក់បៀវត្ស) សហគ្រាសនឹងព្យាយាមប្រើប្រាស់កម្លាំងពលកម្មឱ្យមានប្រសិទ្ធភាពខ្ពស់ផងដែរ។

11.វិបត្តិសេដ្ឋកិច្ច គឺជាការរងផលវិបត្តិហិរញ្ញវត្ថុដែលបណ្ដាលមកពីវិបត្តិបរិស្ថាន អស្ថិរភាពនយោបាយ ឬការរីកចម្រើនដល់កំពូលនៃការងារ ផលិតកម្មដែលនាំឱ្យមានផលិតផលលើស។

☛វិបត្តិសេដ្ឋកិច្ចកើតឡើងដោយបញ្ហាមួយចំនួនដូចជា:

✓ គ្រោះធម្មជាតិ:មានដូចជា ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី បន្ទុះភ្នំភ្លើង ការរាំងស្ងួត។

✓ វិបត្តិនយោបាយ: មានដូចជា សង្គ្រាម ការប្រកាន់យកលទ្ធិផ្ដាច់ការរបបប្រល័យពូជសាសន៍ឬ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

✓ វិបត្តិក្នុងការគ្រប់គ្រងថវិការដ្ឋ: មានន័យថា រដ្ឋមាន

កង្វះខាតក្នុងការគ្រប់គ្រងហិរញ្ញវត្ថុឱ្យបានសមស្របបណ្តាលឱ្យមានការចំណាយដ៏ធំជាងចំណូលដែលរកបាន។

✓ វិបត្តិផលិតផលលើស: បណ្តាលមកពីផលិតផលមានកំណើនលើសពីសេចក្តីត្រូវការរបស់ទីផ្សារដែលនាំឱ្យមានការធ្លាក់ចុះទាំងស្រុងនៃដំណើរផលិតកម្មដែលអាចបណ្តាលឱ្យមានការថយចុះការវិនិយោគទុនការកើនឡើងនៃភាពគ្មានការងារធ្វើការបាត់បង់ប្រាក់ចំណូលរបស់សហគ្រាសនានាការធ្លាក់ចុះនៃអត្រាប្រាក់ហ៊ុននិងកំណើនអតិផរណា។

✓ វិបត្តិកសិកម្ម:បណ្តាលមកពីមានកំណើនកសិកផលលើសពីសេចក្តីត្រូវការរបស់ទីផ្សារនៅក្នុងបណ្តាប្រទេសជឿនលឿន។

✓ វិបត្តិថាមពល:ជាវិបត្តិសេដ្ឋកិច្ចមួយនៅក្នុងចំណោមវិបត្តិសេដ្ឋកិច្ចទាំងឡាយប៉ុន្តែមិនមានលក្ខណ:ជាខួបទេ។

✓ វិបត្តិបរិស្ថាន: គឺការខូតបរិស្ថាននៃប្រទេសអភិវឌ្ឍនានាដែលបណ្តាលមកពីការបំផ្លិចបំផ្លាញប្រកបដោយព្យសនកម្មដែលមិនអាចប្រកែតបាន ឬដែលពិបាកនឹងជួសជុលបាន។

✓ វិបត្តិរូបិយវត្ថុ: គឺការបាត់លំនឹងទូទាត់យ៉ាងធ្ងន់ធ្ងរនៃប្រព័ន្ធហិរញ្ញវត្ថុក្នុងនិងក្រៅប្រទេ

✓ វិបត្តិវប្បធម៌:សំដៅលើការប្រកាន់យកឥរិយាបថអវិជ្ជមានរបស់ប្រជាពលរដ្ឋមួយចំនួនដែលជាមូលហេតុនាំឱ្យរាំងស្ទះដល់ការលើកកម្ពស់សេដ្ឋកិច្ចរបស់បុគ្គលនិងគ្រួសារខ្លួនឯងដែលជះឥទ្ធិពលលើការលើកកម្ពស់សេដ្ឋកិច្ចជាតិ។

---

# ជំពូកទី៣ ប្រវត្តិគំនិតសេដ្ឋកិច្ច

## មេរៀនទី១

## បណ្ដាគំនិតផ្ដួចផ្ដើមដំបូង

?សំណួរ

2. ចូរអ្នកធ្វើស្រាវជ្រាវនិងពិភាក្សាជាមួយដៃគូឬ សមាជិកដទៃទៀតក្នុងក្រុមដើម្បីដោះស្រាយសំណួរខាងក្រោមៈ

ក. ពាណិជ្ជកម្មតែងជៀសមិនផុតពីភាពមន្ទិល។តើគំនិតនេះមាន ន័យយ៉ាងដូចម្ដេច?

ខ. សម្ដេចប៉ាបក្នុងជំនាន់ស្ដេចក្រេហ្គ័រទី៧ (Gregoire VII) បានប្រកាន់យកលទ្ធិមួយ"បញ្ហាសីលធម៌ត្រូវមាន ជាប់ជាមួយនឹងការធ្វើពាណិជ្ជកម្មការកាន់កាប់ទ្រព្យកម្មសិទ្ធិការរកប្រាក់ចំណេញការឱ្យខ្ចីដើម្បីយក រ ប្រាក់"ជាដើម។លទ្ធិនេះមានន័យដូចម្ដេច?

គ. តើលោកអារីស្តូតប្រើពាក្យ"បាបធម៌"នៅពេល និយាយពីអ្វី? ហើយមានអត្ថន័យដូចម្តេច?

ឃ."អ្នកលក់តែងចំណាយកម្លាំងរបស់ខ្លួនដើម្បីទទួលប្រាក់ចំណេញ"តើគំនិតនេះមានន័យដូចម្តេច?ចូរពន្យល់។

ង. តើលោកសាំងតូម៉ាសដាកាំង មានទស្សនៈយ៉ាងណាចំពោះបញ្ហាទ្រព្យកម្មសិទ្ធិ?

ច. តើនៅស.វទី១៥និងទី១៦មានការលើកឡើងអំពីមន្ទិល ក្នុពាណិជ្ជកម្មដែរឬទេ? ហេតុអ្វី?

ឆ. ចូរអ្នករៀបរាប់ព្រឹត្តិការណ៍និងគំនិតនៃអ្នកពាណិជ្ជកម្មនិយម។

ជ. "ភាពសម្បូរដោយធនធានកើតមានមកអំពីដីនិង សេរីភាពនៃពាណិជ្ជកម្ម"តើគំនិតនេះ មានន័យយ៉ាងដូចម្តេច? ចូរពន្យល់។

## ចម្លើយ

2\. ក. ពាណិជ្ជកម្មចៀសមិនផុតពីភាពមន្ទិល។ មានន័យរាល់ការធ្វើពាណិជ្ជកម្មគឺសុទ្ធតែមានការប្រថុយប្រថាន និងមានការបន្ទិលសង្ស័យជានិច្ចថាតើអាជីវកម្មរបស់ខ្លួនទទួលបានជោគជ័យ ឬយ៉ាងណានោះទេ។

ខ.សម្តេចប៉ាបក្នុងជំនាន់ស្តេចគ្រេហ្គ័រទី៧ (Gregoire VII) បានប្រកាន់យកលទ្ធិមួយ"បញ្ហាសីលធម៌ត្រូវមាន ជាប់ជាមួយ នឹងការធ្វើពាណិជ្ជកម្មការកាន់កាប់ទ្រព្យកម្មសិទ្ធិ ការរកប្រាក់ចំណេញការឱ្យខ្ចីដើម្បីយកការប្រាក់" ជាដើម។លទ្ធិនេះមានន័យថា រាល់ការធ្វើពាណិជ្ជកម្ម ការកាន់កាប់ទ្រព្យសម្បត្តិកម្មសិទ្ធិ ការរកប្រាក់ចំណេញ ការឲ្យខ្ចី ការយកការប្រាក់ ត្រូវប្រកាន់ភ្ជាប់សីលធម៌ មិនអាចអាងថាខ្លួនមានដើមទុនច្រើនអាចធ្វើអ្វីបានស្រាច់តែចិត្តម្យ៉ាងការមានសីលធម៌អាចធ្វើឲ្យ

គេគោរពស្រលាញ់ គេចូលចិត្ត ជាហេតុធ្វើឲ្យអាជីវកម្មរបស់យើងមានគេស្គាល់ និងគាំទ្រគ្រប់ៗគ្នា នោះអាជីវកម្មរបស់យើងនឹងទទួលបានជោគជ័យ ព្រមទាំងមនុស្សជាតិរស់នៅជាមួយគ្នាយ៉ាងសុខសប្បាយ។

គ. លោកអារីស្តូតប្រើពាក្យ "បាបធម៌" នៅពេលនិយាយពីការរែអង្គាសគ្មានព្រំដែនដើម្បីភាពមានបាន ការធ្វើជំនួញ កិច្ចការខាងហិរញ្ញវត្ថុ ។ហើយមានន័យថា រាល់ការធ្វើជំនួញ កិច្ចការខាងហិរញ្ញវត្ថុគឺគ្មាននរណាម្នាក់បានគិតពីសីលធម៌ សុជីវធម៌នោះទេពោលគឺធ្វើយ៉ាងណាដើម្បីទទួលបានប្រាក់ចំណេញ។

ឃ."អ្នកលក់តែងចំណាយកម្លាំងរបស់ខ្លួនដើម្បីទទួលប្រាក់ចំណេញ" គំនិតនេះមានន័យថា ដើម្បីទទួលបានប្រាក់ចំណេញអ្នកលក់ត្រូវតែចំណាយកទាំងកម្លាំងកាយ កម្លាំងចិត្ត កម្លាំងប្រាជ្ញារិះរកមធ្យោ

បាយធ្វើយ៉ាងណាលក់ឲ្យបានច្រើន និងទទួលបានផលចំណេញច្រើន។

ង. ចំពោះបញ្ហាទ្រព្យកម្មសិទ្ធិ លោកសាំងតូម៉ាសដាកាំងមានទស្សនៈថាការកាន់កាប់ទ្រព្យកម្មសិទ្ធិត្រូវទទួលស្គាល់ដោយច្បាប់ពីព្រោះម្ចាស់កម្មសិទ្ធតែងយកចិត្តទុកដាក់ខ្លាំងក្នុងការរក្សាសម្បត្តិផ្ទាល់ខ្លួនរបស់គេ។

ឆ. អ្នកពាណិជ្ជវិស័យនិយមបានយល់ឃើញថា វិទ្យាសាស្ត្រនៃកិច្ចការរបស់រាជាធិរាជដែលមាន "គំនិត " ជាមគ្គុទេសជាន់ខ្ពស់។ នៅស.វទី១៥ ពាណិជ្ជកម្មត្រូវគេទទួលស្គាល់ថាជាសន្ទុះលូតលាស់ ឬជាការរកឃើញដ៏មហិមានសបដិវត្តន៍សេដ្ឋកិច្ចនិងទស្សនៈវិស័យនៃពិភពលោកនាសហាសម័យ។រីឯបដិវត្តន៍សិល្បះនិងនបដិវត្តបញ្ញាញាណ ក៏មានដំណើរការលូតលោស់ស្របគ្នាដែរ។

ជ. "ភាពសម្បូរដោយធនធានកើតមានមកអំពីដីនិង សេរីភាពនៃពាណិជ្ជកម្ម"គំនិតនេះមានន័យថា ធនធានដែលកើតឡើងពីដីមានដូចជា កសិផល រ៉ែ ឧស្ម័ន

ធម្មជាតិ... ហើយមនុស្សមានសេរីភាពក្នុងការធ្វើអាជីវកម្មទៅលើធនធានធានទាំងនោះ ជាហេតុធ្វើឲ្យទទួលបានទទួលបានប្រាក់ចំណេញ និងធនធានជាច្រើន នោះមនុស្សនឹងទទួលបានភាពសប្បាយរីករាយ។

---

## មេរៀនទី២

### បណ្ដាគំនិតគន្លឹះ

?សំណួរ

2. ចូរអ្នកពិភាក្សាជាមួយដៃគូ ឬជាក្រុម ដើម្បីដោះស្រាយសំណួរខាងក្រោម

ក. តើលទ្ធិតន្តីនិយមជាអ្វី? លទ្ធិនេះកើតមាននៅទីណា? នៅពេលណា?

ខ. តើគោលការណ៍នៃលទ្ធិតន្តីនិយមមានប៉ុន្មាន? អ្វីខ្លះ?

គ. ក្នុងបណ្តាគោលការណ៍ជាមូលដ្ឋាននៃលទ្ធិតន្តី តើគោលការណ៍ណាមួយដែលមិនសមស្របនឹងទស្សនៈរបស់អ្នក?

ឃ.ចូរអ្នករៀបរាប់និងពន្យល់គោលការណ៍ជាមូលដ្ឋានណាមួយនៃលទ្ធិតន្តីដែលមានភាពស្របនឹងទស្សនៈរបស់អ្នក។

ង. មានគំនិតមួយដែលបែកចេញពីក្រុមតន្តី ហើយក្លាយជាមូលដ្ឋាននៃក្រុមផ្សេងទៀត ចូរអ្នករៀបរាប់គំនិតទាំងនោះ។ក្នុងបណ្តាគំនិតទាំងនោះតើគំនិតណាមួយដែលអ្នកគាំទ្រច្រើនជាងគេ ? តើគំនិតណាមួយដែលមានអ្នកគាំទ្រតិចជាងគេ ? ហេតុអ្វី?

---

## ចម្លើយ

2.ក.លទ្ធិតន្តិនិយមជាការប្រកាន់លើការជួបគ្នាលើលទ្ធិសេរី

និយមមួយដែលនឹងនាំមកនូវរបស់នាក់ពិសេសមួយនៃលទ្ធិមូលធននិយម។លទ្ធិនេះកើតមាននៅប្រទេសអង់គ្លេស នៅស.វទី១៩។

ខ. គោលការណ៍នៃលទ្ធិតន្តិនិយមមាន

✓ការលូតលាស់រីកចំរើនកើតមានដោយសារការបង្កើនការសំរៃ

✓ការរីកចំរើនកើតឡើងពីការបែងចែកការងារ

✓ភាពស្មូនគូនាំទៅរកការរីកចំរើន

✓សកលភាពនៃច្បាប់

✓ភាពសម្បូរធនធានទាំងអស់កើតចេញពីពលកម្ម

✓សុទិដ្ឋិនិយមនៃរកប្រយោជន៍

✓ការបែងចែកពលកម្មជាអន្តរជាតិអាចផ្តល់ផលចំណេញសម្រាប់ទាំអស់គ្នា

✓សេរីភាពនៃពាណិជ្ជកម្មនិងសហគ្រាសគឺជាលក្ខខណ្ឌនៃភាពសម្បូរធនធាន

✓អ្នកតន្តីនិយមមើលឃើញថាសង្គមជាសំណុំនៃវណ្ណៈបី(វណ្ណៈម្ចាស់ដី វណ្ណៈមូលធននិយម វណ្ណៈកម្មករ)

ង. គំនិតមួយដែលបែកចេញពីក្រុមតន្តី ហើក្លាយជាមូលដ្ឋាននៃក្រុមផ្សេងទៀតមានដូចជា:

- តម្លៃពិតនៃផលិតផល
- វិបត្តិខ្វះកនលែងនាំចេញ
- ការផ្គត់ផ្គង់សេចក្តីត្រូវការង
- ចំណុចត្រូវតិទៀនរបស់លោកកាល់ម៉ាក្ស
- អ្នកតន្តីនិយមប្រឆាំងនឹងការទាយស្មាន។
- ការសំចៃលើសកំណត់នឹងនាំអោយរូញកន្លែងលក់ចេញ

# មេរៀនទី៣

## គំនិតលោកកាល់ម៉ាក្សនិងគំនិតតន្តី

### សំណួរ

2. ចូរអ្នកធ្វើការស្រាវជ្រាវនិងពិភាក្សាជាមួយដៃគូ ឬសមាជិកដទៃទៀតក្នុងក្រុម ដើម្បីដោះស្រាយសំណួរខាងក្រោម

ក. តើលោកកាល់ម៉ាក្សមានទស្សនៈវិស័យយ៉ាងណា និងមានសកម្មភាពអ្វីខ្លះ?

ខ. តើលោកកាល់ម៉ាក្សបានមើលឃើញស្ថានភាពការងាររបស់កម្មករមានលក្ខណៈដូចម្តេចខ្លះ?

គ. តាមទ្រឹស្តីវិចារវិទ្យារបស់លទ្ធិម៉ាក្ស តើប្រវត្តិសាស្ត្រជាអ្វី?

ឃ.ក្នុងលទ្ធិម៉ាក្ស អ្វីជាការកេងប្រវ័ញ្ច ?

ង. តើលទ្ធិម៉ាក្សមានការប៉ាន់ប្រមាណទៅអនាគតយ៉ាង

ដូចម្តេចខ្លះ ?

ច. ក្នុងបណ្តាទ្រឹស្តីរបស់លទ្ធិម៉ាក្ស តើទ្រឹស្តីណាមួយដែលមានអត្ថប្រយោជន៍ដល់ការអភិវឌ្ឍសង្គមបច្ចុប្បន្ន ?

---

ចម្លើយ

2.ក.លោកបានប្រើប្រាស់បណ្តាបញ្ញាត្តិរបស់អ្នកតន្តីនិយមៈអោយប្រែត្រលប់សេចក្តីវិនិច្ឆ័យរបស់អ្នក ទាំងនោះដោយយកត្រង់ទស្សនៈវិស័យអំពីជនរងគ្រោះ។ សកម្មភាពរបស់លោកកាល់ម៉ាក្សៈលោកជាទ័ពម្នាក់ដែលស្ថិតនៅក្នុងចលនាយុវជនអាឡឺម៉ង់ដែលស្ថិតនៅជួរខ្ពស់បំផុតក្នុងបដិវត្តន៍ អ៊ឺរ៉ុបឆ្នាំ 1848។ ក្រោយមកលោកបង្កើតបដិវត្តន៍មួយគឺសមាគមកម្មករអន្តរជាតិដែល លោកបានជំរុញតាំងពីពេលដែលលោកបាននិរទេសចេញពីប្រទេសអង់គ្លេស។ហើយលោកក៏បានបោះពុម្ពផ្សាយសៀវភៅតូចៗអំពីនយោបាយមួយចំនួនផងដែរ។

ខ.ស្ថានភាពការងាររបស់កម្មករដែលលោកកាល់ម៉ាក្ស

មើលឃើញៈទាសភាពរបស់កម្មករនាំកម្មករទៅរកការទទួលលក្ខខ័ណ្ឌនានាក្នុងការងារឧស្សាហកម្មមានការបែងចែកជាដើម ហើយការបែងចែកការងារនេះនាំអោយកើតមានវណ្ណៈពលជីវី ដែលមិនយល់ពីសកម្មភាពដែលជារបស់ខ្លួន។ ឯកម្មករខាងសិប្បកម្មសកម្មភាពរបស់គេមិនបានទទួលការគៀបសង្កត់ទេប៉ុន្តែផលនៃការងាររបស់គេត្រូវបានដកហូតយកដែលធ្វើអោយគេមើលមិនឃើញការគៀបសង្កត់ផ្ទៃក្នុងលើការងាររបស់គេផ្ទាល់ជាហេតុនាំអោយគេបង្អាក់ការបញ្ចេញសកម្មភាពច្នៃប្រឌិតរបស់គេ។

គ.តាមទ្រឹស្តីវិចារវិទ្យារបស់លទ្ធិម៉ាក្សប្រវត្តិសាស្ត្រជាប្រវត្តិនៃការតស៊ូវណ្ណៈជាដំណើរបន្តមិនដាច់នៃបែបផែនផលិតកម្ម(បែបទាសករ បែបសក្តិភូមិបែបមូលធននិយមបែបសង្គមនិយម)ដែលបង្ហាញអោយឃើញច្បាស់តាមរយៈទំនាស់ទាំងឡាយដែលលិចឡើងឆ្លងកាត់សម័យកាលនិមួយៗ។

ឃ.ក្នុងលទ្ធិម៉ាក្ស ការកេងប្រវ័ញ្ចជាតម្លៃដែលបង្កើតចេញ

ពីកម្មករក៏ក្លាយជារូបិយ័វត្ថុដែលក្នុងនោះមានតម្លៃលើសជាប្រាក់ចំណេញ។

ង. លទ្ធិម៉ាក្សមានការប៉ាន់ប្រមាណទៅអនាគតៈវិបត្តិទៀងទាត់ទាំងឡាយកើតមានក្នុងរយៈពេលខ្លី ប៉ុន្តែការខូចខាតជាស្វ័យប្រវត្តិកើតមានក្នុងរយៈពេលវែង។

- វិបត្តិស្ថិតនៅជាមួយប្រព័ន្ធៈដំណាក់កាលរីកចម្រើនតែងតែទាក់ទាញបន្ថែមនូវការវិនិយោគទុនជាហេតុបណ្តាលឲ្យមានកំណើនដ៏លើសលុបនៃអំពើកេងប្រវ័ញ្ចដែលដំណោះស្រាយទីផ្សារមិនអាចដោះស្រាយបាន។
- និន្នាការស្រកចុះនៃអត្រាប្រាក់ចំនេញៈ កំណើនផលិតផលនាំឲ្យមានការរីកចម្រើន ប៉ុន្តែកំនើននេះដឹកនាំមូលធនទៅរកការខាតបង់។
- ការយកមធ្យោបាយផលិតកម្មដាក់ជាសម្ហូហាភាពគឺជាដំណោះស្រាយ។

ច. ទ្រឹស្តីរបស់លទ្ធិម៉ាក្ស "ការប៉ាន់ប្រម៉ានមួយ" ព្រោះការប៉ាន់ប្រមានអាចបណ្តាល់អោយមានការរៀបចំទុកសំរាប់

រាល់គ្រប់កាលៈទេសៈ។

---

មេរៀនទី៨

## បណ្ដាគំនិតតន្ដីថ្មីនិងសមតាទូទៅ

?សំណួរ

2. ចូរអ្នកពិភាក្សាជាគូ ឬជាក្រុមដើម្បីដោះស្រាយសំណួរខាងក្រោម

ក. តើការគិតពិចារណារបស់ក្រុមអ្នកតន្ដីនិយមសម័យមុននិងនិយមសម័យថ្មីខុសគ្នាត្រង់ណា?

ខ. ចូរពន្យល់តម្លៃនៃទ្រព្យតាមគំនិតលោកសាយ លោកប៉ារ៉ីតូ និងលោកម៉ង់សេ ។

គ. តើលោកអ្នកប្រាជ្ញាណាដែលបានអនុវត្តគណិតវិទ្យាលើសេដ្ឋកិច្ចដំបូងគេ? អនុវត្តនៅឆ្នាំណា ? អនុវត្តដូចម្ដេចខ្លះ ? ចូរពន្យល់។

ឃ.ក្នុងករណីណាដែលការផ្ដោះប្ដូរអាចកើតឡើងបាន? ចូរពន្យល់។

ង. ហេតុអ្វីបានជាគេថា "ការងារជាទំនិញ" ?ចូរពន្យល់។

ច. អ្នកតន្ត្រីនិយមសម័យថ្មី យល់ថា "ភាពរលាស់បាននៃតម្លៃជាអ្នកធានាឱ្យមានសមតាលើគ្រប់ទីផ្សារដោយព្រមគ្នា" ។តើគំនិតនេះមានន័យយ៉ាងដូចម្ដេច? ចូរពន្យល់។

ឆ. លោកប៉ារ៉ុតូនិងលោកវ៉ាល់រ៉ាសចង់បានយុត្តិធម៌សង្គមដោយវិធីកំណែទម្រង់សង្គមទាំងស្រុងសំដៅធ្វើមានលក្ខណៈស្មើគ្នាក្នុងការចេញដំណើរ ដូចជាការលុបចោលមរតកនិងការធ្វើជាតូបនីយកម្មដីធ្លីប៉ុន្តែគំនិតនេះទទួលការរិះគន់ច្រើន។ តើគំនិតរិះគន់នោះមានអត្ថន័យដូចម្ដេច?

ជ. តើលោកអាល់ហ្វ្រើដម៉ាសាលមានគំនិតយ៉ាងណាខ្លះទាក់ទងនឹង "សេដ្ឋកិច្ចសុខុមាលភាព"?

ឈ.តើធនធានមនុស្សមានន័យយ៉ាងដូចម្ដេច តាមគំនិតរបស់លោកបិកឺ (Becker) ?

## ចម្លើយ

2.ក.ភាពខុសគ្នារវាងគន្តីនិយមសម័យមុននិងនិយម សម័យថ្មី:

គន្តីនិយមសម័យមុន ជាការប្រកាន់លើការជួបគ្នាលើលទ្ធិសេរីនិយមមួយដែលនឹងនាំមកនូវរូបសំនាក់ពិសេសមួយនៃលទ្ធិមូលធននិយម។

គន្តីនិយមសម័យថ្មី បាននាំយកមកជាថ្មីនូវនិក្ខេបទគន្តីនិយមអំពី"សេរីភាព"ប៉ុន្តែបានធ្វើការសម្រួលនូវជម្រើសជាច្រើន ជាពិសេសចំពោះនិក្ខេបទដែលគាំទ្រម៉ាក្សដែលបង្កើតទ្រឹស្តីអំពីការកេងប្រវ័ញ្ចនិងគាំទ្រតម្លៃការងារ។

ខ. តម្លៃនៃទ្រព្យតាមគំនិតលោកសាយ លោកប៉ារ៉ិតូ និងលោកម៉ង់សេ:

- ទ្រព្យមួយមានតម្លៃកាន់តែខ្ពស់ នៅពេលដែលវាកាន់តែខ្សត់
- គេអាចទាញមាត្រដ្ឋានតម្លៃ
- គេស្គាល់ថាផលប្រយោជន៍នៃទ្រព្យតាមបែបលំដាប់

នៃផលប្រយោជន៍ដូចជាការនិយមស្រាបៀរជាង ភេសជ្ជៈកូកាមិនរួមបញ្ចូលនូវការចេះគូសគំនូសលើ ការនិយមទេ(Pareto)។

- ទ្រព្យមួយមានតម្លៃកាន់តែខ្ពស់នៅពេលដែលមនុស្ស ត្រូវការវាកាន់តែច្រើន។

គ. (ប្អូនៗឆ្លើយដោយខ្លួនឯង)

ច. អ្នកតន្តីនិយមសម័យថ្មីយល់ថា"ភាពរលាស់បាននៃ តម្លៃជាអ្នកធានាឱ្យមានសមតាលើគ្រប់ទីផ្សារដោយ ព្រមគ្នា" ។គំនិតនេះមានន័យការផ្លាស់ប្តូរនៃតម្លៃរបស់ ទំនិញនៅលើទីផ្សារ ធ្វើគេអាចផ្គត់ផ្គង់ទំនិញនៅលើ ទីផ្សារបាន។

ជ.ទាក់ទងនឹង "សេដ្ឋកិច្ចសុខុមាលភាព"លោកអាល់ហ្វ្រេដ ម៉ាសាលោៈ អ្នកក្រមិនមានប្រភពធនធានដើម្បីផ្គត់ផ្គង់ ការរៀនសូត្រ ដែលនឹងទៅអនាគតនឹងបន្ថែមកម្លាំង អោយគេបានទទួលមរតកពីសង្គម និងអាចធ្វើអោយ ប្រសើរឡើងនូវការបម្រើសេវាកម្មសាធារណៈ ដែល ទទួលបានពីការអប់រំឡើយ។អត្ថិភាពនៃផ្នែកទាំង

ឡាយដែលមានតំលៃធ្លាក់ចុះ ត្រូវដាក់ក្រោមការត្រួតពិនិត្យជាសាធារណៈពីព្រោះថារបបផ្តាច់មុខនឹងកើតមានដោយចៀសមិនផុត។

ឈ.តាមគំនិតរបស់លោកបិកឺ(Becker):ធនធានមនុស្សមានន័យថាសំណុំនៃបទពិសោធន៍ ចំណេះដឹងនិងសមត្ថភាពដែលបុគ្គលទទួលបានក្រោយពេលកើតមក។

---

មេរៀនទី៨

# កេនជាមួយនឹងគំនិតបូរណានិយោជន៍

## ?សំណួរ

2.. ចូរអ្នកធ្វើការស្រាវជ្រាវនិងពិភាក្សាជាមួយដៃគូឬ សមាជិកដទៃទៀតក្នុងក្រុមដើម្បីដោះស្រាយសំណួរខាងក្រោម:

ក. តើលោកកេនជានរណា?

ខ. តើលោកកេនគិតពីអ្វី ?

គ. តើមានទ្រឹស្តីអ្វីខ្លះជាគំនិតរបស់លោកកេន?ចូរពន្យល់ទ្រឹស្តីនិមួយៗ។

ឃ. ក្រោយពីការបែកបាក់ក្រុមកេននិយម តើមាន ចលនាអ្វីខ្លះកើតឡើង ?

ង. តើក្រុមដែលកើតឡើងក្រោយក្រុនកេននិយមមានអ្វីខ្លះ?តើក្រុមនីមួយៗមានទស្សនៈដូចម្តេចខ្លះ?

## ចម្លើយ

2.ក.លោកកេនរៀននៅសាលាខេមប្រ៊ីដ ជាសិស្សរបស់លោកម៉ាសាលនិងលោកពីហ្គូល និងជាសិស្សដំបូងគេដែលហានការប្រតិបត្តិប្រាសចាគទ្រឹស្តី។

ខ. គំនិតរបស់លោកកេនបង្ហាញក្នុងប័ណ្ណផ្ទត់នៅបណ្តាឆ្នាំនៃទសវត្សរ៍ឆ្នាំ1920។ហើយគំនិតរបស់លោកគឺជាប្រភពនៃប្រភពនៃវិធានការសេដ្ឋកិច្ចអង់គ្លេស នៅឆ្នាំ១៩៦៧ដែលបានបង្កើតមូលធនសម្រាប់ការស្តារឡើងវិញសហគមន៍និងសន្តិភាព។

ង.ក្រុមដែលកើតឡើងក្រោយក្រុនកេន៍និយមនិងទស្សន:

- ក្រុមសំយោគ:បទបង្ហាញរបស់លោកកេនស្តីពីនយោបាយសេដ្ឋកិច្ចដែលជាការលាយចំរុះរវាងសកម្មភាពថវិកានិងសកម្មភាពរូបិយវត្ថុដែលមានអង្គាកណ្តាលគឺអត្រាការប្រាក់។
- ក្រុមក្រោយកេននិយម:ការរីកចំរើនដែលមានភាព

សមស្របគ្នារវាងប្រាក់បៀវត្សរ៍និងប្រាក់ចំណេញ បានបង្ហាញជោគជ័យនៅបណ្តាឆ្នាំនៃទសត្សរ៍ឆ្នាំ1930 តាមរយៈយន្តការមួយដែលនិយ័តករទាំងឡាយត្រូវបានទទួលស្គាល់ថាជាអ្នកសម្របសម្រួលបៀវត្សតាមបែបសម័យទំនើប។

- ក្រុមអ្នកកេននិយមថ្មីៈពួកគេមានចំនុចរួមត្រង់សិក្សាស៊ីជំរៅលើសញ្ញាណទាំឡាយដែលបកស្រាយដោយលោកកេនអំពី"អនុសញ្ញា"(កិច្ចព្រមព្រៀមលំអិត)និងភាពមិនប្រាកដ។

- ក្រុមនិយ័តកម្មៈក្រុមនេះធ្វើការវិភាគលើភាគខណ្ឌទីផ្សារការងាររវាងការជ្រើសរើសផ្ទៃក្នុងរបស់សហគ្រាសធំៗដើម្បីរកនិយោជិតមានជំនាញ មានលំនឹងក្នុងការងារ សមនឹងទទួលបានប្រាក់បៀវត្សសមរម្យនិងប្រើប្រាស់ខាងក្រៅនូវបុគ្គលិកអចៅរៈ គ្មានជំនាញសមនឹងទទួលបានប្រាក់បៀវត្សតិចតួច សម្រាប់បំពេញការងារមិនស្ថិតស្ថេរ។

## ?សំណួរបញ្ចប់ជំពូកទី៣

I. ចូរគូសសញ្ញា✓ក្នុងប្រអប់មុខចម្លើយណាដែលត្រឹមត្រូវ

1. តើហេតុអ្វីបានជាគេថា សម័យវិស័យពាណិជ្ជកម្មជាប់ការមន្ទិលសង្ស័យ?

☐ក.ការធ្វើពាណិជ្ជកម្មដោយមិនគិតពីសីលធម៌និងបាបកម្ម

☐ ខ.ការធ្វើនយោបាយពាណិជ្ជកម្មគិតតែផលចំណេញនិគ្មានសមធម៌

☐ គ.ពាណិជ្ជកម្មជាអ្នកធ្វើអន្តរាគមន៍ក្នុងការចែកចាយផលិតផលដល់អ្នកក្រ

☐ ឃ.សេរីភាពនៃការធ្វើពាណិជ្ជកម្មនាំចេញច្រើននាំឱ្យមានវិបត្តិក្នុងប្រទេស។

2. ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម អ្នកធម្មជាធិបតេយ្យយកចិត្តទុកដាក់លើ

☐ក.ដីជាប្រភពទ្រព្យសម្បត្តិតែមួយគត់

☐ខ.កសិកម្មជាប្រភពនៃវត្ថុធាតុដើមសម្រាប់ផលិតកម្ម

☐គ.ឧស្សាហកម្មនិងពាណិជ្ជកម្មជាប្រភពនៃការរីកចម្រើនរបស់សង្គម

☐ឃ.ទីផ្សារសេរីនាំជាប្រភពនៃការរីកចម្រើនរបស់សង្គម។

3. តើក្រុមអ្នកសេដ្ឋកិច្ចតន្ត្រីនិយមបានសិក្សាលើអ្វី សំខាន់ជាងគេ?

☐ ក.កំណើនសេដ្ឋកិច្ចនិងសេរីភាពសេដ្ឋកិច្ច

☐ ខ.ការប្រកួតប្រជែងដោយសេរីលើទីផ្សារ

☐ គ.ការកើនឡើងចំនួនប្រជាជននាំឱ្យរំខានដល់ការរីកចម្រើននៃសេដ្ឋកិច្ច។

☐ ឃ.មូលដ្ឋានគ្រឹះនៃបាតុភូតសេដ្ឋកិច្ច (ធនធានមនុស្ស ធម្មជាតិ និងទំនិញ)។

4.តើលោកកាល់ម៉ាក្សបានធ្វើការសិក្សាលើអ្វីខ្លាំង ជាងគេក្នុងទ្រឹស្តីរបស់គាត់ ?

☐ ក.ការតស៊ូរបស់នយោជិកនិងនយោជកក្នុងវិស័យផលិតកម្ម

☐ ខ.ការកេងប្រវ័ញ្ចលើតម្លៃការងារនយោជិក

☐ គ.ប្រវត្តិសាស្ត្រនៃការរីកចម្រើនបែបផែនផលិតកម្ម

☐ ឃ.នយោបាយដើម្បីសេរីភាពច្រើនជាងសេដ្ឋកិច្ច។

5. ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចតាមគំនិតលោកកេន

☐ក.រដ្ឋត្រូវតែធ្វើអន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ចដើម្បីរក្សាសេដ្ឋកិច្ចឱ្យមានស្ថិរភាព

☐ខ.ទីផ្សារជាអ្នកសម្រសម្រួលនិងជំរុញឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ចសង្គម

☐គ.រដ្ឋជាអ្នកបង្កើតឱ្យមានតម្រូវការសេដ្ឋកិច្ចក្នុងសង្គម

☐ឃ.រដ្ឋជាអ្នកធានាឱ្យមានសមធម៌ក្នុងការរីកចម្រើននៃសង្គម។

6.ការអន្តរាគមន៍របស់រដ្ឋក្នុងវិស័យសេដ្ឋកិច្ចនាំឱ្យ

☐ ក.ប្រជាជនមានការងារពេញលេញនិងទទួលផលប្រកបដោយសមធម៌

☐ ខ.មានវិបត្តិតម្រូវការនិងការផ្គត់ផ្គង់របស់សេដ្ឋកិច្ច

☐ គ.ទីផ្សារមិនមានដំណើរការល្អក្នុងការជំរុញប្រតិ

បត្តិផលិតកម្មនិងការលក់ទំនិញនានា

□ ឃ.ការសង្គ្រោះសេដ្ឋកិច្ចបានក្នុងពេលមានវិបត្តិ។

II. ចូរអ្នកបកស្រាយគំនិតរបស់លោកកេន

សេដ្ឋវិទូ កេនយល់ច្បាស់ថាកម្លាំងទីផ្សារពិតជាមានអំណាចខ្លាំងណាស់។ទីផ្សារពេលខ្លះពិតជាមិនមានកម្លាំងគ្រប់គ្រាន់សម្រាប់ធ្វើឱ្យសេដ្ឋកិច្ចមានតុល្យភាពយូរអង្វែងឡើយ។វាអាចកើតមានវិបត្តិក្នុងការផ្តោះប្តូរផលិតផលដោយសារចំនួនមនុស្សចេះតែកើនឡើងជារៀងរាល់ ថ្ងៃនិងមានសេចក្តីត្រូវការឥតព្រំដែន ចំណែកឯធម្មជាតិមានកំណត់និងចេះតែរេចរិលជារៀងរាល់ថ្ងៃ។ សេដ្ឋវិទូ កេនមានការព្រួយបារម្ភយ៉ាងខ្លាំង។ តើគេធ្វើយ៉ាង ណាដើម្បីឱ្យតម្លៃទំនិញមានស្ថិរភាព ហើយប្រជាជនមានការងារ ធ្វើពេញលេញ។

លោកកេនបានសង្កត់ធ្ងន់ថា តម្លៃទំនិញថេរ ឬកើនឡើងនោះ វាអាស្រ័យនឹងអ្នកធ្វើជំនួញនិងអង្គការពលកម្មចុះដើម្បីធ្វើឱ្យប្រជាជនមានការងារធ្វើពេញលេញនោះ តើ

ទស្សនៈរបស់លោកកេនគាត់មានយុទ្ធសាស្ត្រអ្វីដែរហើយត្រូវធ្វើដូចម្តេច ?

III. ចូរឆ្លើយសំណួរខាងក្រោម

1. ហេតុអ្វីបានជាគេថា ការរីកចម្រើនសេដ្ឋកិច្ចអាស្រ័យលើការធ្វើពាណិជ្ជកម្មនាំចេញច្រើន?
2. តើសីលធម៌និងសមធម៌មានន័យយ៉ាងដូចម្តេចក្នុងន័យពាណិជ្ជកម្ម ?ចូរពន្យល់។
3. តើមានន័យយ៉ាងដូចម្តេចចំពោះពាក្យថា បាបកម្មក្នុងន័យពាណិជ្ជកម្ម ? ចូរពន្យល់ ។
4. ហេតុអ្វីវិស័យពាណិជ្ជកម្មនិយមនាសតវត្សទី១៥ ដល់ទី១៧ ចាត់ទុកមាននិងប្រាក់សំខាន់ជាងគេ?
5. ហេតុអ្វីបានជាអ្នកធម្មជាធិបតេយ្យនិយាយថា "ដីជាប្រភពនៃទ្រព្យសម្បត្តិរបស់មនុស្សជាតិ"?
6. ហេតុអ្វីវិស័យពាណិជ្ជកម្មជាវិស័យមួយគ្រាន់តែជាការប្តូរទីតាំងផលិតផលគ្នាប៉ុណ្ណោះ?
7. តើក្រុមសេដ្ឋកិច្ចក្លាសិចបានសិក្សាលើអ្វីខ្លះ ដែលជាមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ច ?

8. ហេតុអ្វីបានជាលោកកាល់ម៉ាក្សសិក្សាលើការកេងប្រវ័ញ្ចនៃតម្លៃពលកម្មនិងការតស៊ូវណ្ណៈ ?
9. តើកេនបានពន្យល់ដូចម្តេចចំពោះ "អនិកម្មភាព អត្រាការប្រាក់ និងរូបិយវត្ថុ" ?
10. តាមគំនិតរបស់លោកកេន តើរដ្ឋគួរមានតួនាទីដូចម្តេចខ្លះក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ?
11. តើសេដ្ឋកិច្ចសម័យក្រោយលោកកេន សិក្សាអំពីអ្វីខ្លះ?

---

## ចម្លើយ

I. ចូរគូសសញ្ញា✓ក្នុងប្រអប់មុខចម្លើយណាដែលត្រឹមត្រូវ

1. តើហេតុអ្វីបានជាគេថា សម័យវិស័យពាណិជ្ជកម្មជាប់ការមន្ទិលសង្ស័យ?

☑ខ.ការធ្វើនយោបាយពាណិជ្ជកម្មគិតតែផលចំណេញនិងគ្មានសមធម៌

2. ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម អ្នកធម្មជាធិបតេយ្យយកចិត្តទុកដាក់លើ

☑ឃ.ដីជាប្រភពទ្រព្យតែមួយគត់។

3. តើក្រុមអ្នកសេដ្ឋកិច្ចតន្តីនិយមបានសិក្សាលើអ្វីសំខាន់ជាងគេ? ☑ក.កំណើនសេដ្ឋកិច្ចនិងសេរីភាពសេដ្ឋកិច្ច

4.តើលោកកាល់ម៉ាក្សបានធ្វើការសិក្សាលើអ្វីខ្លាំងជាងគេក្នុងទ្រឹស្តីរបស់គាត់?

☑ខ.ការកេងប្រវ័ញ្ចលើតម្លៃការងារនយោជិក

5. ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចតាមគំនិតលោកកេន

☑គ.រដ្ឋជាអ្នកបង្កើតឱ្យមានតម្រូវការសេដ្ឋកិច្ចក្នុងសង្គម

6.ការអន្តរាគមន៍របស់រដ្ឋក្នុងវិស័យសេដ្ឋកិច្ចនាំឲ្យ

☑ក.ប្រជាជនមានការងារពេញលេញនិងទទួលផលប្រកបដោយសមធម៌

II. តាមទស្សនរបស់លោកកេន ដើម្បីអោយប្រជាជនមានការងារធ្វើពេញលេញគឺត្រូវមានការអន្តរាគមន៍របស់រដ្ឋដែលមានតួនាទីក្នុងតំរូវការ។លោកកេនទាមទារ

អោយមាននយោបាយសកម្មមួយគឺ:

- នយោបាយថវិការ(ចំណាយនិងការទាមទារប្រាក់ជំពាក់សាធារណៈ):ក្នុងករណីដែលសេដ្ឋកិច្ចមានការធ្លាក់ចុះរដ្ឋអាចអនុវត្តដំណោះស្រាយថវិកាហិរញ្ញវត្ថុតាមរយៈការខ្ចីបុលនិងការទារអោយសងត្រលប់វិញដែលនឹងធានាដល់ការងើបបំពេញការងារឡើងវិញដែលនឹងនាំមកនូវកំណើននៃផលទុននិងការណាយសារពើពន្ធលើផលទុននិងការប្រើប្រាស់រដ្ឋគឺជាស្ថាប័នតែមួយគត់ដែលបំរើគោលបំណងសារធារណៈ។
- នយោបាយថវិការត្រូវរក្សាអោយបាននូវអត្រាការប្រាក់នៅកំរិតទាបមួយ ដើម្បីទ្រទ្រង់ការវិនិយោគទុនដោយការដាក់ទុនរាល់ថ្ងៃដែលអាចផ្តល់នូវធនលាភជាងផ្តល់ការប្រាក់(ប្រសិទ្ធភាពម៉ាស៊ីណាល់នៃមូលធនមានដូចជាអត្រាប្រាក់ចំណេញខ្ពស់ជាងការប្រាក់)។

III.1.បានជាគេនិយាយថា ការរីកចម្រើនសេដ្ឋកិច្ចអាស្រ័យលើការធ្វើពាណិជ្ជកម្មនាំចេញច្រើន ពីព្រោះនៅក្នុងស្រុកមិនមានទីផ្សារគ្រប់គ្រាន់សម្រាប់លក់ផលិតផលដែលផលិតបាននោះទេ។ ផ្ទុយទៅវិញនៅទីផ្សារអន្តរជាតិជាទីផ្សារដ៏ធំទូលាយដែលយើងមិនអាចកំណត់និងបំពេញតម្រូវការបាន ព្រមទាំងផ្តល់នូវប្រាក់ចំនេញជាច្រើនជូនជាតិ។

2. នៅក្នុងពាណិជ្ជកម្ម ពាក្យសីលធម៌មានន័យថា ការចេះគោរពគ្នា មិនបង្កភាពលម្បាកដល់នរណាម្នាក់។ ឧទាហរណ៍: ក្រុមហ៊ុនធំមានដើមទុនច្រើន មិនត្រូវលក់ទំនិញថោកជាងក្រុមហ៊ុនតូចៗចំពោះទំនិញតែមួយនោះទេ។

ពាក្យថា សមធម៌ គឺមានន័យថាមានសិទ្ធិស្មើគ្នាក្នុងការធ្វើអាជីវកម្ម។

3. ក្នុងន័យពាណិជ្ជកម្ម "បាបកម្ម" សំដៅលើការរំលោភ(អង្គាស)គ្មានព្រំដែនដើម្បីតែភាពមានបានការធ្វើជំនួញ កិច្ចការ

ខាងហិរញ្ញវត្ថុ(លោកអាវីស្លូត)។

9. ការវិនិយោគទុនគឺជាផ្នែកមិននឹងនរនៃកម្រូវការវាប្រែប្រួលខ្លាំងទាក់ទងទៅនឹងមុខរបរជំនាញនិងអត្រាការប្រាក់ដែលកំណត់ថ្លៃដើមក្នុងការខ្ចីប្រាក់។ហាំយរូបបិវត្តវិញមិនមានលក្ខណៈអព្យាក្រិតឡើយ។

10 .តាមទស្សនរបស់លោកកេនដើម្បីអោយប្រជាជនមានការងារធ្វើពេញលេញ គឺត្រូវមានការអន្តរាគមន៍របស់រដ្ឋដែលមានតួនាទីក្នុងតំរូវការ។

11.សេដ្ឋកិច្ចសម័យក្រោយពេលកេនបានសិក្សាពី:

- សមភាពកើនអត្រាបរិភោគ មិនអាស្រ័យលើថ្លៃទេ
- ការរីកចំរើនជំរុញដោយតំរូវការ
- ការជួលកម្មករ
- មិនគេនសមភាពក្រៅសេដ្ឋកិច្ច[illegible]ការងាររបស់បុគ្គលទេ
- ការវិនិយោគទុនរបស់អ្នកប្រើប្រាស់
- ការវិនិយោគទុនគឺជាផ្នែកមិននឹងនរនៃតម្រូវការ

- រូបិយវត្ថុមិនមានលក្ខណៈអព្យាក្រឹត
- សមតាមិនកើនឡើងដោយស្វ័យប្រវត្តិ។

# ចប់ដោយបរិបូណ៌